**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ភាពខុសគ្នារវាងតួនាទីមេធាវី និងតួនាទីសារការី នៅប្រទេសកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ លោក **រូណា រស្មី**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ចាំង ស៊ីណាត**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **រុណា រស្មី** ជានិស្សិតបរិញ្ញាប័ត្រនីតិសាស្ត្រ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ខ្ញុំបាទ សូមធ្វើការថ្លែងអំណរគុណ និងសូមសម្តែងនូវកតញ្ញូតាធម៌ចំពោះ៖

**លោកឪពុក រុណា សុផល** និង **អ្នកម្តាយ ធិ សុថាវី** ដែលលោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូនៗប្រកបដោយព្រហ្មវិហារធម៌ ជាពិសេសបានទំនុកបំរុងគ្រប់បែបយ៉ាងទាំងផ្នែកសម្ភារៈថវិកា ស្មារតី កម្លាំងចិត្ត និងដំបូន្មានល្អៗ តាំងពីថ្នាក់បឋមសិក្សាមកដល់បច្ចុប្បន្ននេះ ដែលអនុញ្ញាតឱ្យកូនៗមានឱកាសក្នុងការទទួលបាននូវចំណេះដឹងដែលជាប្រទីប និងជាទ្រព្យធនដែលមិនចេះបាត់បង់ជារៀងរហូត។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** និងសមាជិក-សមាជិកាទាំងអស់នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលលោកបានខិតខំក្នុងការដឹកនាំនិងអភិវឌ្ឍមាតុភូមិកម្ពុជាប្រកបដោយកត្តិបណ្ឌិត ការអភិវឌ្ឍន៍ និងសន្តិភាពពេញលេញស្មើមុខស្មើមាត់ក្នុងឆាកអន្តរជាតិ។

**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងសាកលវិទ្យាធិការរងព្រមទាំងសាស្ត្រាចារ្យ ដែលបានខិតខំបង្រៀនដោយបានផ្តល់នូវចំណេះដឹង និងបង្កជាបរិយាកាសងាយស្រួលនានាដើម្បីឲ្យយើងខ្ញុំទទួលបានចំណេះដឹងនិងបង្កជាបរិយាកាសងាយស្រួលនានាដើម្បីឲ្យយើងខ្ញុំបានទទួលយកចំណេះដឹងរហូតអាចបញ្ចប់ការសិក្សាបានដោយជោគជ័យ។

ជាពិសេសខ្ញុំបាទសូមថ្លែងអំណរគុណចំពោះ **លោកស្រី ចាំង ស៊ីណាត** ជាសាស្ត្រាចារ្យណែនាំដោយលោកស្រីបានចំណាយពេលមានវេលាមានតម្លៃលះបង់អស់ពី កម្លាំងកាយនិងកម្លាំងចិត្តមិនខ្លាចនឿយហត់ដើម្បីជួយដឹកនាំនិងជំរុញក្នុងការសរសេរជាស្នាដៃនេះតាំងពីចាប់ផ្តើមរហូតដល់ការបញ្ចប់ជាស្ថាពរ។

ជាចុងក្រោយយើងខ្ញុំ សូមបួងសួងអស់បារមីនៃវត្ថុសក្តិសិទ្ធិទាំងពួងសូមប្រសិទ្ធិពរជ័យ សិរីមង្គលវិបុលសុខគ្រប់ប្រការជូនដល់អស់លោកអ្នកមានគុណទាំងឡាយ និងសូមជួយបីបាច់ថែរក្សាលោកអ្នកមានគុណឲ្យមានសុខភាពល្អ ព្រមទាំងសូមជូនពរឲ្យលោក ជួបប្រទះនូវពុទ្ធទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ខ្ញុំបាទជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី ២១ ដែលបាន សិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចាប់តាំងពីឆ្នាំ២០១៧ រហូតដល់ឆ្នាំ ២០២១។ បន្ទាប់ពីបានសិក្សាអស់រយៈពេល ៤ ឆ្នាំកន្លងមកនេះយើងបានទទួលនូវចំណេះដឹងជាច្រើនពីសាស្ត្រាចារ្យទាំងឡាយ ដែលបានខិតខំប្រឹងប្រែងបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ ទោះបីជាប្រទេសកម្ពុជា ជួបវិបត្តិនៃជំងឺកូវីដ១៩។ ហេតុដូច្នេះហើយ ដើម្បីធ្វើការវាយតម្លៃ និងវាស់ស្ទង់ទៅលើចំណេះដឹងរបសខ្ញុំបាទ ដែលបានសិក្សាកន្លងមកក្នុងរយៈពេល ៤ឆ្នាំមកនេះ ខ្ញុំបាទលើកយកនូវប្រធានបទមួយដែលមានចំណងជើងថា **“ភាពខុសគ្នារវាងតួនាទីមេធាវីនិងតួនាទីសារការីនៅប្រទេសកម្ពុជា”** មកធ្វើការសិក្សាស្រាវជ្រាវដើម្បីធ្វើជាសារណាក្នុងការបញ្ចប់ការសិក្សា ។

មូលហេតុដែលយើងខ្ញុំសម្រេចចិត្ត លើកយកប្រធានបទនេះមកសរសេរសារណា គឺដោយមើលឃើញថា វិជ្ជាជីវៈមេធាវីនិងវិជាជីវៈសារការីជាវិជ្ជាជីវៈដែលមានតម្លៃសម្រាប់រូបខ្ញុំបំផុតបន្ទាប់ពីមានការសិក្សាស្រាវជ្រាវអំពីវិជ្ជាជីវៈទាំងពីរនេះថា ជាវិជ្ជាជីវៈដែលមានសិទ្ធិ និងអំណាចគ្រប់គ្រាន់ដើម្បីបម្រើយុត្តិធម៌យ៉ាងពិតប្រាកដហើយវិជ្ជាជីវៈនេះខ្ញុំយល់ឃើញថាសង្គមខ្មែរត្រូវការជាចាំបាច់ និងមិនអាចខ្វះបាន។ ជាពិសេសនោះខ្ញុំបាទឃើញនូវការវិវត្តន៍នៃវិជ្ជាជីវៈសារការីចាប់ផ្តើមរីកឡើង ដែលអាចមានការភ័ន្តច្រឡំគ្នា ទៅនិងវិជ្ជាជីវៈ មេធាវីនៅក្នុងតួនាទីតាក់តែងលិខិត និងប្រឹក្សា ឬផ្តល់យោបល់ ក្នុងវិស័យច្បាប់មួយចំនួន ដោយហារតែវិជ្ជាជីវៈទាំងពីរសុទ្ធសឹងតែជាអ្នកជំនាញក្នុងវិស័យច្បាប់ដូចគ្នា។តាមរយៈស្នាដៃនៃសារណារបស់ខ្ញុំបាទ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាអត្ថបទសារណាមួយនេះនឹងចូលរួមជាពិសេស ក្នុងការផ្សព្វផ្សាយ និងជាជំនួយដល់ស្មារតីផ្នែកច្បាប់ និងសម្រាប់បុគ្គលទូទៅមិនចំពោះតែអ្នកច្បាប់ ជាពិសេសសម្រាប់ សមញ្ញជនដែលចង់ស្វែងរកសេវាកម្មច្បាប់ និងសិស្ស និស្សិតណា ចង់ដឹងនិងចង់សិក្សាខាងវិជ្ជាជីវមេធាវីនិងសារការីជាដើម។

ដោយសារតែពេលវេលាក្នុងការសិក្សាស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ការសិក្សាមានរយៈពេលខ្លីហើយម្យ៉ាងវិញទៀត ដោយសារតែចំណេះដឹងខ្ញុំបាទនូវមានកម្រិត យើងខ្ញុំជឿជាក់ថា កំហុសដែលកើតមានឡើងដោយអចេតនាមួយចំនួន ដែលក្នុងនោះមានដូចជា កំហុសអក្ខរាវិរុទ្ធ ខ្លឹមសារអត្ថន័យ និងភាពខ្វះចន្លោះមិនគ្រប់ជ្រុងជ្រោយតាមខ្លឹមសារច្បាប់នឹងកើតមានក្នុងសារណានេះ ជាក់ជាពុំខាន ។ យើងខ្ញុំរីករាយទទួលនូវមតិរិះគន់ក្នុងន័យស្ថាប័នា ដើម្បីកែលំអនូវកំហុសឆ្គង ពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ ក៏ដូចជា មិត្តនិស្សិតទាំងឡាយ ដើម្បីបំពេញនូវរាល់កំហុសឆ្គងនិងចំណុចខ្វះខាតទាំងឡាយដោយក្តីសោមនស្សរីករាយព្រមទាំង សូមអរគុណ និង អរព្រះគុណ ។

# មាតិកា

**ទំព័រ**


**សេចក្ដីផ្ដើម** ........ 1

**ជំពូកទី១**

**ប្រវត្តិនៃការកកើតវិជ្ជាជីវៈមេធាវី និងសារការី**

**ផ្នែកទី១ ៖ ប្រវត្តិនៃការកកើតវិជ្ជាជីវៈមេធាវី** ........ 5

១.១. វិជ្ជាជីវៈមេធាវីមុនឆ្នាំ១៩៧៥ ........ 5

១.២. វិជ្ជាជីវៈមេធាវីក្រោយឆ្នាំ១៩៧៥ ........ 5

**ផ្នែកទី២ ៖ ប្រវត្តិនៃការកកើតវិជ្ជាជីវៈសារការី** ........ 7

២.១. វិជ្ជាជីវៈសារការីមុនឆ្នាំ១៩៧៥ ........ 7

២.២. វិជ្ជាជីវៈសារការីក្រោយឆ្នាំ១៩៧៥ ........ 10

**ជំពូកទី២**

**បែបបទនៃការប្រកបវិជ្ជាជីវៈមេធាវី និងការបង្កើតការិយាល័យមេធាវី**

**ផ្នែកទី១ ៖ បែបបទនៃការប្រកបវិជ្ជាជីវៈមេធាវី** ........ 14

១.១. តាមរយៈការប្រឡងប្រជែង ........ 14

១.២. តាមរយៈបទពិសោធន៍ច្បាប់ ........ 15

១.៣. ការចុះឈ្មោះក្នុងបញ្ជីកម្មសិក្សា និងបញ្ជីគណៈមេធាវី ........ 17

**ផ្នែកទី២ ៖ បែបបទនៃការបង្កើតការិយាល័យមេធាវី** ........ 19

២.១. លក្ខណៈសម្បត្តិជាមេធាវី ........ 19

២.២. បែបបទនៃបើកការិយាល័យមេធាវី ........ 19

២.២.១. ការិយាល័យដើម(ជាឯកត្តជន) ........ 20

២.២.២. ការិយាល័យសាខា ........ 20

**ជំពូកទី៣**

**បែបបទនៃការប្រកបវិជ្ជាជីវៈសារការី និងការបង្កើតមន្ទីរសារការី**

**ផ្នែកទី១ ៖ បែបបទនៃការប្រកបវិជ្ជាជីវៈសារការី** ........ 22

១.១. តាមរយៈការប្រឡងប្រជែង ........ 22

១.២. តាមរយៈការតែងតាំងជាសារការី .......... 23
១.២.១. ការតែងតាំងដោយប្រកាសក្រសួងយុត្តិធម៌ .......... 23
១.២.២. ការតែងតាំងដោយអនុក្រឹត្យ .......... 24
**ផ្នែកទី២ ៖ បែបបទនៃការបង្កើតមន្ទីរសារការី** .......... 24
២.១. លក្ខណៈសម្បត្តិជាសារការី .......... 24
២.២. ការតម្កល់ប្រាក់ធានានៅធនាគារជាតិនៃកម្ពុជា .......... 24

## ជំពូកទី៤

## តួនាទី និងការទទួលត្រូវរបស់មេធាវី

**ផ្នែកទី១ ៖ តួនាទីរបស់មេធាវី** .......... 26
១.១. សញ្ញាទូទៅទាក់ទង និងវិជ្ជាជីវៈរបស់មេធាវី .......... 26
១.២. តួនាទីរបស់មេធាវី .......... 27
១.២.១. ប្រឹក្សាយោបល់ក្នុងវិស័យគតិយុត្ត .......... 27
១.២.២. តាក់តែងលិខិតស្នាមគតិយុត្ត .......... 29
១.២.៣. អ្នកអាជ្ញាកណ្តាល ឬអ្នកសម្រុះសម្រួល .......... 30
១.២.៤. តំណាងដោយអាណត្តិ និងការពារកូនក្តី .......... 30
**ផ្នែកទី២ ៖ ការទទួលខុសត្រូវរបស់មេធាវី** .......... 32
២.១. កាតព្វកិច្ចគោរពនូវការសម្ងាត់វិជ្ជាជីវៈ .......... 32
២.២. ទំនួលខុសត្រូវចំពោះអតិថិជន .......... 34
២.២.១. ភក្តីភាពក្នុងការបំពេញបេសសកម្មជូនអតិថិជន .......... 34
២.២.២. កាតព្វកិច្ចរបស់មេធាវីចំពោះ អតិថិជន .......... 36
២.២.៣. ទំនួលខុសត្រូវផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌ .......... 37
២.៣. ទំនួលខុសត្រូវចំពោះគណៈមេធាវី .......... 38
២.៣.១. កាតព្វកិច្ចបង់ភាគទាន .......... 38
២.៣.២. កាតព្វកិច្ចការពារក្តីជូនជនក្រីក្រ .......... 39
២.៣.៣. កាតព្វកិច្ចចំពោះក្រុមប្រឹក្សាគណៈមេធាវី និងប្រធានគណៈមេធាវី .......... 39
២.៣.៤. បទវិន័យ .......... 40

២.៤. ការធានារ៉ាប់រងវិជ្ជាជីវៈមេធាវី...40

## ជំពូកទី៥

## តួនាទី និងការទទួលខុសត្រូវរបស់សារការី

**ផ្នែកទី១ ៖ តួនាទីរបស់សារការី**...42

១.១. សញ្ញាទូទៅទាក់ទង និងវិជ្ជាជីវៈសារការី...42

១.២. តួនាទីរបស់សារការី...44

១.២.១. តួនាទីតាក់តែងលិខិតយថាភូត...44

១.២.២.តួនាទីផ្តល់យថាភូតភាពនៃលិខិត...49

១.២.៣. ធានារ៉ាប់រង អំពីកាលបរិច្ឆេទ...50

១.២.៤. តម្កល់រក្សាទុក...51

១.២.៥. ចេញសេចក្តីចម្លងយថាភូតនៃលិខិតដែលត្រូវឲ្យមានការបញ្ជាក់...51

១.៣. អានុភាពនៃលិខិតយថាភូត...52

១.៣.១. អំណាចបន្ទាល់...52

១.៣.២. លិខិតដែលមានកាលបរិច្ឆេទសាពរ...52

១.៣.៣. លិខិតអនុវត្ត...53

**ផ្នែកទី២ ៖ ការទទួលខុសត្រូវរបស់សារការី**...53

២.១. កាតព្វកិច្ចផ្តល់យោបល់...53

២.២. កាតព្វកិច្ចគោរពនូវការសម្ងាត់វិជ្ជាជីវៈ...54

២.៣. ទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុ និងព្រហ្មទណ្ឌ...54

២.៤. អង្គភាពគ្រប់គ្រង និងដាក់ពិន័យ...54

២.៥. ការធានាសុវត្ថិភាពគតិយុត្ត...54

## ជំពូកទី៦

## ភាពខុសគ្នារវាងតួនាទីមេធាវី និងសារការី

**ផ្នែកទី១ ៖ វិជ្ជាជីវៈមេធាវី និងសារការី**...55

១.១. វិជ្ជាជីវៈមេធាវី ឯករាជ្យ និងសេរី...55

១.២. វិជ្ជាជីវៈសារការី ជាមន្ត្រីសាធារណៈ...55

**ផ្នែកទី២ ៖ ការផ្ដល់យោបល់** ........ 56
២.១. ការផ្ដល់យោបល់របស់មេធាវី ........ 56
២.២. ការផ្ដល់យោបល់របស់សារការី ........ 56
**ផ្នែកទី៣ ៖ អានុភាពនៃលិខិត** ........ 56
៣.១. លិខិតរបស់មេធាវី ........ 56
៣.២. លិខិតរបស់សារការី ........ 57
**ផ្នែកទី៤ ៖ វិសមិតភាពតួនាទី រវាងមេធាវីនិងសារការី** ........ 58
៤.១. សារការីមិនអាចតំណាងដោយអាណត្តិ និងការពារក្ដីនៅតុលាការ ........ 58
៤.២. មេធាវីមិនអាចតាក់តែង លិខិតយថាភូត ........ 60
៤.៣. មេធាវីមិនអាចផ្ដល់ យថាភូតភាពនៅលើលិខិត ........ 60
**សេចក្ដីសន្និដ្ឋាន** ........ 61
**អនុសាសន៍** ........ 63
**បញ្ជីឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងប្រទេសកម្ពុជាមុនឆ្នាំ១៩៧៥យើងឃើញមានការបង្កើតវិជ្ជាជីវៈមេធាវីដំបូង តាមរយៈការបង្កើតនូវវិជ្ជាជីវៈស្នាក្តីតាមព្រះរាជប្រកាសលេខ ៣២ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៣២ ដោយយោងតាមសេចក្តីប្រកាសរបស់លោកទីប្រឹក្សា យុខ្វាន់ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៤៨ និងក្រោយឆ្នាំ១៩៧៥ រាប់ចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ វិជ្ជាជីវៈស្នាក្តី ត្រូវបានលុបបំបាត់ចោលដោយពួកខ្មែរក្រហម ។ ចំណែកឯ វិជ្ជាជីវៈសារការីវិញ តាំងពីថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៨៦៣ ព្រះបាទនរោត្តម បានយល់ព្រម ចុះសន្ធិសញ្ញាទទួលយកអាណាព្យាបាលបារាំង ដោយសារ លោក ឌូដារ ដឺឡាក្រេ បានស្នើឲ្យព្រះអង្គដាក់កម្ពុជាឲ្យស្ថិតក្រោមអាណាព្យាបាលបារាំង និង បានសន្យាថា បារាំងនឹងការពារកម្ពុជាឲ្យរួចផុតពីការត្រួតត្រារបស់នគរសៀមនិងអាណ្ណាម ។ យើងក្រឡេកមើលឃើញប្រព័ន្ធច្បាប់ដែលអនុវត្តលើដែនដីអាណាព្យាបាលបារាំងទាំងមូល គឺ ជាប្រព័ន្ធច្បាប់ចាស់របស់ខ្មែរ ទោះបីបារាំងបានមកដាក់អាណាព្យាបាលមកកម្ពុជាក៏ដោយ ។ ចាប់ពីឆ្នាំ ១៩១១ ទៅទើបអាជ្ញាធរបារាំងចាប់ផ្តើមបញ្ចូលច្បាប់ទំនើបមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយសារសន្ធិសញ្ញាកម្ពុជា-បារាំង ព្រះបាទនរោត្តម បានសន្យាទទួលយកនូវគ្រប់កំណែទំរង់រដ្ឋបាល យុត្តាធិការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ដែលប្រទេសបារាំងនឹងធ្វើ ដែលប្រភពមួយ ឲ្យលោកមេធាវី អាំង អេងថុង សរសេរ ក្នុងសៀវភៅវិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជា(ដោយសង្ខេប), ក្នុងទំព័រទី១៧បានសរសេរថា សារការីជាមុខវិជ្ជាជីវៈមួយ ដែលបានចូលមកប្រទេសកម្ពុជាយើងកាលពីដើមសតវត្សទី២០ និងក្រោយឆ្នាំ១៩៧៥មក រាប់ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ វិជ្ជាជីវៈសារការី ត្រូវបានលុបបំបាត់ចោលដោយពួកខ្មែរក្រហម ។

## ២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

ម៉្យាងវិញទៀតបើយើងក្រឡេកមើលអំពីល័ក្ខខណ្ឌដើម្បីទទួលបានមុខងារជាមេធាវី និងសារការី វិជ្ជាជីវៈទាំងពីរនេះ សុទ្ធសឹងតែជាអ្នកជំនាញវិជ្ជាជីវៈក្នុងវិស័យច្បាប់ ដូចនេះហើយទើបមានមនុស្សជាច្រើនទាំងសមញ្ញជន និងនិស្សិតច្បាប់អាចចោទជាសំណួរថា៖

- តើវិជ្ជាជីវៈរវាងមេធាវី និងសារការី មានតួនាទីខុសគ្នាត្រង់ណាខ្លះ ?
- តើឯករាជ្យភាពរវាងមេធាវី និងសារការីខុសគ្នាដែលឬទេ ?
- តើលិខិតរបស់មេធាវីមានអានុភាពដូចលិខិតសារការីដែលឬទេ ?

- តើសារការីអាចជាអាជ្ញាកណ្តាល ឬអ្នកផ្សះផ្សារបានទេ ?
- តើមេធាវីអាចតាក់តែងមតកសាសន៍ជាលិខិតយថាភូតដូចសារការីបានដែលឬទេ ?
- តើសារការីអាចតំណាងដោយអាណត្តិបានដែលឬទេ ?
- តើសារការីអាចការពារក្តីនៅតុលាការបានដែលឬទេ ?
- តើមេធាវីអាចតាក់តែងលិខិតយថាភូតបានដែលឬទេ ?
- តើមេធាវីអាចធ្វើលិខិតបញ្ជាក់បានដែលឬទេ ?
- តើសាការីអាចប្រឹក្សាយោបល់ក្នុងវិស័យគតិយុត្តិបានដូចមេធាវីដែលឬទេ ? បើបានតើខុសច្បាប់ស្តីពីលក្ខន្តិកៈមេធាវីបានដែលឬទេ ?
- តើមូលហេតុអ្វីបានមានការកកើតវិជ្ជាជីវៈមេធាវី និងសារការីនៅកម្ពុជា ?
- តើដើម្បីក្លាយខ្លួនជាមេធាវី និងសារការីត្រូវបំពេញបែបបទអ្វីខ្លះដើម្បីចូលប្រកបវិជ្ជាជីវៈ ?

ហេតុដូចនេះហើយបានជាយើងបានលើក **ប្រធានបទ “ភាពខុសគ្នារវាងតួនាទីមេធាវី និងតួនាទីសារការីនៅកម្ពុជា”** មកបកស្រាយ ដោយផ្អែកជាចម្បងនៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និង អនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីនៅកម្ពុជាជាដើម។

## ៣. គោលបំណងនៃការស្រាវជ្រាវ

សារណានេះមានគោលបំណងធ្វើការសិក្សាស្វែងយល់អំពី ប្រវត្តិនៃការកកើតវិជ្ជាជីវៈមេធាវី និង សារការីក្នុងប្រទេសកម្ពុជា ព្រមទាំងបែបបទនៃការប្រកបវិជ្ជាជីវៈមេធាវី និង ការបង្កើតការិយាល័យមេធាវី និង បែបបទនៃការប្រកបវិជ្ជាជីវៈសារការី និងបង្កើតមន្ទីរសារការី ជាពិសេសតួនាទី និងការទទួលត្រូវរបស់មេធាវី ហើយបន្ថែមនូវតួនាទី និងការទទួលត្រូវរបស់សារការី ដែលជាមូលដ្ឋានគ្រឹះ ដើម្បីឈ្វេងយល់ពីភាពខុសគ្នារវាងតួនាទីមេធាវី និងសារការីនៅកម្ពុជា។

## ៤. វិធីសាស្ត្រនៃការស្រាវជ្រាវ

សារណានេះធ្វើការស្រាវជ្រាវប្រព័ន្ធច្បាប់ពាក់ព័ន្ធនឹង ប្រព័ន្ធមេធាវី និងសារការីដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានានៅក្នុងប្រទេសកម្ពុជា។ ម៉្យាងវិញទៀត ការស្រាវជ្រាវនេះគ្រាន់តែជាការរៀបរៀងបង្ហាញនូវ ឯកសារដែលមានស្រាប់និងធ្វើការវិភាគវែកញែករកលទ្ធផល

នានាដោយផ្អែកលើឯកសារទាំងស្រុង។ ជាពិសេសការស្រាវជ្រាវមួយនេះ គ្រាន់តែចង់រំលេចឡើងឲ្យឃើញនូវភាពខុសគ្នាមួយចំនួនពាក់ព័ន្ធ នឹង តួនាទីមេធាវី និងសារការីតែប៉ុណ្ណោះ។

ការស្រាវជ្រាវនេះបានធ្វើឡើងដោយការប្រមូលទិន្នន័យពិតមានតាមវិធីជាច្រើន។ ជាដំបូង គឺតាមរយៈការស្វែងរកឯកសារពាក់ព័ន្ធប្រធានបទ តាមបណ្ណាគារ និងស្រាវជ្រាវលើស្នាដៃស្រាវជ្រាវកន្លងមកទាក់ទងនឹងមេធាវី និងសារការីរបស់សាស្ត្រាចារ្យ និងសិស្សច្បង ។ បន្ទាប់មកធ្វើការស្វែងយល់បន្ថែមតាមរយៈការអានកម្រងច្បាប់ និងបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងប្រព័ន្ធ មេធាវី និងសារការីនៅប្រទេសកម្ពុជា។ បន្ទាប់មកធ្វើការ ប្រមូលព័ត៌មានដែលមានបច្ចុប្បន្នភាពនានាតាមរយៈបណ្តាញសារពត៌មានផ្លូវការមួយចំនួនក្នុងប្រទេសកម្ពុជា។ ក្នុងដំណើរការនៃការប្រមូលទិន្នន័យខាងលើភាគច្រើនធ្វើតាមបណ្តាញអ៊ីនធើណេត និងបណ្ណាល័យច្បាប់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចជាដើម។

## ៥. សារប្រយោជន៍នៃការស្រាវជ្រាវ

សារណានេះ ផ្តល់អត្ថប្រយោជន៍ជាច្រើនដល់វិស័យស្រាវជ្រាវផ្ទាល់ ចំពោះសាធារណជន និងសង្គមជាតិទាំងមូលផងដែរ។ តាមរយៈការស្រាវជ្រាវនេះបានប្រមូលនូវពត៌មានជាច្រើន និងការវិភាគ បកស្រាយ រកលទ្ធផលថ្មីៗមួយចំនួន ដែលជាប្រយោជន៍សម្រាប់អ្នកសិក្សា សិស្ស និស្សិតដែលធ្វើការស្រាវជ្រាវក្រោយៗទៀតដើម្បីធ្វើការស្វែងយល់ និងយកទៅពិចារណា។ បន្ថែមពីនេះទៀត សារណានេះក៏ជាប្រភពពត៌មានទូទៅសម្រាប់សារធារណជន ជាពិសេសនិស្សិតផ្នែកនីតិសាស្ត្រដែលមានបំណងចង់ក្លាយជាមេធាវី និងសារការី ឲ្យយល់កាន់តែច្បាស់ពីលក្ខខណ្ឌរបស់វិជ្ជាជីវៈមួយនេះផងដែរ។ ជាចុងក្រោយ សារណានេះបានផ្តល់នូវការប្រៀបធៀបដែលបង្ហាញឲ្យឃើញពីភាពខុសគ្នារវាងតួនាទីមេធាវី និងតួនាទីសារការីនៅកម្ពុជា ព្រមទាំងផ្តល់អនុសាសន៍មួយចំនួនក្នុងការចូលរួមចំណែកមួយផ្នែកតូចដើម្បីពង្រីកការយល់ដឹង និងផ្សព្វផ្សាយ ក៏ដូចជាពង្រឹងនូវប្រព័ន្ធមេធាវី និងសារការីនៅកម្ពុជា។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដូចនេះប្រធានបទស្រាវជ្រាវអំពី ភាពខុសគ្នារវាងតួនាទីមេធាវី និងតួនាទីសារការីនៅប្រទេសកម្ពុជា ខាងលើនេះ ត្រូវបានបែងចែកការបកស្រាយជាប្រាំមួយជំពូកដូចខាងក្រោម៖

- **ជំពូកទី១ ប្រវត្តិនៃការកកើតវិជ្ជាជីវៈមេធាវី និងសារការីក្នុងប្រទេសកម្ពុជា** ដែលការបកស្រាយអំពី ប្រវត្តិនៃការកកើតវិជ្ជាជីវៈមេធាវី និង ប្រវត្តិនៃការកកើតវិជ្ជាជីវៈសារការី

- **ជំពូកទី២ បែបបទនៃការប្រកបវិជ្ជាជីវៈមេធាវី និងការបង្កើតការិយាល័យមេធាវី** ដែលការបកស្រាយផ្ដោតសំខាន់ទៅលើ លក្ខខណ្ឌដើម្បីទទួលបានមុខងារជាមេធាវី និង បែបបទនៃការបង្កើតការិយាល័យមេធាវី
- **ជំពូកទី៣ បែបបទនៃការប្រកបវិជ្ជាជីវៈសារការី និងបង្កើតមន្ទីរសារការី** ដែលការបកស្រាយ អំពី បែបបទនៃការប្រកបវិជ្ជាជីវៈសារការី និង បែបបទនៃការបង្កើតមន្ទីរសារការី
- **ជំពូកទី៤ តួនាទី និងការទទួលត្រូវរបស់មេធាវី** ដែលការបកស្រាយ បង្ហាញអំពី តួនាទីរបស់មេធាវី និងការទទួលខុសត្រូវរបស់មេធាវី
- **ជំពូកទី៥ តួនាទី និងការទទួលត្រូវរបស់សារការី** ដែលការបកស្រាយអំពី តួនាទីរបស់សារការី និងការទទួលខុសត្រូវរបស់សារការី
- **ជំពូកទី៦ ភាពខុសគ្នារវាងតួនាទីមេធាវី និងសារការី**

# ជំពូកទី១

# ប្រវត្តិនៃការកកើតវិជ្ជាជីវៈមេធាវី និងសារភាវី

## ផ្នែកទី១ ៖ ប្រវត្តិនៃការកកើតវិជ្ជាជីវៈមេធាវី

### ១.១. វិជ្ជាជីវៈមេធាវីមុនឆ្នាំ១៩៧៥

វិជ្ជាជីវៈមេធាវីនៅក្នុងប្រទេសកម្ពុជាមុនឆ្នាំ១៩៧៥ ឃើញមានការបង្កើតវិជ្ជាជីវៈមេធាវីដំបូង តាមរយៈការបង្កើតនូវវិជ្ជាជីវៈស្មាក្តីតាមព្រះរាជប្រកាសលេខ ៣២ ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ១៩៣២ ដោយយោងតាមសេចក្តីប្រកាសរបស់លោកទីប្រឹក្សា យូខ្វាន់ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៤៨ ។ កាលនោះគេមិនហៅថាវិជ្ជាជីវៈមេធាវីទេ គឺគេហៅថា “ វិជ្ជាជីវៈស្មាក្តី ” ដែលអ្នកប្រកបរបរនេះគេហៅថា “ អ្នកថណាយក្តី ” ។ ដោយសារមានសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ ទើបធ្វើឱ្យសិទ្ធិការពារខ្លួនចំពោះមុខច្បាប់បានបើកចំហរកាន់តែទូលាយ ដែលបណ្តាលឱ្យព្រះរាជប្រកាសលេខ ៣២ ខាងលើបានកែប្រែខ្លះៗតាមព្រះរាជក្រមលេខ ៦៤៨ន.ស ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៥១ ។[1]

### ១.២. វិជ្ជាជីវៈមេធាវីក្រោយឆ្នាំ១៩៧៥

ចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ វិជ្ជាជីវៈស្មាក្តី ត្រូវបានលុបបំបាត់ចោលដោយពួកខ្មែរក្រហម ។

នៅក្រោយថ្ងៃរំដោះ ៧ ខែមករា ឆ្នាំ ១៩៧៩ តុលាការបដិវត្តប្រជាជនកម្ពុជាត្រូវបានបង្កើតឡើងកាលនេះមានអ្នកការពារក្តីដែរ ដែលអ្នកទាំងនោះ ត្រូវបានជ្រើសរើសចេញពីអង្គការមហាជននានា... ។ល។ ព្រោះកាលនោះរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចែងត្រង់មាត្រា ៨៥ កថាខណ្ឌទី២ ថា “ ជនជាប់ចោទមានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬ ពឹងមេធាវី ឬពឹងអ្នកដ៏ទៃណាម្នាក់អោយជួយការពារ ” ។

នៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១ កិច្ចព្រមព្រៀងទីក្រុងប៉ារីសត្រូវបានបង្កើតឡើង ។ នៅដំណាក់កាលពីឆ្នាំ ១៩៩១ ដល់ ១៩៩៣ UNTAC បានធ្វើបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅកម្ពុជាក្នុងសម័យអន្តរកាល ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ដែលក្នុងច្បាប់នេះបានកំណត់អំពីសិទ្ធិទទួលបាននូវទីប្រឹក្សា ឬមេធាវីផងដែរ ចំពោះ ជន

[1] សូមមើលព្រឹត្តិបត្រ មេធាវី ច្បាប់ ចេញប្រចាំត្រីមាសទី១ ឆ្នាំ១៩៩៩លេខ១របស់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ទំព័រ២។ មេធាវី ប៊ុន ហុន, ក្រមសិលធម៌ និង ការទទួលខុសត្រូវចំពោះវិជ្ជាជីវៈមេធាវី, សីហា, ២០០៩

ជាប់ចោទគ្រប់រូប ។ នៅសម័យនោះគេឃើញមានអ្នកការពារក្តីជាអ្នកដើរតួជាមេធាវី ព្រោះយើងមិនទាន់មានច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៅឡើយ ។ តាមច្បាប់ព្រហ្មទណ្ឌអន្តរកាលនេះ បានអនុញ្ញាតអោយជនដែលមានសញ្ញាប័ត្រមធ្យមសិក្សាអាចតំណាងជនជាប់ចោទបានតាមមាត្រា ៧ នៃច្បាប់នេះ ព្រោះកាលនោះមានអ្នកច្បាប់នៅតិចតួចណាស់ ។

នៅឆ្នាំ ១៩៩៤ ក្រសួងយុត្តិធម៌ បានសហការជាមួយគណៈគណៈមេធាវីលីយ៉ុង ប្រទេសបារាំងបង្កើតវគ្គបណ្តុះបណ្តាលមេធាវីលើកដំបូងឆ្លងតាមការប្រលងប្រជែង ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌ និងគណៈមេធាវីលីយ៉ុង ។ ជាលទ្ធផលនៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៥ វគ្គបណ្តុះបណ្តាលនេះ ត្រូវបានបញ្ចប់ដោយមានអ្នកប្រលងជាប់បានវិញ្ញាប័នបត្រសម្បទាខាងវិជ្ជាជីវៈមេធាវីចំនួន ២៩ នាក់ ។ អ្នកទាំងនេះនៅមិនទាន់ក្លាយជាមេធាវីទាំងស្រុងទេ ព្រោះនៅមិនទាន់មានច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៅឡើយ ។[2]

នៅក្នុងសម័យអន្តរកាល និងមុនច្បាប់ស្តីពីលក្ខន្តិកៈមេធាវីត្រូវបានអនុម័ត នៅពេលដែលគណៈមេធាវីមិនទាន់បានបង្កើតនៅឡើយ ការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈមេធាវីត្រូវសុំពីមហាអយ្យការអមសាលាឧទ្ធរណ៍ ។ បន្ទាប់ពីបានទទួលពាក្យសុំមក មហាអយ្យការអមសាលាឧទ្ធរណ៍កោះហៅអ្នកដែលមានគុណសម្បត្តិប្រកបវិជ្ជាជីវៈនេះមកធ្វើសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍ ហើយបន្ទាប់មកបានក្លាយទៅជាមេធាវីដែលអាចប្រកបវិជ្ជាជីវៈច្បាប់បាន ។[3] តែបើយោទៅតាម ឯកសារ របស់វិទ្យាស្ថានខ្មែរដើម្បីលិទ្ធិប្រជាធិបតេយ្យ ស្តីអំពី “ តួនាទីរបស់មេធាវី ” ថាដើម្បីអនុវត្តការងារជាមេធាវីបាន គេចាំបាច់ត្រូវតែសុំការអនុញ្ញាតដើម្បីអនុវត្តការងារជាមេធាវី ពីអគ្គព្រះរាជអាជ្ញាដែលនៅអមសាលាឧទ្ធរណ៍ នៅពេលនោះមន្ត្រីតុលាការទាំងអស់ ជាពិសេសមន្ត្រីដែលមានស័ក្តិខ្ពស់ជាអគ្គព្រះរាជអាជ្ញា មានសម្ព័ន្ធភាពយ៉ាងជិតដិតជាមួយគណៈបក្សកាន់អំណាច ហើយត្រូវបានជ្រើសរើសសំរាំងដោយមន្ត្រីរដ្ឋាភិបាល មុនពេលដែល គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានគេបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥ ។[4]

នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ត្រូវបានអនុម័តដោយរដ្ឋសភា ហើយត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/ រកម/០៨៩៥ / ០៦ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥ ។

[2] មេធាវី ប៊ុន ហុន, ក្រមសិលធម៌ និង ការទទួលខុសត្រូវចំពោះវិជ្ជាជីវៈមេធាវី, សីហា, ២០០៩

[3] កុយនាម, ដំណើរការក្តីនៅក្នុងតុលាការនៅកម្ពុជា

[4] វិទ្យាស្ថានខ្មែរដើម្បីលិទ្ធិប្រជាធិបតេយ្យ, តួនាទីរបស់មេធាវី, ទំព័រ ៣៩

ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បានចែងកំណត់ពីការរៀបចំ និងប្រព្រឹត្តទៅនៃវិជ្ជាជីវៈមេធាវី ហើយបានផ្តល់អំណាចផ្តាច់មុខក្នុងការប្រកបរបរវិជ្ជាជីវៈមេធាវី ជូនទៅមេធាវី ។ ទោះជាមានច្បាប់ស្តីពីលក្ខន្តិកៈមេធាវីក៏ដោយ ក៏ការប្រកបវិជ្ជាជីវៈនេះ ត្រូវមានបទបញ្ញត្តិផ្សេងទៀតដើម្បីគ្រប់គ្រង និង ការពារតំលៃវិជ្ជាជីវៈផងដែរ គឺបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ដែលអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ និងក្រមសីលធម៌ នៃមេធាវី ដែលបានចុះក្នុងបញ្ជីគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័ត ដោយក្រុមប្រឹក្សាគណៈមេធាវី នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥។

បន្ទាប់ពីច្បាប់ស្តីពីលក្ខន្តិកៈមេធាវីបានអនុម័តមកមេធាវីដែលទទួលយល់ព្រមដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចូលរួមក្នុងសន្និបាតដើម្បីបង្កើត "គណៈមេធាវីចាប់ពីពេលនោះមកការប្រកបវិជ្ជាជីវៈមេធាវីទាំងអស់នៅប្រទេសកម្ពុជាត្រូវបានអនុម័តដោយអង្គការមួយហៅថា " គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា " ។[5]

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតឡើងដំបូងតាមរយៈមហាសន្និបាតរបស់គណៈមេធាវី ដែលបានធ្វើឡើងនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥ ដោយមានសមាជិកសរុបចំនួន ៣៣ នាក់ ដែលបានស្បថចូលប្រកបវិជ្ជាជីវៈមេធាវីមុនគេ ។ ក្នុងសម័យនោះមាន **លោកបណ្ឌិត សាយ បូរី** ជាប្រធានដឹកនាំគណៈមេធាវី និងមានសមាជិកក្រុមប្រឹក្សាគណៈមេធាវីចំនួន ៩រូប ជាអ្នកគ្រប់គ្រងគណៈមេធាវី ។[6]

## ផ្នែកទី២ ៖ ប្រវត្តិនៃការកើតវិជ្ជាជីវៈសារការី

ដើម្បីឲ្យងាយស្រួលក្នុងការស្វែងយល់អំពីវិជ្ជាជីវៈសារការីនៃប្រទេសកម្ពុជា ដែលចាប់កំណើតតាំងពីសតវត្សទី២០ យើងខ្ញុំសូមបង្ហាញដោយធ្វើការបែងចែកនូវប្រវត្តិរបស់សារការីជាពីរដំណាក់កាលគឺ វិជ្ជាជីវៈសារការីមុនឆ្នាំ១៩៧៥(២.១) និងក្រោយឆ្នាំ១៩៧៥(២.២) ។

### ២.១. វិជ្ជាជីវៈសារការីមុនឆ្នាំ១៩៧៥

សារការីជាមុខវិជ្ជាជីវៈមួយ ដែលបានចូលមកប្រទេសកម្ពុជាយើងកាលពីដើមសតវត្សទី២០ ។ នៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៨៦៣ ព្រះបាទនរោត្តម បានយល់ព្រម ចុះសន្ធិសញ្ញាទទួលយកអាណាព្យាបាលបារាំង ដោយសារ លោក ឌូដារ ដឺឡាក្រេ បានស្នើឲ្យព្រះអង្គដាក់កម្ពុជាឲ្យស្ថិតក្រោមអាណាព្យាបាលបារាំង និង បាន

[5] កុយនាម, ដំណើរការក្តីនៅក្នុងតុលាការនៅកម្ពុជា

[6] មេធាវី ប៊ុន ហុន, ក្រមសិលធម៌ និង ការទទួលខុសត្រូវចំពោះវិជ្ជាជីវៈមេធាវី, សីហា, ២០០៩

សន្យាថា បារាំងនឹងការពារកម្ពុជាឲ្យរួចផុតពីការត្រួតត្រារបស់នគរសៀម និងអាណ្ណាម ។[7] បើយើងក្រឡេកមកមើល ប្រព័ន្ធច្បាប់ដែលអនុវត្តលើដែនដីអាណាព្យាបាលបារាំងទាំងមូល គឺ ជាប្រព័ន្ធច្បាប់ចាស់របស់ខ្មែរ ទោះបីបារាំងបានមកដាក់អាណាព្យាបាលមកកម្ពុជាក៏ដោយ ។ ចាប់ពីឆ្នាំ ១៩១១ ទៅ ទើបអាជ្ញាធរបារាំងចាប់ផ្តើមបញ្ចូលច្បាប់ទំនើបមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយសារ សន្ធិសញ្ញាកម្ពុជា-បារាំង ព្រះបាទនរោត្តម បានសន្យាទទួលយកនូវគ្រប់កំណែទំរង់រដ្ឋបាល យុត្តាធិការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ដែលប្រទេសបារាំងនឹងធ្វើ ។ អាជ្ញាធរបារាំង បានបង្កើតគណៈកម្មការដល់ទៅ ៥ ជាបន្តបន្ទាប់ ដើម្បីពិនិត្យមើលច្បាប់រដ្ឋប្បវេណីរបស់ខ្មែរ ។ គណៈកម្មការទាំង ៥ ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ដោយព្រះរានុក្រិត្យចំនួន ៥ ដែលក្នុងនោះ ព្រះរាជានុក្រឹត្យពីរ ចេញនៅឆ្នាំ ១៩១២ ព្រះរាជានុក្រឹត្យមួយចេញនៅឆ្នាំ ១៩១៣ ព្រះរាជានុក្រិត្យមួយចេញនៅ ឆ្នាំ ១៩១៨ និងព្រះរាជានុក្រឹត្យមួយទៀត ចេញនៅឆ្នាំ ១៩១៩ ។ កម្មវិធីកំណែទម្រង់ដ៏ធំមួយបានសំរេចជាស្ថាពរ នៅឆ្នាំ ១៩២០ ។ ព្រះរាជប្បញ្ញត្តិចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩២០ បានប្រកាសឱ្យប្រើក្រមថ្មីមួយចាប់ពីថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ១៩២០ ត ទៅ គឺក្រមរដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី និងការរៀបចំសាលាជំរះក្តីរដ្ឋប្បវេណី ។[8]

នៅក្នុងក្រមរដ្ឋប្បវេណីចាស់ដែលបារាំងបានជួយកំណែទម្រង់ប្រកាសឱ្យប្រើនៅឆ្នាំ ១៩២០ នោះ យើងឃើញមាននៅក្នុង ជំពូកទី៣ ហ៊ីប៉ូតែក មាត្រា ១៣៦៥ បានចែងថា៖ ហ៊ីប៉ូតែក ជាកិច្ចសន្យាដែលត្រូវប្រតិបត្តិតាមល័ក្ខខណ្ឌនៃច្បាប់បារាំង ដែលស្តីពីធ្វើបែបណាដែលទុកថាត្រឹមត្រូវគឺថាត្រូវធ្វើនៅសារការីបើមិនដូច្នោះទេត្រូវទុកជាមោឃៈជាដាច់ខាត។ខ្លឹមសារមាត្រា១៣៦៥ នៃក្រមរដ្ឋប្បវេណីចាស់ឆ្នាំ ១៩២០ មានន័យថា ការបង្កើតកិច្ចសន្យាហ៊ីប៉ូតែកគឺជាសមត្ថកិច្ចផ្តាច់មុខរបស់សារការី និងត្រូវប្រតិបត្តិតាមល័ក្ខខណ្ឌនៃច្បាប់បារាំង និង បានបញ្ជាក់ផងដែលថា វិជ្ជាជីវៈសារការី បានប្រព្រឹត្តទៅក្រោមឥទ្ធិពលនៃច្បាប់បារាំង ។ នៅសម័យនោះតាមការបង្ហាញខ្លះៗ មន្ទីសារការីបុគ្គលិកធ្វើការជាជនជាតិបារាំងសុទ្ធ ។ ប៉ុន្តែមិនច្រើនទេ ប្រហែលជា ២ ទៅ ៣ នាក់ប៉ុណ្ណោះពីព្រោះសម័យនោះ ការងារសារការីនេះពុំទាន់ជ្រួតជ្រាបដល់ប្រជាពលរដ្ឋភាគច្រើនទេ ។ ពលរដ្ឋដែលស្គាល់មុខងារ និងការងាររបស់សារការីនេះ មានតែអ្នកជំនួញ និងអ្នកនៅទីផ្សារមួយចំនួនតូច ។ កន្លែងសារការីធ្វើការ គេប្រែជាខ្មែរយើងថា មន្ទីរ ។ សារការីខ្មែរយើងដំបូង គឺលោកសារការី អ៊ឹង អ៊ី ដែលមានមន្ទីរសារការីនៅ

[7] សេង ឌីណា, ការដាក់អាណាព្យាបាលបារាំងនៅកម្ពុជានៅឆ្នាំ ១៨៦៣, ចុះផ្សាយនៅថ្ងៃ ០៩ ខែ កម្ភៈ ឆ្នាំ ២០១៤ និង កែប្រែថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៥ https://www.rfi.fr/km/french-protectorate-over-cambodia

[8] សេចក្តីផ្តើមនៃនីតិកម្ពុជា, ទំព័រទី១៥, ១៦

ភ្នំពេញ ។ ចំណែកឯកិច្ចការដែលធ្វើគឺជាភាសាបារាំងលាយ និងភាសាខ្មែរ ។ បន្ទាប់មកមានលោកសារការី ចេង ហេង ក្រោយមកទៀត គឺលោកសារការី ប៉ុក ធួន ។

នៅថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៥៣ ទើបបារាំងព្រមប្រគល់ឯករាជ្យពេញលេញ ឲ្យព្រះរាជាណាចក្រកម្ពុជាយើងក្រោមព្រះរាជបូជនីយកិច្ច ទាមទារឯករាជ្យពីព្រះករុណាសម្តេចព្រះមហាវីរៈក្សត្រ សម្តេចព្រះនរោត្តម សីហនុបានទាមទារឯករាជ្យពីប្រទេសបារាំងដោយបានចរចារផ្ទេរអធិបតេយ្យភាពមកឲ្យកម្ពុជាជាបន្ទាន់ ហើយព្រះអង្គបានធ្វើយុទ្ធនាការតស៊ូជាច្រើនឆ្នាំ ។[9]

បន្ទាប់ពីកម្ពុជាទទួលបានឯករាជ្យពេញលេញពីប្រទេសបារាំងនៅថ្ងៃ ២៨ ខែ សីហា គ.ស. ១៩៥៣ មានធ្វើពិធីសារមួយ ដែលរដ្ឋាភិបាលបារាំងប្រគល់សមត្ថកិច្ចតុលាការមកឱ្យប្រទេសកម្ពុជាយើង ។ ច្បាប់ខ្មែរក៏បានក្លាយទៅជាកម្មសិទ្ធិ និងកិច្ចការរបស់អ្នកច្បាប់ខ្មែរដោយខ្លួនឯង ។ ត្បិតអ្នកច្បាប់ខ្មែរទាំងនេះនៅតែទទួលឥទ្ធិពលពីច្បាប់ដែលគេអនុវត្តនៅប្រទេសបារាំងបច្ចុប្បន្នក៏ដោយ ប៉ុន្តែអ្នកច្បាប់ទាំងនេះបានក្លាយទៅជាម្ចាស់ដោយខ្លួនឯងនៃការរីកចំរើនទស្សនៈច្បាប់ដោយឡែករបស់ខ្មែរមួយ ។

នៅថ្ងៃទី ៤ ខែ វិច្ឆិកា គ.ស. ១៩៥៤ ព្រះរាជក្រមលេខ៩១០ន.ស. បានបង្កើតឡើង និងត្រូវបានឡាយព្រះហស្តលេខាដោយព្រះករុណាជាអង្គម្ចាស់ជីវិតលើត្បូង។ព្រះរាជក្រមសរសេរជាភាសាខ្មែរផង និងបកប្រែជាភាសាបារាំងផង ដែលបទបញ្ញត្តិទាក់ទងនឹងសារការី ថែមទាំងមានភាពលម្អិតជាងក្រមរដ្ឋប្បវេណីចាស់ឆ្នាំ ១៩២០ផងដែរ ។ នៅក្នុងមាត្រា ១ នៃព្រះរាជក្រមលេខ៩១០ន.ស.ឆ្នាំ១៩៥៤ បានបញ្ញតិអំពីមុខងាររបស់សារការីថា សារការីជាមន្ត្រីសាធារណៈ ដែលត្រូវបានតែងតាំងឡើងតាមព្រះរាជក្រឹតនៃរដ្ឋាភិបាល ដោយមានបំណង៖

**ទី១.** ទទួល និងធ្វើតាមតម្រូវការនៃលិខិត ឬ កិច្ចសន្យាទាំងឡាយ ឲ្យក្លាយទៅជាលិខិតតាមផ្លូវច្បាប់ ដូចជាលិខិតរបស់រាជការសាធារណៈ (លិខិតយថាភូត) កាន់អំណាចសាធារណៈ ។

**ទី២.** ធ្វើការបញ្ជាក់កាលបរិច្ឆេទនៃលិខិតនេះ ទទួលរក្សាលិខិតនេះទុក និងចេញឲ្យសេចក្តីដើម ឬ សេចក្តីចម្លងលិខិតនេះ ។ ករណីកិច្ចជាដើមរបស់សារការី គឺត្រូវបំភ្លឺ ឲ្យដំណឹង ទន្ទានគូសញ្ញាអំពីលិខិត ដែលអ្នកនេះបានធ្វើ ឬមានបំណងនឹងធ្វើ ក្នុងឋានៈខ្លួនឯងជាមន្ត្រីសាធារណៈ ។ ក្នុងករណីណាក៏ដោយ មន្ត្រីនេះមិនអាចបំរាស់ពីការ

[9] ភិន សុភី, ប្រវត្តិទាមទារឯករាជ្យពីបារាំង ដោយព្រះបាទនរោត្តមសីហនុ៩វិច្ឆិកា, ចុះផ្សាយនៅថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០២០ https://vayofm.com/news/detail/105576-841121735.html

ទទួលខុសត្រូវដោយថា ខ្លួនគ្រាន់តែទទួលកត់តាមសេចក្តី ឬកត់តាមលិខិតរបស់គូសសញ្ញាដោយឥតល្អៀង ដើម្បីឲ្យបំពេញលក្ខណៈច្បាប់ទេ ។ សារការីនីមួយៗត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនរបស់គេ ។[10] ប៉ុន្តែព្រះរាជក្រម លេខ៩១០ ន.ស. ឆ្នាំ ១៩៥៤ ដែលបញ្ញត្តិអំពីមុខងាររបស់សារការីនេះត្រូវបាននិរាករណ៍ដោយតុណ្ហ ដោយសារ ប្រទេសកម្ពុជាស្ថិតក្នុងរបបខ្មែរក្រហមពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ។

## ២.២. វិជ្ជាជីវៈសារការីក្រោយឆ្នាំ១៩៧៥

ចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ វិជ្ជាជីវៈសារការី ត្រូវបានលុបបំបាត់ចោល ដោយពួកខ្មែរក្រហម ។ អង្គការសហប្រជាជាតិបានចូលអន្តរាគម ដើម្បីជួយបញ្ចប់ជំលោះនៅកម្ពុជា ក្រោយការ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសនៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ និង បានរៀបចំការបោះឆ្នោតជា ទូទៅមួយ នៅថ្ងៃទី ២៣ ដល់ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៣ ក្រោមការត្រួតពិនិត្យផ្ទាល់របស់អង្គការសហប្រជា ជាតិ និងក្រុមប្រឹក្សាជាតិជាន់ខ្ពស់ដែលមានសម្តេចព្រះបាទ នរោត្តម សីហនុ ជាព្រះប្រធាន ។ ការបោះឆ្នោតបាន អនុញ្ញាត ឲ្យមានការបង្កើតជាសភាធម្មនុញ្ញមួយ ដែលមានតួនាទីអនុម័តរដ្ឋធម្មនុញ្ញថ្មីមួយ ។ រដ្ឋធម្មនុញ្ញនេះត្រូវ បានអនុម័ត នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ និងប្រកាសឲ្យប្រើជាផ្លូវការ នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ដោយព្រះបាទ នរោត្តម សីហនុ បន្ទាប់ពីព្រះអង្គ ត្រូវបានសភាធម្មនុញ្ញប្រកាសឲ្យឡើងគ្រងរាជសម្បត្តិសាជាថ្មី នៅថ្ងៃនោះដែរ ។[11]

ដើម្បីឆ្លើយតបទៅនឹងស្មារតីរដ្ឋធម្មនុញ្ញ និងដើម្បីឲ្យប្រទេសកម្ពុជាមាននីតិរដ្ឋពេញលេញជាពិសេស ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីកំណែទម្រង់ប្រព័ន្ធច្បាប់ និងប្រព័ន្ធតុលាការដែលជាស្នូល នៃដំណើរការប្រជាធិបតេយ្យភាវូបនីយកម្មការកាត់បន្ថយភាពក្រីក្រ នោះព្រះរាជាណាចក្រកម្ពុជាត្រូវតែមាន ប្រព័ន្ធតុលាការរដ្ឋប្បវេណីមួយដែលមានរចនាសម្ព័ន្ធ និងនីតិវិធីច្បាស់លាស់ ដើម្បីដោះស្រាយដោយយុត្តិធម៌ និងឆាប់រហ័សនូវរឿងក្តីរដ្ឋប្បវេណីរបស់គ្រប់រូបដែលស្ថិតក្រោមសមត្ថកិច្ចនៃតុលាការកម្ពុជា ។

សូមរំលឹកផងដែលថាចាប់តាំងពីក្រោយ ការដួលរលំនៃរបបខ្មែរក្រហមមកដល់មុនពេលអនុម័តក្រសួង យុត្តិធម៌ដែលជាសេនាធិការនៃរាជរដ្ឋាភិបាលកម្ពុជាហើយ ដែលជាក្រសួងទទួលបន្ទុកអនុវត្តកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពី យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធច្បាប់និងប្រព័ន្ធតុលាការបានស្នើសុំឲ្យមានកិច្ច

[10] មេធាវី អាំង អេងថុង, វិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជា(ដោយសង្ខេប), ទំព័រទី១៩, ២០

[11] សេចក្តីផ្តើមនៃនីតិកម្ពុជា, ទំព័រទី១៩, ២០

សហប្រតិបត្តិការ របស់រាជរដ្ឋាភិបាលជប៉ុនតាមរយៈអង្គការសហប្រតិបត្តិអន្តរជាតិនៃប្រទេសជប៉ុន ហៅកាត់ JICA ដើម្បីបង្កើតក្រមនីតិវិធីរដ្ឋប្បវេណីមួយ ។ គម្រោងសហប្រតិបត្តិការ ដើម្បីរៀបចំក្រមនីតិវិធីរដ្ឋប្បវេណី បាន ចាប់ផ្តើមជាផ្លូវការតាំងពីឆ្នាំ ១៩៩៨ ។ យើងអាចសន្និដ្ឋាននៅត្រង់ចំណុច គម្រោងសហប្រតិបត្តិការ ដើម្បីរៀបចំ ក្រមនីតិវិធីរដ្ឋប្បវេណី ចាប់ផ្តើមជាផ្លូវការតាំងពីឆ្នាំ ១៩៩៨ នេះបានថា ក្រមរដ្ឋប្បវេណី ក៏ត្រូវបានក្រសួងយុត្តិធម៌ ស្នើសុំឲ្យមានកិច្ចសហប្រតិបត្តិការរបស់រាជរដ្ឋាភិបាលជប៉ុនតាមរយៈ អង្គការសហប្រតិបត្តិអន្តរជាតិនៃប្រទេស ជប៉ុន( JICA )ដើម្បីបង្កើតក្រមនីតីរដ្ឋប្បវេណីផងដែល។ ដោយសារកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជារួម ជាមួយការឧត្តមគាំទ្រពី ប្រទេសជប៉ុនជាមិត្តគំនិតផ្តួតផ្តើមក្នុងការបង្កើតឡើងវិញនូវក្រមរដ្ឋប្បវេណីកម្ពុជា ក៏បាន លេចចេញជារូបរាងឡើង ។ ជាលទ្ធផលក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ។ ហើយ វត្តមានសារការីក៏បានលេចឡើងម្តងទៀតនៅក្នុងលិខិតបទដ្ឋានទាំងនោះ ។ នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជា ណាចក្រកម្ពុជាឆ្នាំ២០០៧ នេះយើងឃើញថាពាក្យនីមួយៗដែលក្រមនេះបានសរសេរពីសារការីភាគច្រើននោះគឺ មន្ត្រីសារធារណៈ និងការទាមទារអោយមានមានលិខិតយថាភូតចំពោះការបង្កើតកិច្ចសន្យាឯកជននីមួយៗ ដោយក្នុងគោលគំនិតថានឹងជៀសវាងការធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណី។ មានន័យថា ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មិនបានចែងច្បាស់នូវភាគកិច្ចរបស់សារការីនៅឡើយទេនៅឆ្នាំ២០០៧ នោះដោយអាចយល់ឃើញថា វិជ្ជាជីវៈសារការីមិនអាចដំណើរការបានល្អ។

សូមរំលឹកផងដែលថាចាប់តាំងពីក្រោយការដួលរលំនៃរបបខ្មែរក្រហមមកដល់ មុនពេលអនុម័តក្រមរដ្ឋ ប្បវេណីថ្មី កម្ពុជាយើងមិនទាន់មានច្បាប់សារធាតុគ្រប់គ្រាន់ ដើម្បីយកមកសោះស្រាយរឿងក្តីរដ្ឋប្បវេណីទេ។ អ្វី ដែលជាការកត់សម្គាល់ កម្ពុជា មានត្រឹមតែ ក្រឹត្យ-ច្បាប់លេខ ៣៨ ក្រ.ច ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវ ក្រៅកិច្ចសន្យា ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែលត្រូវបានប្រកាសឲ្យ ប្រើនៅថ្ងៃ ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ ច្បាប់ភូមិបាលដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ និងអមដោយអនុក្រឹត្យ ព្រមទាំងប្រកាសនិងសារាចរណែនាំខ្លះៗផ្សេងទៀតរបស់ក្រសួងយុត្តិធម៌តែ ប៉ុណ្ណោះ។ហើយនៅក្នុងច្បាប់ភូមិបាលឆ្នាំ ១៩៩២ មាត្រា ១៦៦ ក៏បានចែងទាក់ទងសារការីផងដែលថា “ កិច្ច សន្យាដាក់ហ៊ីប៉ូតែកត្រូវធ្វើនៅសារការី បើមិនដូច្នេះទេត្រូវទុកជាមោឃៈជាដាច់ខាត ” ។ ហើយមាត្រា ២០១ នៃ ច្បាប់ភូមិបាលឆ្នាំ ២០០១ បានចែងទាក់ទងនិងសារការផងដែលថា កិច្ចសន្យាហ៊ីប៉ូតែកត្រូវរៀបចំតាមរូបមន្ត យថាភូត ចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច ឬ អ្នកច្បាប់ណាម្នាក់ដែលមាននីតិសម្បទាក្នុងរឿងនេះ ។ កិច្ចសន្យា

ត្រូវចុះបញ្ជីនៅអង្គភាពសុរិយោដី ។ អាជ្ញាធរមានសមត្ថកិច្ចក្នុងការចាត់ចែងការតាក់តែងកិច្ចសន្យាហ៊ីប៉ូតែក និង ទម្រង់នៃការចុះបញ្ជីនឹងកំណត់ដោយអនុក្រឹត្យ ។

ខ្លឹមសារទាំងពីរនេះសបញ្ជាក់ថា សារការីត្រូវបានផ្តល់តួនាទីបង្កើតកិច្ចសន្យាហ៊ីប៉ូតែក ដែលជាមុខងារត្រូវតែធ្វើចេញពីសារការីផ្ទាល់ និងការរៀបចំរូបមន្តអនុវត្តយថាភូតនៅនឹងមុនអាជ្ញាធរមានសមត្ថកិច្ច ដូចជាមន្ត្រីសុរិយោដីជាដើម ។ បើប្រៀបធៀបទៅនិងក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ យើងឃើញថាសារការីត្រូវបានផ្តល់មុខងារបន្ថែមទៀតនោះគឺ សិទ្ធិរៀបចំរូបមន្តអនុវត្តយថាភូត ។

សូមបញ្ជាក់ថា ទោះបីជា ក្រមរដ្ឋប្បវេណីត្រូវបានប្រកាសឲ្យប្រើក៏ដោយ ក៏បញ្ញត្តិនៃក្រមនេះ មិនទាន់ត្រូវបានអនុវត្តនៅឡើយទេ ដោយរងចាំនូវច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលជាច្បាប់មួយដើម្បីធ្វើការសម្របសម្រួលជាមួយបទប្បញ្ញត្តិច្បាប់ និង បទដ្ឋានគតិយុត្តធរមាននានា ឲ្យមានភាពស៊ីសង្វាក់នឹងគ្នាក្នុងការអនុវត្ត ។ គណៈកម្មការទទួលបន្ទុកកិច្ចការផ្នែកច្បាប់រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីដោយមាន ការឧបត្ថម្ភគាំទ្រពីប្រទេសជប៉ុនជាមិត្តក៏បានបញ្ចប់នូវការតាក់តែងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ ។ ច្បាប់នេះបានចែងយ៉ាងច្បាស់ផងដែរនៅក្នុងមាត្រា ៩ ដែលបានបកស្រាយពីលិខិយថាភូតទាំងឡាយណាដែលសារការីមានសិទ្ធិ និង គ្មានសិទ្ធិធ្វើ ។ មិនតែប៉ុណ្ណោះ ខ្លឹមសារដែលមានចែងនៅក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីនេះបានចែងយ៉ាងច្បាស់ពីតួនាទីរបស់សារការីនៅក្នុងការបង្កើតលិខិតយថាភូតយ៉ាងលម្អិតបំផុត ។ ដោយមានតម្រូវការជាចាំបាច់ក្នុងការអនុវត្តន៍មុខងារសារការី រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតស្ថាប័នសារការីមួយ តាមអនុក្រឹត្យលេខ ៥០៥ អនក្រ.តត ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០១ ។ លោក ប៉ែន សុន សម័យ ត្រូវបានតែងតាំងដោយអនុក្រឹត្យនេះក្នុងភាពចាំបាច់ និងជាបន្ទាន់នូវមុខងារបន្ថែមជាមេធាវីសារការី នៃព្រះរាជាណាចក្រកម្ពុជា ការតែងតាំងនេះត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល ជាមន្ត្រីសាធារណៈទទួលនូវមុខងារសាធារណៈ ឲ្យប្រកបវិជ្ជាជីវៈសេរីជាសារការី តម្រូវឲ្យមានទីតាំងត្រឹមត្រូវ ដើម្បីធ្វើជាមន្ទីសារការី ដែលត្រូវមានទ្រព្យធន និង មូលនិធិគ្រប់គ្រាន់សម្រាប់ធានា តំកល់បំណុលរដ្ឋ និងសងការខូចខាតដល់អតិថិជន ។ ដោយមុខងារសារការី ជាមុខងារមួយដែលស្ថិតក្នុងវិស័យច្បាប់ មុខងារនេះក៏ត្រូវបានចាប់អារម្មណ៍យ៉ាងខ្លាំង ក្នុងពពួកមេធាវី រហូតនៅថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០២ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានទទួលញត្តិរបស់សមាជិក សមាជិកាមេធាវីរបស់ខ្លួន ដោយមានចុះហត្ថលេខាចំនួន១០៥នាក់ ដើម្បីស្នើដល់ក្រុមប្រឹក្សាគណៈមេធាវីបើកមហាសន្និបាតវិសាមញ្ញមួយ

ពិសេស ស្តីអំពីមុខនាទីមេធាវីសារការីតាមអនុក្រឹត្យ ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែម ជាសារការីដល់មេធាវីនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា លេខ ៥០៥ អនក្រ.តត ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០១ ។

មហាសន្និបាតវិសាមញ្ញនេះ បានប្រព្រឹត្តទៅនៅសណ្ឋាគារអាំងទែរកង់ទីណង់តាល់ ។ ក្រោយមកទៀត លោកសារការី លី តៃសេង និងលោកសារការី តាន់ហ៊ាន ដារ៉ែណ្ណ បានតែងតាំង នាឆ្នាំ២០០៨ ។រាជរដ្ឋាភិបាលក៏បានចេញអនុក្រឹត្យលេខ ១៤៨អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ ដែលជាអនុក្រឹត្យដំបូងបង្អស់ប្រកាសទទួលស្គាល់មន្ទីសារការីដែលមានឈ្មោះថា " មន្ទីសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា " ។ លើសពីនេះទៅទៀត មានបញ្ញត្តិមួយចំនួនទៀតទាក់ទង នឹងការតែងតាំង មន្ត្រីទទួលបន្ទុកសារការី ដូចជាប្រកាសរបស់ក្រសួងយុត្តិធម៌ លេខ ៤៧ កយ.ប្រក/១២ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១២ ។ ប្រកាសមួយទៀតទាក់ទងនឹងការកំណត់ មន្ត្រីទទួលបន្ទុកសារការីរបស់ក្រសួងយុត្តិធម៌ដដែល លេខ ៧២ កយ.ប្រក/១២ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ ដដែល ហើយធ្វើឲ្យប្រកាសលេខ ៤៧ ត្រូវបាននិរករណ៍ដោយប្រកាសនេះ ។ ហើយការវិវត្តចុងក្រោយ នៃវិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជាយើងនេះ គឺការបង្កើតសាលាភូមិន្ទ សារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។[12]

មាត្រា១នៃអនុក្រឹត្យនេះបានចែងថា ត្រូវបានទទួលស្គាល់ការបង្កើតមន្ទីរសារការីដែលមានឈ្មោះថា មន្ទីរសារការី អេចប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា ( HBS Notary Public of the kingdom of Cambodia ) សរសេរកាត់ជាភាសាខ្មែរ "**អ.ប.អ.ស**" សរសេរកាត់ជាភាសាខ្មែរ ជាភាសាអង់គ្លេស H.B.S.N ។

ដោយអនុក្រឹត្យលេខ១១៧ អនក្រ.បកចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ និងចាប់ផ្តើមបណ្តុះបណ្តាលសិស្សសារការីជំនាន់ទី១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈសារការី ដែលសិស្សសារការីទាំង១៥នាក់ កំពុងបណ្តុះបណ្តាលសព្វថ្ងៃនេះត្រូវបាន ជ្រើសរើសដោយការប្រលងប្រជែង ដើម្បីឲ្យចូលបំរើការងារក្នុងវិជ្ជាជីវៈសារការីនេះ ដែលបានតែងតាំងដោយប្រកាសលេខ ១៧ ប្រក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ។

[12] មាត្រា១នៃអនុក្រឹត្យនេះបានចែងថា ត្រូវបានទទួលស្គាល់ការបង្កើតមន្ទីសារការីដែលមានឈ្មោះថា មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា ( HBS Notary Public of the kingdom of Cambodia ) សរសេរកាត់ជាភាសាខ្មែរ"អ.ប.អ.ស" សរសេរកាត់ជាភាសាខ្មែរ ជាភាសាអង់គ្លេស H.B.S.N"។

# ជំពូកទី២

# បែបបទនៃការប្រកបវិជ្ជាជីវៈ និងការបង្កើតការិយាល័យមេធាវី

## ផ្នែកទី១ ៖ បែបបទនៃការប្រកបវិជ្ជាជីវៈមេធាវី

ដើម្បីអាចស្នើរសុំចូលប្រកបវិជ្ជាជីវៈជាមេធាវី បានលុះត្រាតែបេក្ខជនបានបំពេញនូវលក្ខខ័ណ្ឌទាំងឡាយ ដែលបានកំណត់នៅក្នុងមាត្រាទាំងពី ៣១ (ដែលគេស្គាល់ថាចូលប្រកបវិជ្ជាជីវៈតាមរយៈការប្រលងប្រជែង) និង ៣២ (ដែលគេនិយមហៅថាការចូលប្រកបវិជ្ជាជីវៈមេធាវីតាមរយៈបទពិសោធន៍ច្បាប់) នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ បន្ទាប់ពីត្រូវបានទទួលឲ្យប្រកបវិជ្ជាជីវៈ មេធាវីត្រូវធ្វើការចុះឈ្មោះក្នុងបញ្ជីកម្មសិក្សា និងបញ្ជីគណៈមេធាវីហើយបានក្លាយទៅជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទទួលបានសិទ្ធិប្រកបវិជ្ជាជីវៈជាឯកត្តជន ជាសមូហភាព ជាកិច្ចសហការជាមួយមេធាវី ដទៃទៀត ឬ ធ្វើកិច្ចសហប្រតិបត្តិការជាមួយវិជ្ជាជីវៈសេរីដទៃទៀត។

### ១.១. តាមរយៈការប្រឡងប្រជែង

បេក្ខជនទាំងឡាយ ដែលចង់ទទួលបាន មុខងារជាមេធាវីតាមរយៈការប្រឡងជ្រើសរើសឲ្យចូលរៀនវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ត្រូវបំពេញលក្ខខ័ណ្ឌសព្វគ្រប់ដែលមានចែងក្នុងមាត្រា៣១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។ លក្ខខ័ណ្ឌទាំងឡាយ ដែលកំណត់នៅក្នុងមាត្រា ៣១ មានដូចតទៅ ៖

- ត្រូវមានសញ្ជាតិជាខ្មែរ : លក្ខខ័ណ្ឌសញ្ជាតិនេះ ច្បាប់មិនបានកំណត់ថា បេក្ខជន ដែលបានចង់ចូលប្រកបវិជ្ជាជីវៈមេធាវី ត្រូវតែមានសញ្ជាតិជាខ្មែរពីកំណើតទេ គឺគេគ្រាន់តែតម្រូវឲ្យមានសញ្ជាតិជាខ្មែរទោះជាការទទួលសញ្ជាតិដោយសញ្ជាតូបនីយកម្ម ក៏ដោយ ។ តាមច្បាប់ស្តីពីសញ្ជាតិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ ១៩៩៦ បានចែងកំណត់នៅក្នុងមាត្រា ៤ មាត្រា ៥ និងមាត្រា ៧ ពីការទទួលបានសញ្ជាតិជាខ្មែរតាមរយៈ ៤ យ៉ាង ៖ លោហិត, ទីកន្លែងកំណើត, អាពាហ៍ពិពាហ៍, សញ្ជាតូបនីយកម្ម ។

- ត្រូវមានបរិញ្ញាប័ត្រច្បាប់ ឬសញ្ញាប័ត្រច្បាប់ ដែលបានប្រកាសថាមានតម្លៃសមមូល ។ នៅក្នុងន័យនៃមាត្រាច្បាប់នេះ យើងឃើញថា សញ្ញាប័ត្រមួយចំនួន ដែលចេញមកពីបរទេសត្រូវការវាយតំលៃពីស្ថាប័នមានសមត្ថកិច្ច ដើម្បីកំណត់ថា តើវាមានតំលៃសមមូល និងបរិញ្ញាប័ត្រច្បាប់ ឬទេ ? ការវាយតម្លៃលើសញ្ញាប័ត្រគឺក្រសួងអប់រំ យុវជន និងកីឡា ។

- ត្រូវមានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ។ វិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវីនេះ ត្រូវចេញដោយមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

- មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈឹម ឬបទឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ ឬ ផ្តន្ទាទោសជាបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ ។ មិនត្រូវធនក្ស័យផ្ទាល់ខ្លួន ដែលប្រកាសដោយតុលាការ ។

លក្ខខ័ណ្ឌ ដែលកំណត់នៅក្នុងមាត្រា ៣១ នេះតំរូវឲ្យបេក្ខជនឆ្លងកាត់វគ្គអប់រំនៅមជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹតការវិជ្ជាជីវៈមេធាវី ដើម្បីទទួលបានវិញ្ញាប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ។ បេក្ខជនត្រូវឆ្លងកាត់ការប្រលងប្រជែងចូលរៀននៅមជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹតការវិជ្ជាជីវៈមេធាវី ហើយបើប្រលងជាប់គឺត្រូវរៀននៅមជ្ឈមណ្ឌលនេះរយៈពេលមួយឆ្នាំ ដែលមានការបណ្តុះបណ្តាលលើទ្រឹស្តី និងការអនុវត្តជាក់ស្តែង។

ដើម្បីសម្រេចឲ្យចូលប្រកបវិជ្ជាជីវៈមេធាវី បេក្ខជនទាំងឡាយ ដែលបានបំពេញលក្ខខ័ណសព្វគ្រប់ដូចដែលបានចែងកំណត់ក្នុងមាត្រា ៣១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីខាងលើ ត្រូវបំពេញបែបបទ និងដាក់ពាក្យប្រកបវិជ្ជាជីវៈមេធាវីទៅគណៈមេធាវីដើម្បីក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសំរេច ។ បែបបទ និង ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីមានលក់ជូននៅការិយាល័យរដ្ឋបាលរបស់គណៈមេធាវី ។

សំណុំបែបបទរបស់បេក្ខជន ដែលបំពេញតាមលក្ខខ័ណ្ឌនៃមាត្រា ៣១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី គឺដំបូងគណៈមេធាវីបញ្ជូនទៅសុំការពិនិត្យ និងផ្តល់ជាយោបល់ដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ បន្ទាប់មកគណៈមេធាវីដាក់ចូលជារបៀបវារៈ កោះប្រជុំក្រុមប្រឹក្សាគណៈមេធាវី ដើម្បីពិនិត្យ និងសំរេច ។

### ១.២. តាមរយៈបទពិសោធន៍ច្បាប់

ចំពោះបេក្ខជន ដែលចង់ទទួលបានមុខងារមេធាវី តាមរយៈបទពិសោធន៍ផ្នែកច្បាប់ ត្រូវបំពេញលក្ខខ័ណ្ឌសព្វគ្រប់ដែលមានបញ្ញត្តិក្នុងមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដើម្បីផ្តល់លទ្ធភាពដល់បេក្ខជន ដែលមិនបានឆ្លងកាត់វគ្គអប់រំ បណ្តុះបណ្តាលនៅមជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹតការវិជ្ជាជីវៈមេធាវី ។ លក្ខខ័ណ្ឌនៅក្នុងមាត្រា ៣២ មានដូចតទៅៈ

មិនចាំបាច់មានវិញ្ញាណបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងមិនចាំបាច់មានបរិញ្ញាប័ត្រច្បាប់ ៖

- ចៅក្រម ដែលបានបំរើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ៥ ឆ្នាំ និងអតីតចៅក្រម ដែលមានសញ្ញាប័ត្រមធ្យមសិក្សាច្បាប់ហើយដែលបានបំរើក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ២ ឆ្នាំ ។

មិនចាំបាច់មានវិញ្ញាណបនប័ត្រខាងវិជ្ជាជីវៈមេធាវី ៖

- អ្នកមានបរិញ្ញាប័ត្រច្បាប់ ហើយដែលបានបម្រើការងារក្នុងវិស័យច្បាប់ ឫតុលាការលើសពី ២ ឆ្នាំ ។
- មេធាវីដែលមានសញ្ជាតិដើមជាខ្មែរ ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេស ក្រៅ ។ សូមបញ្ជាក់ នៅក្នុងវាក្យខ័ណ្ឌនេះមានពាក្យមួយសរសេរថា "សញ្ជាតិដើមជាខ្មែរ" ដែលជាសញ្ញាមួយបញ្ជាក់ថា៖ ការអាចទទួលឲ្យចូលប្រកបវិជ្ជាជីវៈមេធាវីនៅព្រះរាជាណាចក្រកម្ពុជាលុះត្រាតែជនជាតិខ្មែរ ដែលសិក្សារៀនសូត្រនៅប្រទេសក្រៅ ។ ចំណែកឯជនបរទេស ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេសក្រៅហើយក្រោយ មកគាត់បានទទួលជាសញ្ជាតិខ្មែរ គាត់មិនអាចទទួលបានអនុញ្ញាតឲ្យចូលជាសមាជិកគណៈមេធាវីតាមលក្ខខណ្ឌខាងលើនេះទេ ។
- អ្នកមានសញ្ញាប័ត្របណ្ឌិតច្បាប់ ។

ដើម្បីសម្រេចឲ្យចូលប្រកបវិជ្ជាជីវៈមេធាវី បេក្ខជនទាំងឡាយ ដែលបានបំពេញលក្ខខ័ណសព្វគ្រប់ដូចដែលបានចែងកំណត់ក្នុងមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។ បេក្ខជនត្រូវបានឆ្លងកាត់ច្រើនដំណាក់កាល និងមានភាពខុសគ្នាពីមាត្រា៣១ ដោយសារបេក្ខជនដែលបានដាក់ចូលមកតាមវិធីនេះ ពុំតម្រូវឲ្យឆ្លងការប្រលងវិញ្ញាសាសរសេរនោះទេ ប៉ុន្តែបេក្ខជនត្រូវឆ្លងកាត់ដំណាក់កាលដំបូងគឺ ត្រូវឆ្លងកាត់ការអង្កេត និងធ្វើរបាយការណ៍ដោយក្រុមអធិការកិច្ចរបស់គណៈមេធាវី និង ការសំភាសន៍ ដោយគណៈកម្មការសំភាសន៍មួយដែលមានសមាសភាពប្រធានគណៈមេធាវី និងសមាជិកក្រុមប្រឹក្សាគណៈមេធាវី ២ រូប ។ បន្ទាប់មកសំណុំបែបបទទាំងអស់ត្រូវបានបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីផ្តល់ជាយោបល់ ។ ក្រោយពីទទួលបាននូវការផ្តល់ជាយោបល់របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍រួចមក គណៈមេធាវីរៀបចំរបៀបវារៈកោះប្រជុំក្រុមប្រឹក្សាគណៈមេធាវី ។ ដើម្បីអាចដំណើរការនីតិវិធីអង្កេត និងសំភាសន៍បេក្ខជន ដែលបានដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈតាមលក្ខ័ណ្ឌនៃមាត្រា ៣២ បានក្រុមប្រឹក្សាគណៈមេធាវី បានសំរេចនៅក្នុងសម័យប្រជុំថ្ងៃទី ១៣ ធ្នូ ឆ្នាំ ២០០២ តំរូវអោយបេក្ខជនម្នាក់ៗបង់ថ្លៃភ្ជាប់ជាមួយពាក្យសុំចំនួន ២០០ ដុល្លារអាមេរិក ។

ក្រុមប្រឹក្សាគណៈមេធាវី ជាអ្នកសំរេចយល់ព្រមអោយចូលប្រកបវិជ្ជាជីវៈ ក្រោយពីបានត្រួតពិនិត្យ លើការបំពេញលក្ខខ័ណ្ឌសព្វគ្រប់ ដែលមានកំណត់នៅខាងលើ និងក្រោយពីមានយោបល់របស់អគ្គព្រះរាជអាជ្ញា

អមសាលាឧទ្ធរណ៍ ។ សេចក្តីសំរេចត្រូវអោយដំណឹងដល់សាមីខ្លួន និងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

ក្រុមប្រឹក្សាគណៈមេធាវីមិនអាចសំរេចមិនយល់ព្រមដោយគ្មាន ការកោះអញ្ជើញសាមីខ្លួនអោយចូលមកបញ្ចេញយោបល់ជាមុនយ៉ាងតិច ១០ ថ្ងៃបានឡើយ ។ ការកោះអញ្ជើញនេះ ត្រូវធ្វើតាមលិខិតអនុសិដ្ឋ ឬ លិខិតប្រគល់ផ្ទាល់ដៃ ដោយមានសេចក្តីបញ្ជាក់ថាបានទទួល ។[13]

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី អាចត្រូវបានប្តឹងតវ៉ាក្នុងរយៈពេល ២ ខែ ចាប់ពីថ្ងៃទទួលដំណឹង ។ ពាក្យបណ្តឹងត្រូវដាក់នៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ឬ តាមលិខិតអនុសិដ្ឋមានចុះសេចក្តីថាបានទទួល ។[14]

## ១.៣. ការចុះឈ្មោះក្នុងបញ្ជីកម្មសិក្សា និងបញ្ជីគណៈមេធាវី

មេធាវី ដែលត្រូវបានទទួលអោយប្រកបវិជ្ជាជីវៈ ត្រូវធ្វើសច្ចាប្រណិធានជាមុននៅចំពោះមុខសាលាឧទ្ធរណ៍ ដោយមានវត្តមានប្រធានគណៈមេធាវី ហើយដែលមានសេចក្តីដូចតទៅៈ“ ខ្ញុំសូមសច្ចាប្រណិធានថានឹងអនុវត្តវិជ្ជាជីវៈរបស់ខ្ញុំ ដោយសេចក្តីថ្លៃថ្នូរ ដោយសតិសម្បជញ្ញៈ ដោយសេចក្តីទៀតត្រង់ ដោយមនុស្សធម៌ ដោយស្មារតីឯករាជ្យ និងដោយគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា ” ។

មេធាវី ដែលទើបនឹងបានអនុញ្ញាត និងធ្វើសច្ចាប្រណិធាន ត្រូវធ្វើកម្មសិក្សារយៈពេល ១ ឆ្នាំ ហើយអាចពន្យាពេលបានមួយឆ្នាំទៀត តាមការសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ។

ក្រុមប្រឹក្សាគណៈមេធាវីអាចសំរេចអនុញ្ញាតឲ្យមេធាវីមួយចំនួនរួចផុតពីកម្មសិក្សាផងដែរ ដោយផ្អែកលើបទពិសោធន៍របស់គេ ។

សកម្មភាពភាពកម្មសិក្សាមានជាអាទិ៍ ដូចតទៅៈ

- ត្រូវទទួលការបំពាក់បំប៉នជាបន្ថែម ដែលរៀបចំឡើងដោយគណៈមេធាវី
- ការចូលសិក្សាបន្ថែមនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹតការវិជ្ជាជីវៈមេធាវី ,
- ការចូលរួមបំរើការងារអោយពិតប្រាកដជាសហការីក្នុងការិយាល័យមេធាវីណាមួយ
- ការទៅធ្វើកម្មសិក្សានៅការិយាល័យមេធាវីបរទេសណាមួយ។

[13] យោងតាមមាត្រា ៣៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

[14] យោងតាមមាត្រា ២៥ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

បេក្ខជន ដែលត្រូវបានសំរេចអនុញ្ញាតឲ្យចូលប្រកបវិជ្ជាជីវៈមេធាវី ដោយផ្អែកតាមលក្ខខ័ណ្ឌ នៃមាត្រា ៣១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បេក្ខជនអាចស្វែងរក និងស្នើសុំគ្រូកម្មសិក្សា ដើម្បីដាក់ពាក្យសុំកម្មសិក្សាតាមការកំណត់របស់ច្បាប់ ដោយមិនតំរូវអោយបង់ថ្លៃអីទៀតទេ។ ផ្ទុយទៅវិញបេក្ខជន ដែលត្រូវបានសំរេចអនុញ្ញាតឲ្យចូលប្រកបវិជ្ជាជីវៈមេធាវីដោយផ្អែកតាមលក្ខខ័ណ្ឌ នៃមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បេក្ខជនត្រូវបង់ប្រាក់ចំនួន ២.០០០ ដុល្លារអាមេរិកចូលក្នុងបេឡាគណៈមេធាវី ដើម្បីយកមកប្រើប្រាស់សំរាប់ការបណ្តុះបណ្តាលបន្ថែមក្នុងរយៈពេល នៃការធ្វើកម្មសិក្សា។[15]

មេធាវីកម្មសិក្សា ដែលត្រូវបានទទួលអនុញ្ញាតអោយចូលប្រកបវិជ្ជាជីវៈមេធាវីតាមលក្ខខ័ណ្ឌមាត្រា ៣២ ត្រូវមានកាតព្វកិច្ចចូលរៀនក្រមសីលធម៌មេធាវី ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និង
បច្ចេកទេសការពារក្តី នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលរយៈពេល៨០ម៉ោង ហើយថែមទាំងមានកាតព្វកិច្ចការពារក្តីជូនជនក្រីក្រ ដែលចាត់តាំងឡើងដោយគណៈមេធាវីផងដែរ។

មេធាវីកម្មសិក្សា ដែលត្រូវបានទទួលអនុញ្ញាតអោយចូលប្រកបវិជ្ជាជីវៈមេធាវីតាមលក្ខខ័ណ្ឌមាត្រា ៣២ ត្រូវមានកាតព្វកិច្ចចូលរៀនក្រមសីលធម៌មេធាវី ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងបច្ចេកទេសការពារក្តី នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលរយៈពេល៨០ម៉ោង ហើយថែមទាំងមានកាតព្វកិច្ចការពារក្តីជូនជនក្រីក្រ ដែលចាត់តាំងឡើងដោយគណៈមេធាវីផងដែរ។

ក្រោយពីក្រុមប្រឹក្សាគណៈមេធាវី សំរេចចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី មេធាវីម្នាក់ៗមានសិទ្ធិប្រកបវិជ្ជាជីវៈជាឯកត្តជន ជាសមូហភាព ជាកិច្ចសហការជាមួយមេធាវី ឬ ធ្វើកិច្ចសហប្រតិបត្តិការជាមួយវិជ្ជាជីវៈដ៏ទៃទៀត។ ដូច្នេះ ខ្ញុំសូមលើកយកមេធាវីប្រកបវិជ្ជាជីវៈជាឯកត្តជនយកមកបង្ហាញ ដើម្បីឲ្យងាយយល់កាន់តែច្បាស់។ មេធាវីអាចប្រកបវិជ្ជាជីវៈជាឯកត្តជនបាន គឺមានន័យថា មេធាវីម្នាក់ៗអាចធ្វើការប្រកបវិជ្ជាជីវៈតែម្នាក់ៗឯងបាន ដោយមានទីលំនៅវិជ្ជាជីវៈច្បាស់លាស់នៅព្រះរាជាណាចក្រកម្ពុជា។

មេធាវីម្នាក់ៗមានសិទ្ធិប្រើប្រាស់ត្រាមេធាវីមួយ និងត្រាឈ្មោះ។ ក្រុមប្រឹក្សាគណៈមេធាវីបានសម្រេចថាត្រូវធ្វើត្រាមេធាវីតាមទម្រង់តែមួយដូចគ្នា ហើយផ្ញើរឲ្យគ្រប់ស្ថាប័នស្គាល់ ជាពិសេសក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌។ មាត្រានេះមានទម្រង់តែមួយរាងមូលដែលអង្កត់ផ្ចិតប្រវែង ៣៨មម។ នៅរង្វង់មូលខាងក្រៅ ខាងលើមានដាក់អក្សរថា “ព្រះរាជាណាចក្រកម្ពុជា” និងនៅខាងក្រោមមានដាក់ភាសាអក្សរអង់គ្លេសថា “KINGDOM

[15] សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវីនាសម័យប្រជុំថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៦

OF CAMBODIA”. នៅរង្វង់ខាងក្នុងខាងលើដាក់ថា ”មេធាវី“ នៅខាងក្រោមបន្ទាត់ដាក់ថា “AVOCAT” ហើយនៅក្រោមគេដាក់ថា ”ATTORNEY-AT-LAW”។[16]

## ផ្នែកទី២ ៖ បែបបទនៃការបង្កើតការិយាល័យមេធាវី

ដើម្បីស្នើសុំបង្កើតការិយាល័យមេធាវីបាន បេក្ខជនត្រូវមានលក្ខណៈសម្បត្តិជាមេធាវី ហើយអាចបើកជាការិយាល័យដើម( ទីលំនៅវិជ្ជាជីវៈដើម ) និងការិយាល័យសាខា។

### ២.១. លក្ខណៈសម្បត្តិជាមេធាវី

បុគ្គល ដែលទទួលបានមុខងារជាមេធាវី ទើបមានសិទ្ធិក្នុងការស្នើសុំបង្កើតការិយាល័យមេធាវី ដើម្បីទទួលបានមុខងារជាមេធាវី បានលុះត្រាតែបេក្ខជនបានបំពេញនូវលក្ខខ័ណ្ឌទាំងឡាយ ដែលបានកំណត់នៅក្នុងមាត្រាទាំងពី ៣១(ដែលគេស្គាល់ថាចូលប្រកបវិជ្ជាជីវៈតាមរយៈការប្រលងប្រជែង) និង ៣២ (ដែលគេនិយមហៅថាការចូលប្រកបវិជ្ជាជីវៈមេធាវីតាមរយៈបទពិសោធន៍ច្បាប់) នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

បន្ទាប់ពីត្រូវបានទទួលឲ្យប្រកបវិជ្ជាជីវៈ មេធាវីត្រូវធ្វើការចុះឈ្មោះក្នុងបញ្ជីកម្មសិក្សា និងបញ្ជីគណៈមេធាវីហើយបានក្លាយទៅជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទទួលបានសិទ្ធិប្រកបវិជ្ជាជីវៈជាឯកត្តជន ជាសមូហភាព ជាកិច្ចសហការជាមួយមេធាវី ដទៃទៀត ឬ ធ្វើកិច្ចសហប្រតិបត្តិការជាមួយវិជ្ជាជីវៈសេរីដទៃទៀត និងអាចបើក ការិយាល័យដើម និងការិយាល័យសាខា។ សូមបញ្ជាក់ថា ចំពោះលក្ខណៈសម្បត្តិជាមេធាវីនេះ យើងបានរៀបរាប់រួចហើយដូច្នេះប់ចង់យល់ច្បាស់សូមមើលនៅក្នុង **ជំពូកទី២ នៃផ្នែកទី១ (បែបបទនៃការប្រកបវិជ្ជាជីវៈមេធាវី**)ខាងលើ។

### ២.២. បែបបទនៃបើកការិយាល័យមេធាវី

ការិយាល័យមេធាវី ក្រុមហ៊ុនមេធាវី ឬ ក្រុមមេធាវី គឺជាទីកន្លែងអាជីវកម្មចម្បងរបស់មេធាវីក្នុង ការប្រកបវិជ្ជាជីវៈរបស់ខ្លួន។ ការិយាល័យមេធាវីមាន២ប្រភេទ គឺ ការិល័យដើម( ទីលំនៅវិជ្ជាជីវៈដើម ) និងការិយាល័យសាខា។ សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកបវិជ្ជាជីវៈ ត្រូវមានការិយាល័យដើម ឬ ជាសមាជិកនៃការិយាល័យមេធាវីណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងអាចបើកការិយាល័យជាឯកត្តជនជាក្រុម ឬ ជាទំរង់ក្រុមហ៊ុន។

---

[16] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវីនាសម័យប្រជុំថ្ងៃទី១៥ មីនា ឆ្នាំ១៩៩៩ និងថ្ងៃទី ០១ ខែមេសា ឆ្នាំ១៩៩៦។

### ២.២.១. ការិយាល័យដើម(ជាឯកត្តជន)

ការបើកការិយាល័យដើមនៅក្នុងប្រទេសកម្ពុជាដោយមេធាវីតែម្នាក់ឯងត្រូវតែជូនដំណឹងទៅគណៈមេធាវី ។ ការិយាល័យដើមរបស់មេធាវីត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- នាមករណ៍ ស្លាកសញ្ញា អាសយដ្ឋានការិយាល័យ និងលេខទូរស័ព្ទ
- ទូរសារ ទូរពុម្ព គេហទំព័ររបស់ការិយាល័យនិងរូបភាពរបស់ការិយាល័យ (ប្រសិនមាន)
- បញ្ជីឈ្មោះមេធាវីដែលបានចូលរួមក្នុងការិយាល័យនេះ (ប្រសិនមាន)
- គំនូសបង្ហាញទីតាំងការិយាល័យ និងគំនូសបង្ហាញប្លង់ក្នុងការិយាល័យ
- រូបសញ្ញា (Logo) ប្រសិនបើមាន ត្រូវមានការអនុញ្ញាតពីគណៈមេធាវី
- ឯកសារពាក់ពន្ធ័ផ្សេងទៀត តាមតម្រូវការរបស់គណៈមេធាវី។

ការតាំងការិយាល័យប្រកបវិជ្ជាជីវៈត្រូវធ្វើនៅដាច់ដោយឡែកពី ការិយាល័យពាណិជ្ជកម្ម រ៉ាប់រងឲ្យបាននូវការគោរពគោលការណ៍នៃសេចក្តីថ្លៃថ្នូរ និងឯករាជ្យភាពព្រមទាំងធានានូវការសម្ងាត់នៃវិជ្ជាជីវៈ។

សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកបវិជ្ជាជីវៈ នៅតាមអង្គភាព ឬ ស្ថាប័នមួយដែលគ្មានការិយាល័យដើម ឬ ជាសមាជិកនៃការិយាល័យមេធាវីណាមួយត្រូវផ្តល់អាសយដ្ឋានជាក់លាក់សម្រាប់ទំនាក់ទំនងជាមួយគណៈមេធាវី។[17]

### ២.២.២. ការិយាល័យសាខា

ការិយាល័យសាខា គឺជាការិយាល័យមួយដោយឡែកពីការិយាល័យដើម និងមានទីតាំងស្ថិតនៅក្រៅដែនដី រដ្ឋបាលរាជធានី-ខេត្តដែលការិយាល័យដើមតាំងនៅ។ មេធាវីដែលចង់បើកការិយាល័យសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១០ ខាងលើ និងយ៉ាងតិចត្រូវមានមេធាវីពេញសិទ្ធិម្នាក់ជាអ្នកទទួលខុសត្រូវ។

ការបើកការិយាល័យសាខាត្រូវមានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាគណៈមេធាវី។ ការបើកការិយាល័យសាខាធ្វើបានតែមួយគត់ នៅតាមរដ្ឋបាលដែនដីនៃរាជធានី និងខេត្តនីមួយៗ។

[17] មាត្រា១០នៃច្បាប់ស្តីពីក្រមសីលធម៌មេធាវី

មេធាវីដែលមានបំណងបើកការិយាល័យសាខានៅបរទេស ត្រូវជូនដំណឹងដល់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងគោរពតាមលក្ខខណ្ឌតម្រូវនានារបស់គណៈមេធាវីបរទេសនោះ។ ដើម្បីធានាការសម្ងាត់និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈមេធាវីគណៈមេធាវីអាចត្រួតពិនិត្យការិយាល័យដើម និងការិយាល័យសាខាបាននៅរាល់ម៉ោងធ្វើការ ដោយគ្រាន់តែជូនដំណឹងជាមុនក្នុងរយៈពេល៧ថ្ងៃនៃថ្ងៃធ្វើការយ៉ាងតិច ទៅការិយាល័យដែលត្រូវត្រួតពិនិត្យនោះ។[18]

[18] មាត្រា១១ នៃច្បាប់ស្តីពីក្រមសីលធម៌មេធាវី

# ជំពូកទី៣

# បែបបទនៃការប្រកបវិជ្ជាជីវៈសារការី និងការបង្កើតមន្ទីរសារការី

## ផ្នែកទី១ ៖ បែបបទនៃការប្រកបវិជ្ជាជីវៈសារការី

នៅក្នុងពេលបច្ចុប្បន្ន ដើម្បីទទួលបានមុនងារជាសារការី បេក្ខជនអាចជ្រើសរើសមធ្យោបាយពីរគឺ តាមរយៈការប្រឡងប្រជែង ដើម្បីទទួលបានការបណ្តុះបណ្តាលពីសាលាភូមិន្ទវិជ្ជាជីវៈសារការី និង តាមរយៈការតែងតាំងជាសារការី ។

### ១.១. តាមរយៈការប្រឡងប្រជែង

ដើម្បីក្លាយជាបេក្ខភាពដែលអាចចូលប្រលងប្រជែងបាន បេក្ខជនទាំងអស់ត្រូវ បំពេញលក្ខខ័ណ្ឌសព្វគ្រប់ដែលមានបញ្ញត្តិក្នុងមាត្រា៦ នៃអនុក្រឹត្យស្តីពីការបង្កើតសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។ បេក្ខជនដែលប្រលងប្រជែងចូល សាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិជាខ្មែរ ។ ចំពោះបេក្ខជនជានិស្សិត ត្រូវមានអាយុមិនលើសពី៣៥ឆ្នាំ រីឯបេក្ខជនជាមន្ត្រីរាជការ ត្រូវមានអាយុមិនលើសពី៤០ឆ្នាំ គិតមកត្រឹមថ្ងៃប្រឡង
- ត្រូវមានសញ្ញាប័ត្របរិញ្ញាបត្រនីតិសាស្ត្រ ឡើងទៅ
- ត្រូវមានលិខិតថ្កោលទោសបញ្ជាក់ថា មិនធ្លាប់ជាប់ទោសពីបទមជ្ឈិម ឬ បទឧក្រិដ្ឋ
- ត្រូវមានកាយសម្បទាគ្រប់គ្រាន់ ។

បេក្ខជនដែលប្រឡងប្រជែងជាប់ជាស្ថាពរនៅ សាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាករត្រូវតែងតាំងជាសិស្សសាការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងរយៈពេលនៃការបណ្តុះបណ្តាល សិស្សសាការី ត្រូវទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ តាមការកំណត់របស់រដ្ឋ ។ [19]

សិស្សសារការីត្រូវទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងសម្រាប់សារការី ឲ្យបានពេញលេញតាមកម្មវិធីសិក្សា ត្រូវកំណត់ដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

[19] មាត្រា៧ នៃអនុក្រឹត្យស្តីពីការបង្កើតសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

សិស្សសារការីដែលបានបញ្ចប់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈដំបូងសម្រាប់សារការី ដោយជោគជ័យ ត្រូវទទួលបានសញ្ញាប័ត្រវិជ្ជាជីវៈសារការី ដែលចេញដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។[20]

## ១.២. តាមរយៈការតែងតាំងជាសារការី

ក្រៅពីការទទួលបានមុខងារជាសារការីតាមរយៈការបណ្ដុះបណ្ដាលមន្ត្រីមួយចំនួនក៏អាចទទួលបានទទួលមុខងារជាសារការីផងដែរគឺតាមរយៈការតែងតាំងដោយប្រកាសរបស់ក្រសួងយុត្តិធម៌ និងការតែងតាំងដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ។

### ១.២.១. ការតែងតាំងដោយប្រកាសក្រសួងយុត្តិធម៌

ដោយសារតែច្បាប់ស្ដីពីលក្ខន្តិកៈនៃសារការីមិនទាន់អនុម័ត ពេញលេញ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានចេញប្រកាសលេខ ៤៧ កយ. ប្រក/១២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ដើម្បីតែងតាំងមន្ត្រីជាច្រើនដើម្បីទទួលបន្ទុកអនុវត្តជាបណ្ដោះអាសន្ននូវកិច្ចការសារការីរហូតដល់មានសារការីដែលមាន វិជ្ជាជីវៈចេញមកពីការបណ្ដុះបណ្ដាលឬមានបទប្បញ្ញត្តិផ្ទុយពីប្រកាសនេះទើបមន្ត្រីទទួលបន្ទុកនោះត្រូវចប់ភារកិច្ចរបស់ខ្លួន ។ ការតែងតាំងនេះត្រូវបានធ្វើឡើងដោយយោងតាមមាត្រា១០ នៃច្បាប់ស្ដីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ដែលតម្រូវឲ្យមានសារការី ដើម្បីអនុវត្តមុខងារដូចជាដូចមានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ក្រោយពីបានអនុវត្តមួយរយៈរួចមក ប្រកាសលេខ ៤៧ កយ. ប្រក/១២ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០១២ ក៏បានត្រូវនិរាករណ៍ ដោយប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ៣២ កយ. ប្រក/ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ ដែលបានចែងថាប្រកាសលេខ ៤៧ កយ. ប្រក/ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់ក្រសួងយុត្តិធម៌ត្រូវទុកជានាករណ៍ហើយការតែងតាំងមន្ត្រីទទួលបន្ទុកសារការីត្រូវបានបន្ថែមច្រើនជាងមុន ។[21]

មន្ត្រីទទួលបន្ទុកសារការីទាំងអស់ដែលមានចែងនៅក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ៣២ កយ. ប្រក/ចុះថ្ងៃទី២៣ ខែឧសភាឆ្នាំ២០១២ ត្រូវបានតែងតាំងឲ្យអនុវត្តកិច្ចការសារការីរហូតដល់ការបរិច្ឆេទនៃការអនុវត្តច្បាប់ស្ដីពីលក្ខន្តិកៈនៃសារការីអនុម័តពេញលេញ ។ សូមបញ្ជាក់ថា នេះជាការតែងតាំងមន្ត្រីទទួលបន្ទុកអនុវត្តជាបណ្ដោះអាសន្ននូវកិច្ចការសារីដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ។

[20] មាត្រា៨ នៃអនុក្រឹត្យស្ដីពីការបង្កើតសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

[21] ប្រការ ៣ នៃប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ៣២ កយ.ប្រក/១២ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២។

### ១.២.២. ការតែងតាំងដោយអនុក្រឹត្យ

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ ៥០៥ អនក្រ/តត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ តែង តាំង លោក បែន សុនសម័យ ដែលជាសមាជិកមេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានូវមុខងារបន្ថែមជាមេធាវីសារការី ។ ការតែងតាំងនេះ ដោយសារមានតម្រូវការចាំបាច់នូវមុខងារសារការី ក្នុងប្រតិបត្តិការនានាលើវិស័យអចលនវត្ថុ ក៏ដូចជាវិស័យដែលពាក់ព័ន្ធដែលតម្រូវឲ្យមាន ការទិញលក់ ការជួល ការចុះបញ្ជី ដើម្បីឲ្យការផ្ទេរកម្មសិទ្ធិ, ការធ្វើមរតកសាសន៍ ដែលទាមទារឲ្យមានការផ្តល់យថាភូតដោយមន្ត្រីសារការី ដើម្បីឲ្យមានសុពលភាព ។ រហូតមកដល់បច្ចុប្បន្ននេះមានមេធាវីជាច្រើនត្រូវបានតែងតាំងដោយអនុក្រឹត្យជាមេធាវីសារការីនិងបានបង្កើតមន្ទីសារការីជាច្រើនជាបន្តបន្ទាប់ផងដែរ ។[22]

## ផ្នែកទី២ ៖ បែបបទនៃការបង្កើតមន្ទីរសារការី

ដើម្បីស្នើសុំបង្កើតមន្ទីសារការីបាន បេក្ខជនត្រូវមានលក្ខណៈសម្បត្តិជាសារការី និងត្រូវមានប្រាក់តម្កល់ធានាក្នុងធនាគារជាតិនៃកម្ពុជាសម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

### ២.១. លក្ខណៈសម្បត្តិជាសារការី

បុគ្គល ដែលទទួលបានមុខងារសារការី ទើបមានសិទ្ធិក្នុងការស្នើសុំបង្កើតមន្ទីរសារការីៗ ចំពោះលក្ខខណ្ឌដើម្បីក្លាយទទួលបានមុខងារជាសារការីនៅក្នុងពេលបច្ចុប្បន្ន បេក្ខជនអាចជ្រើសរើសមធ្យោបាយពីរគឺ តាមរយៈការប្រឡងប្រជែង ដើម្បីទទួលបានការបណ្តុះបណ្តាលពីសាលាភូមិន្ទវិជ្ជាជីវៈសារការី និង តាមរយៈការតែងតាំងជាសារការី ដូចដែលបានរៀបរាប់លម្អិតខាងលើនៅក្នុង **ជំពូកទី៣ នៃផ្នែកទី១** (**បែបបទនៃការប្រកបវិជ្ជាជីវៈសារការី**)។ ការទទួលបានមុខងារជាសារការីមានន័យថា បុគ្គលមួយរូបបានបំពេញនូវលក្ខខណ្ឌក្នុងការក្លាយខ្លួនជាសារការីយ៉ាងពេញលេញ ដោយមានទាំងចំណេះដឹង និង បទពិសោធន៍ យ៉ាងច្បាស់លាស់ក្នុងការបំពេញមុខងារ ក៏ដូចជាភារកិច្ចរបស់ខ្លួន ក្នុងគោលដៅធានាដល់ការអនុវត្តមុខងារឲ្យមានប្រសិទ្ធិភាព និងបម្រើផលប្រយោជន៍ដល់បុគ្គលឯកជន ព្រមទាំងសង្គមជាតិទាំងមូល។

### ២.២. ការតម្កល់ប្រាក់ធានានៅធនាគារជាតិនៃកម្ពុជា

យោងទៅតាម មាត្រា ៥ នៃអនុក្រឹត្យ ៥០៥ អនក្រ/តត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលតែង តាំង លោក បែនសុន

[22] អនុក្រឹត្យ ៥០៥ អនក្រ/តត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ តែង តាំង លោក បែនសុន សម័យ

សម័យដែលជាសមាជិកមេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នូវមុខងារបន្ថែមជាមេធាវីសារការី ។ តម្រូវឲ្យមេធាវីសារការី ត្រូវតំកល់ប្រាក់ធានាចំនួន ៦០០.០០០.០០០ ប្រាំមួយរយលានរៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ទទួលខុសត្រូវក្នុងមុខការនេះ។

ដូច្នេះបានបញ្ជាក់ថា បន្ទាប់ពីទទួលបាននូវមុខងារជាសារការីហើយ សារការីត្រូវតែធនធាន ក្នុងការបង់ប្រាក់តម្កល់ធានានៅធនាគារជាតិនៃកម្ពុជា ទើបអាចធ្វើការស្នើសុំបង្កើត និងដឹកនាំមន្ទីរសារការី ដើម្បីអនុវត្តមុខងាររបស់ខ្លួនបាន។

# ជំពូកទី៤

# តួនាទី និងការទទួលខុសត្រូវរបស់មេធាវី

## ផ្នែកទី១ ៖ តួនាទីរបស់មេធាវី

### ១.១. សញ្ញាណទូទៅទាក់ទង និងវិជ្ជាជីវៈរបស់មេធាវី

នៅពេលដែលគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាបានចាប់ផ្តើមដំណើរការដំបូង តាមរយៈមហាន្និបាតរបស់គណៈមេធាវី ដែលបានធ្វើឡើងនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥ ។ យើងឃើញមាន ព្រះរាជក្រមប្រកាសឲ្យប្រើ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥ ស្តីពីលក្ខន្តិកៈមេធាវី ។ ហើយមាត្រាដំបូងបង្អស់នៃច្បាប់លក្ខន្តិកៈមេធាវីចែងថា វិជ្ជាជីវៈមេធាវីគឺជា វិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបម្រើវិស័យយុត្តិធម៌។

ឯក្សារាជ្យភាពនៃវិជ្ជាជីវៈមេធាវី មានន័យថា មេធាវីអាចបំពេញមុខងាររបស់ខ្លួន ដោយគ្មានការកំហិត ឬការជ្រៀតជ្រែកដែលមិនសមស្រប ពីព្រោះ ជាទូទៅពួកគេ ដើរតួនាទីដ៏សំខាន់នៅក្នុងរដ្ឋបាលយុត្តិធម៌ត្រឹមត្រូវ និងក្នុងការបង្កើតនីតិរដ្ឋ។ ស្ថាប័នដែលតំណាងឲ្យមេធាវី គឺគណៈមេធាវី មិនមែនជាផ្នែកមួយនៃអំណាចរដ្ឋទេ ( អង្គនីតិប្រតិបត្តិ អង្គនីតិបញ្ញត្តិ និងស្ថាប័នតុលាការ ) មិនស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យពី គណៈបក្សនយោបាយ អង្គការសាសនា ឬអង្គការនានាផ្សេងទៀតប៉ុន្តែវាជាផ្នែកមួយនៃសង្គមស៊ីវិល។ គណៈមេធាវីជាអង្គការក្រៅរដ្ឋាភិបាលដែលត្រូវបានការពារដោយច្បាប់ជាក់លាក់មួយ( ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ) ពីព្រោះថា វាមានតួនាទីដែលឋិតថេរ នៅក្នុងការពង្រឹងនីតិរដ្ឋ និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ហើយនៅពេលអនុវត្តវិជ្ជាជីវៈរបស់ខ្លួនមេធាវីម្នាក់ៗ មិនស្ថិតនៅក្រោមបញ្ជា ឬការណែនាំពីបុគ្គលណាម្នាក់ ឬពីស្ថាប័នណាមួយឡើយ។

រីឯសេរីភាពនៃវិជ្ជាជីវៈមេធាវីគឺមានន័យថា មេធាវីមានសេរីភាពពេញលេញក្នុងការជ្រើសរើសទីកន្លែងប្រកបវិជ្ជាជីវៈ សេរីភាពទទួល ឬមិនទទួលផ្តល់សេវាកម្មច្បាប់ជូនអតិថិជន សេរីភាពក្នុងការកំណត់កំរៃសេវា និងសេរីភាពក្នុងការជ្រើសរើសមធ្យោបាយបំពេញការងារជាដើម។ កំរៃសេវារបស់មេធាវី គឺអាស្រ័យតាមការ ព្រមព្រៀងរវាងមេធាវី និងអតិថិជន ពោលគឺមិនមានច្បាប់ ឬបទដ្ឋានគតិយុត្តណាមួយកំណត់ពីអត្រានៃកម្រៃសេវារបស់មេធាវីទេ។ នៅក្នុងការផ្តល់សេវាកម្មច្បាប់ សកម្មភាពនៃវិជ្ជាជីវៈឯករាជ្យ និងសេរីទាំងនោះបានចូលរួមបម្រើវិស័យយុត្តិធម៌ ដែលជាបេសកកម្ម របស់មេធាវីក្នុង ការចូលរួមក្នុងការរៀបចំនីតិរដ្ឋ ពង្រឹងយុត្តិធម៌សង្គម និងការពារសិទ្ធិមនុស្ស។[23]

---

[23] យោងតាមមាត្រា៤ នៃច្បាប់ស្តីពី ក្រមសីលធម៌មេធាវី

ចំណែកឯក្នុងការបំពេញមុខងាររបស់ខ្លួន មេធាវីមានតួនាទីសំខាន់ៗជាច្រើនដូចជា មេធាវីអាចតំណាងកូនក្តីក្នុងរឿងក្តីរដ្ឋប្បវេណីដោយមានការយល់ព្រមពីកូនក្តី តាមរយៈលិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាល នៃនីតិវិធី លើកលែងតែមានបទបញ្ញត្តិច្បាប់ចែងផ្ទុយពីនេះជាពិសេសក្នុងរឿងរដ្ឋប្បវេណី ពាណិជ្ជកម្ម រដ្ឋបាល ការងារ សង្គមកិច្ច។ ទន្ទឹមនឹងនេះ មេធាវីអាចតំណាងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈពាក្យសុំពឹងពាក់ និងប្រគល់សិទ្ធិ ប៉ុន្តែនៅក្នុងរឿងព្រហ្មទណ្ឌមេធាវីមិនអាចតំណាងជនជាប់ចោទបានឡើយ លើកលែងតែក្នុងករណីអនុវត្តបទបញ្ញត្តិពិសេស នៃច្បាប់។ នៅក្នុងរឿងក្តីខាងលើនេះ មេធាវីដើរតួនាទីយ៉ាងសកម្មក្នុងការស្វែងរកភស្តុតាងបង្ហាញជូនតុលាការ។ បន្ថែមពីនេះ មេធាវីក៏អាចការពារសិទ្ធិជនសង្ស័យ ជនត្រូវចោទ និងជនចាប់ចោទ តាមរយៈពាក្យសុំពឹងពាក់មេធាវីក្នុងរឿងក្តីព្រហ្មទណ្ឌ និងអាចជួយការពារកូនក្តីបនៅចំពោះមុខក្រុមប្រឹក្សាវិន័យផងដែរ ប៉ុន្តែនៅក្នុងរឿងព្រហ្មទណ្ឌមេធាវីមិនអាចតំណាងជនជាប់ចោទបានឡើយ លើកលែងតែក្នុងករណីអនុវត្តបទបញ្ញត្តិពិសេស នៃច្បាប់។ ជាងនេះទៅទៀត មេធាវីអាចផ្តល់យោបល់ និងតាក់តែងលិខិតស្នាមផ្សេងៗក្នុងវិស័យគតិយុត្ត។ ជាពិសេសមេធាវីក៏អាចត្រូវបានចាត់តាំងដោយគូក្តី ឬចៅក្រមឲ្យបំពេញមុខងារជាអ្នកផ្សះផ្សារ ឬ ជាអ្នកសម្របសម្រួល ហើយមេធាវីនឹងអាចត្រូវបានចាត់តាំងជាអាជ្ញាកណ្តាលបានផងដែរ ប៉ុន្តែលុះត្រាតែមានច្បាប់អនុញ្ញាត។[24]

## ១.២. តួនាទីរបស់មេធាវី

### ១.២.១. ប្រឹក្សាយោបល់ក្នុងវិស័យគតិយុត្ត

មេធាវីអាចប្រឹក្សាយោបល់ផ្នែកច្បាប់[25] ជូនអតិថិជន ដោយគិតកម្រៃ ។ ហើយទំនាក់ទំនងរវាងមេធាវី និងអតិថិជន គឺជាទំនាក់ទំនងតាមកិច្ចសន្យា ហើយកិច្ចសន្យានោះមានប្រភពពីទំនៀមទម្លាប់ និងការព្រមព្រៀងគ្នាទៅវិញទៅមក ។ ទំនាក់ទំនងរវាងមេធាវី និងអតិថិជន កើតមានពេលជនណាម្នាក់ បង្ហាញអំពីបំណងចង់ឲ្យមេធាវីផ្តល់សេវាកម្មផ្នែកច្បាប់ ហើយមេធាវីនោះក៏យល់ព្រម ។

---

[24] យោងតាមមាត្រា២ និងមាត្រា៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

[25] មាត្រា៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

នេះជាជំហ៊ានដំបូង នៃទំនាក់ទំនងរវាងមេធាវី និងអតិថិជន មកសួរយោបល់ផ្នែកច្បាប់ តាមរយៈផ្ទាល់មាត់ ឬលាយអក្សរ ហើយមេធាវីមានកាតព្វកិច្ចរក្សាកាសម្ងាត់ជូនអតិថិជនរបស់ខ្លួន លើលលែងតែមានការជូនដំណឹងនិងយល់ព្រមពីអតិថិជនឬកាលណាមានការអនុញ្ញាតដោយច្បាប់ឬតម្រូវដោយច្បាប់។[26]

ចំពោះទីកន្លែងពិគ្រោះយោបល់ផ្នែកច្បាប់ជូនអតិថិជនត្រូវធ្វើនៅការិយាល័យដើម ឬ ក្នុងការិយាល័យសាខារបស់ខ្លួន ឬ ទីកន្លែងផ្សេងទៀតដែលមានភាពសមរម្យ និងធានាបាននូវការសម្ងាត់វិជ្ជាជីវៈ ។[27] កិច្ចការប្រឹក្សាយោបល់ផ្នែកច្បាប់មានដូចជា ៖

- ប្រមូលនូវព័ត៌មានអំពីអង្គហេតុ និង ភស្តុតាង ពាក់ព័ន្ធនឹងបញ្ហា ឬ វិវាទ ដែលអតិថិជនកំពុងជួបប្រទះ និង ទាមទារឱ្យរកដំណោះស្រាយ ។
- ធ្វើការវិភាគលើអង្គហេតុ និង ភស្តុតាងពាក់ព័ន្ធ ដើម្បីស្វែងរកចំណុចវិវាទ ឬ ស្នូលនៃបញ្ហា ដោយកំណត់ចំណុចខ្លាំង ឬ ចំណុចខ្សោយរបស់អតិថិជន ក្នុងការឈានដល់ការស្វែងរកវិធីដោះស្រាយជាវិជ្ជមានជូនអតិថិជនតាមរយៈយន្តការនៃការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតាមរយៈយន្តការសាលាជម្រះក្តី ។
- ផ្តល់អតិថិជននូវជម្រើសនៃវិធីដោះស្រាយ និង លទ្ធផល ដែលអាចរំពឹងទុកបាន ដោយកំណត់បង្ហាញអំពីចំណុចវិជ្ជមាន និង ចំណុចអវិជ្ជមាន ស្របទៅតាមវិធីដោះស្រាយ ដែលអតិថិជនបានជ្រើសរើស ។
- ពន្យល់បង្ហាញដល់អតិថិជននៅក្នុងការដោះស្រាយបញ្ហា តាមរយៈយន្តការនៃការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ ឬ ដំណើរការនីតិវិធីក្នុងដំណាក់កាលនីមួយៗ តាមរយៈយន្តការតុលាការមានសមត្ថកិច្ច ។
- ការប្រឹក្សាយោបល់ផ្នែកច្បាប់ខាងលើនេះ ពាក់ព័ន្ធនឹងផ្នែកផ្សេងៗ ជាអាទិ៍ ផ្នែកព្រហ្មទណ្ឌ ផ្នែករដ្ឋប្បវេណី ផ្នែកពាណិជ្ជកម្ម ផ្នែកការងារ និង ផ្នែកផ្សេងៗទៀត ស្របទៅតាមបទដ្ឋានគតិយុត្តក្នុងព្រះរាជាណាចក្រកម្ពុជា ។

[26] មាត្រា ១៩ ក្រមសិលធម៌មេធាវី

[27] មាត្រា ១៣ នៃក្រមសីលធម៌មេធាវី

### ១.២.២. តាក់តែងលិខិតស្នាមគតិយុត្ត

មេធាវីអាចតាក់តែងលិខិតស្នាមផ្សេងៗក្នុងវិស័យគត្តិយុត្តិ ជូនអតិថិជន ដោយគិតកម្រៃ ។[28] លិខិតស្នាមគតិយុត្តិ ដែលមេធាវីអាចតាក់តែងឡើង ដូចជាៈ

- ពាក្យបណ្តឹង
- តាក់តែងកិច្ចសន្យាគ្រប់ប្រភេទ និងគ្រប់ទម្រង់ ជាអាទិ៍ កិច្ចសន្យាលក់ទិញ, កិច្ចសន្យាខ្ចីបរិភោគ, កិច្ចសន្យាការងារ, កិច្ចសន្យាបញ្ញើ, កិច្ចសន្យាម៉ៅការ, កិច្ចសន្យាប្រវាស់, កិច្ចសន្យាប្រទានកម្ម, កិច្ចសន្យាភតិសន្យា, កិច្ចសន្យាខ្ចីប្រើ, កិច្ចសន្យាអាណត្តិ, កិច្ចសន្យាក្រុមហ៊ុន, កិច្ចសន្យាសះជា, កិច្ចសន្យាធនលាភសាមយិកមួយជីវិតជាដើម ស្របតាមច្បាប់ និង តម្រូវការរបស់អតិថិជន ដោយឈរលើផលប្រយោជន៍អតិថិជនជាធំ ។
- រៀបចំតាក់តែងកិច្ចព្រមព្រៀង លក្ខន្តិកៈក្រុមហ៊ុន និងឯកសារគតិយុត្តផ្សេងៗទៀត ស្របតាមតម្រូវការរបស់អតិថិជន ស្ថិតក្នុងលក្ខខណ្ឌច្បាប់ ដែលធានាឱ្យបាននូវផលប្រយោជន៍របស់អតិថិជន និងបញ្ចៀសនូវការរំលោភបំពានសិទ្ធិ រួមទាំងផលប្រយោជន៍របស់អតិថិជន ដែលអាចកើតចេញពីឯកសារគតិយុត្តទាំងនោះ។
- ចុះហត្ថលេខា និងប្រថាប់ត្រា បញ្ជាក់អំពីភាពត្រឹមត្រូវលើកិច្ចសន្យា កិច្ចព្រមព្រៀង និងលិខិតស្នាមគតិយុត្តផ្សេងៗ អនុលោមតាមច្បាប់ ។
- រៀបចំលិខិតជូនដំណឹងទៅភាគីពាក់ព័ន្ធ តាមរយៈការជូនដំណឹងឱ្យធ្វើ ឬ ហាមឃាត់ការធ្វើសកម្មភាពណាមួយ រួមទាំងដាស់តឿន ឬព្រមានចាត់វិធានការតាមផ្លូវច្បាប់ ចំពោះសកម្មភាពរំលោភបំពានផ្សេងៗ ស្របតាមអង្គហេតុ និង តាមការចង់បានរបស់អតិថិជន ស្របតាមក្របខណ្ឌច្បាប់ ។

សូមបញ្ជាក់ថា កិច្ចសន្យាដែលធ្វើដោយឡើងដោយមេធាវី គឺជាលិខិតឯកជន មិនមានតម្លៃស្មើនឹងសាលក្រមស្ថាពរទេ ។ លិខិតឯកជន សំដៅដល់លិខិតទាំងឡាយណា ដែលបង្កើតឡើងដោយបុគ្គលឯកជន ដោយមានការចុះហត្ថលេខា ឬស្នាមមេដៃ។[29] ហើយ បើកូនបំណុលមិនអនុវត្តកាតព្វកិច្ចម្ចាស់បំណុលមិនអាចយកទៅអនុវត្តដោយបង្ខំបានទេ គឺត្រូវតែឆ្លងកាត់នីតិវិធីតុលាការដើម្បីសម្រេចសេចក្តី។

[28] មាត្រា៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

[29] យោងតាមសន្ទានុក្រមនៃក្រមរដ្ឋប្បវេណី

### ១.២.៣. អ្នកអាជ្ញាកណ្តាល ឬអ្នកសម្រុះសម្រួល

ការផ្សះផ្សារថាគឺជាវិធីដែលភាគីទីបីដែលជាអ្នកផ្សះផ្សារជួបជាមួយនឹងភាគីជម្លោះដាច់ដោយឡែកពីគ្នា (ការជួបដាច់ដោយឡែកពីគ្នា)ដើម្បីព្យាយាមរកនូវការព្រមព្រៀងពីភាគីក្នុងការដោះស្រាយជម្លោះ។ មេធាវីអាចត្រូវបានចាត់តាំងដោយគូក្តី នៅពេលមេធាវីមានការយល់ព្រមពីកូនក្តីក្នុង តំណាងឱ្យភាគីក្នុងការចូលរួមដំណើរការផ្សះផ្សា ចរចា សម្រុះសម្រួល លើវិវាទរដ្ឋប្បវេណី ការងារ ពាណិជ្ជកម្មជាដើម។ មេធាវីក៏អាចចាត់តាំង ដោយចៅក្រមឲ្យបំពេញមុខងារជាអ្នកផ្សះផ្សា ឬ ជាអ្នកសំរុះសំរួលផងដែល ប្រសិនបើរឿងនោះមានលក្ខណៈជារឿងរដ្ឋប្បវេណី ឬអាពាហ៍ពិពាហ៍ និងគ្រួសារ។ មេធាវីនឹងអាចបំពេញតួនាទីជា អាជ្ញាកណ្តាល ដោយរៀបចំដំណើរការផ្សះផ្សាលើវិវាទរដ្ឋប្បវេណី និង ពាណិជ្ជកម្ម បានលុះត្រាតែមានច្បាប់អនុញ្ញាត ។ នៅក្នុងវិវាទការងារ មានមេធាវីមួយចំនួន ត្រូវបានតែងតាំងជាអ្នកអាជ្ញាកណ្តាល នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ ។[30]

សូមបញ្ជាក់ថា ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺជាស្ថាប័នជាតិ ឯករាជ្យមួយ ដែលមានអំណាចសម្រេចសេចក្តីដូចមានចែងនៅ ក្នុងច្បាប់ស្តី ពីការងាររបស់ព្រះរាជាណាចក្រកម្ពុជា។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៣ ដោយមានការគាំទ្រ ពីក្រសួងការងារ សមាគមនិយោជក និងសហជីព ព្រមទាំងជំនួយបច្ចេកទេសពីអង្គការអន្តរជាតិខាងការងារ(ILO)។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចតាមច្បាប់ដើម្បីជួយភាគីវិវាទ ដោះស្រាយវិវាទការងាររួមនៅក្នុងប្រទេសកម្ពុជា។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបាន ការគាំទ្រពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងការគ្រប់គ្រងសំណុំរឿងវិវាទការងារ និងពីមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលលើផ្នែកបច្ចេកទេស និងការគ្រប់គ្រងទូទៅ។ សព្វថ្ងៃនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានគេទទួលស្គាល់ថា ស្ថាប័នចម្បងដ៏សំខាន់ក្នុងការដោះស្រាយវិវាទការងារនៅព្រះរាជាណាចក្រកម្ពុជា ដែលត្រូវការចាំបាច់ក្នុងការជួយធ្វើឲ្យមានស្ថេរភាពនៃទីផ្សារការងារ និងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចជាតិ។[31]

### ១.២.៤. តំណាងដោយអាណត្តិ និងការពារកូនក្តី

មេធាវីអាចតំណាង និង ជួយការពារកូនក្តីតាមការយល់ព្រមពីកូនក្តី នៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធីលើកលែងតែមានបទបញ្ញត្តិច្បាប់ចែងផ្ទុយពីនេះ ជាពិសេសក្នុងរឿង រដ្ឋប្បវេណី

[30] មាត្រា ៤ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

[31] ក្រុមប្រឹក្សាអាជ្ញាកណ្តាល https://www.arbitrationcouncil.org/about-ac/arbitration-council/?lang=km

ពាណិជ្ជកម្ម រដ្ឋបាល ការងារ សង្គមកិច្ច ។ មេធាវីអាចតំណាងចំពោះតែអ្នកទទួលខុសត្រូវក្នុងបទរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ហើយមេធាវីមិនអាចតំណាងជន ជាប់បានឡើយនៅក្នុងរឿងក្តីព្រហ្មទណ្ឌ លើកលែងតែក្នុងករណីអនុវត្តបទបញ្ញត្តិពិសេសនៃច្បាប់ ។[32]

ប្រសិនបើមេធាវីតំណាងក្នុងរឿងក្តីរដ្ឋប្បវេណី គេហៅថា មេធាវីតំណាងដោយអណត្តិ ។ ការធ្វើជាមេធាវីតំណាងដោយអាណត្តិឱ្យអតិថិជន (កូនក្តី) សំណុំរឿងរដ្ឋប្បវេណី មានច្រើនដូចជា ៖

- សំណុំរឿងអង្គសេចក្តី
- សំណុំរឿងរក្សាការពារ
- សំណុំរឿងអនុវត្តដោយបង្ខំ
- សំណុំរឿងសុំឱ្យជំនុំជម្រះសាជាថ្មី
- សំណុំរឿងទាក់ទងនឹងឋានៈបុគ្គល
- សំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង
- សំណុំរឿងដែលពាក់ព័ន្ធនឹងពាក្យសុំផ្សេងៗ នៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ។

ចំណែកឯការធ្វើជាមេធាវីតំណាងដោយអាណត្តិឱ្យអតិថិជន (កូនក្តី) ក្នុងសំណុំរឿងពាណិជ្ជកម្ម និង ការងារ រួមមាន ដូចជា ៖

- វិវាទកិច្ចសន្យាភាគហ៊ុន
- ការផ្លាស់ប្តូរលក្ខន្តិកៈក្រុមហ៊ុន
- ការរំលាយក្រុមហ៊ុន
- ការជម្រះបញ្ជីក្រុមហ៊ុន
- វិវាទអំពីសិទ្ធិនៃបទប្បញ្ញត្តិនៅក្នុងច្បាប់ការងារ កិច្ចសន្យាការ ជាដើម ។

ចំពោះមេធាវីជួយការពារកូនក្តី តាមការយល់ព្រមពីកូនក្តី នៅគ្រប់ សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធីលើកលែងតែមានបទបញ្ញត្តិច្បាប់ចែងផ្ទុយពីនេះ ជាពិសេសក្នុងរឿង រដ្ឋប្បវេណី ពាណិជ្ជកម្ម រដ្ឋបាល ការងារ សង្គមកិច្ច នោះ ។ មេធាវីអាចជួយការពារជនជាប់ចោទក្នុងរឿងក្តីព្រហ្មទណ្ឌ

[32] មាត្រា ២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

និងជួយការពារកូនក្តីបានដែរនៅចំពោះមុខក្រុមប្រឹក្សាវិន័យ ។ ការធ្វើជា មេធាវី ការពារសិទ្ធិ ឱ្យជនសង្ស័យ ឬជនត្រូវចោទ ឬជនជាប់ចោទ នៅសំណុំរឿងព្រហ្មទណ្ឌ នៅគ្រប់ដំណាក់កាលនីតិវិធីដូចខាងក្រោមៈ

- នីតិវិធីស៊ើប អង្កេត
- នីតិវិធី ចោទប្រកាន់ (អយ្យការ)
- នីតិវិធីការស៊ើបសួរ និង
- នីតិវិធីកាលជំនុំជម្រះក្តី។

ចំណែកឯការតំណាង និងការការពារសិទ្ធិខាងលើ នេះ អាចធ្វើឡើង នៅ គ្រប់ សាលាជម្រះក្តី រួម មានៈ

- សាលាដំបូង
- សាលាឧទ្ធរណ៍ និង
- តុលាការកំពូល ។

ហើយមេធាវីការពារក្តី យើងសម្គាល់ឃើញគេប្រើពាក្យនេះសម្តៅក្នុងរឿងព្រហ្មទណ្ឌ ។ ការការពារក្នុងសំណុំរឿងព្រហ្មទណ្ឌ តម្រូវឲ្យមេធាវី ត្រូវស្វែងយល់ពីដំណើរអង្គហេតុដែលបានកើតឡើងឲ្យបានច្បាស់លាស់ ពិសេសគឺត្រូវដឹងអំពីមូលដ្ឋាន និងគោលការណ៍ច្បាប់ព្រហ្មទណ្ឌ ។

ជាទូទៅមូលដ្ឋាន នៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាធ្វើឡើងនៅពេលដែលធាតុផ្សំបទល្មើសមានគ្រប់គ្រាន់ មេធាវីត្រូវដឹងច្បាស់កំហុស និងអង្គហេតុដែលកូនក្តីខ្លួនបានប្រព្រឹត្ត និងដឹងពីលក្ខខណ្ឌដែលច្បាប់បានកំណត់ចំពោះការប្រព្រឹត្តផ្ទុយពីនេះ តួយ៉ាងតាមរយៈសាក្សី ឬភស្តុតាងបង្ហាញនានាដែលអាចជួយកូនក្តីបាន ។ នៅក្នុងការពារការសំណុំរឿងព្រហ្មទណ្ឌ មេធាវីយកទ្រឹស្តីពីរមកការពារ ស្នើឲ្យកូនក្តីរួចផុតពីបទចោទ និង ស្នើសុំស្ថានសម្រាលឲ្យកូនក្តី ។

## ផ្នែកទី២ ៖ ការទទួលខុសត្រូវរបស់មេធាវី

### ២.១. ភាតព្វកិច្ចគោរពនូវការសម្ងាត់វិជ្ជាជីវៈ

មេធាវីត្រូវតែ រក្សាការសំងាតវិជ្ជាជីវៈមេធាវីជាដាច់ខាត។ ការសំងាត់នេះ មិនត្រូវអាចអោយជនណាស្រង់យកបានឡើយ ទោះបីថាជាអតិថិជនក៏ដោយ ។ មេធាវីកំណត់តាមសតិសម្បជញ្ញៈ របស់ខ្លួន និងដោយមានការយល់ព្រមពីអតិថិជនផងនូវអ្វី ដែលខ្លួនត្រូវលើកឡើង ដើម្បីការពារផលប្រយោជន៍របស់អតិថិជន ដែលខ្លួនទទួលបន្ទុក ។ មេធាវីពុំអាចបំពារបំពានលើការសំងាត់ នៃវិជ្ជាជីវៈ បានឡើយ ហើយក៏មិនអាចត្រូវបានបង្ខំ

អោយបំពារបំពានលើការសំងាត់ នៃវិជ្ជាជីវៈរបស់ខ្លួនទោះបីនៅមុខតុលាការក៏ដោយ ។ ពុំមានកាតព្វកិច្ចលាក់អាថ៌កំបាំងទេ ស្តីកណាមេធាវីត្រូវឆ្លើយតបទៅនឹងបណ្តឹងរបស់អតិថិជនរបស់ខ្លួនប៉ុន្តែត្រូវស្ថិតត្រឹមក្នុងកំរិត នៃការចាំបាច់ នៃការការពាររបស់ខ្លួនតែប៉ុណ្ណោះ ។ត្រូវទុកជាការសំងាត់នៃវិជ្ជាជីវៈ ការពិគ្រោះយោបល់ និងការផ្តល់យោបល់ឯកសារក្រៅផ្លូវការទាំងឡាយ ដែលមេធាវីតាក់តែងឡើងសំរាប់អតិថិជនរបស់ខ្លួន លិខិតស្នាមទាំងឡាយ ដែលមេធាវី និងអតិថិជនផ្ញើទាក់ទងគ្នា។[33]

ការរក្សាការសំងាត់នេះ មានន័យថា មេធាវីពេលទទួលពិគ្រោះច្បាប់ ឬ ការពារក្តី ឬ តំណាងក្តីអោយអតិថិជនណាម្នាក់ហើយ គឺមិនអាចនិយាយ ឬទំលាយរឿងហេតុ ដែលខ្លួនអោយទៅជាសាក្សី ឬ អោយប៉ះពាល់ដល់អាថ៌កំបាំងវិជ្ជាជីវៈ ។ មេធាវីក៏មិនអាចធ្វើអន្តរាគមន៍ទៅកើតដែរ កាលណាការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់ខ្លួន ត្រូវចោទប្រកាន់ឡើង ។មេធាវីមិនអាចទទួលការពិគ្រោះច្បាប់នៅទីកន្លែងសាធារណៈ បានឡើយ លើកលែងតែនៅសាលាខេត្តក្រុង និងឃុំ ដែលមានបន្ទប់សំរាប់ការពិគ្រោះច្បាប់នេះ ដើម្បីរក្សាការសំងាត់វិជ្ជាជីវៈ ។ ខ្លួនបានដឹងទៅអោយជនណាម្នាក់ ឬច្រើននាក់បានដឹងឡើយ ។ ការទំលាយពត៌មានទាំងឡាយ នៃរឿងក្តីគឺជាការរំលោភលើការសំងាត់ នៃវិជ្ជាជីវៈ ។ ប៉ុន្តែមិនអាចចាត់ទុកជាការសំងាត់ នៃវិជ្ជាជីវៈទេ បើគ្រាន់តែជានីតិវិធីរបស់តុលាការក្នុងរឿងក្តីណាមួយនោះ ។

មេធាវី ដែលជាអ្នកតាក់តែងលិខិតស្នាមតែម្នាក់ឯង អាចធ្វើសកម្មភាព ឬការពារលើការអនុវត្តន៍លិខិត , នោះ បាន នៅពេលដែលការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់ខ្លួនត្រូវចោទប្រកាន់ឡើង លើកលែងតែទៅប្រឆាំងនឹងភាគីណាមួយ ដែលនៅក្នុងលិខិតស្នាមនោះ ។ មេធាវី ដែលបានចូលរួមក្នុងការតាក់តែលិខិតស្នាមក្នុងឋានៈជាទីប្រឹក្សារបស់ភាគីម្ខាង អាចធ្វើសកម្មភាព ឬការពារលើការអនុវត្តន៍លិខិតនោះតទល់នឹងភាគីម្ខាងទៀតបាន ។

មេធាវី ដែលជាអ្នកតាក់តែងលិខិតស្នាម ឬ ដែលជាអ្នកចូលរួមតាក់តែងមិនអាចបំពេញកិច្ចការ ឬការពារលើសុពលភាព ឬ លើការបកស្រាយលិខិតស្នាម ដែលខ្លួនបានសរសេរនោះទេ កាលបើការអន្តរាគមន៍របស់ខ្លួននាំខ្លួនឲ្យទៅជាសាក្សី ឬ ឲ្យប៉ះពាល់ដល់អាថិកំបាំងវិជ្ជាជិវៈ។ មេធាវីនេះក៏មិនអាចធ្វើះអន្តរាគមន៍ទៅកើតដែរ កាលណាការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់ខ្លួន ត្រូវចោទប្រកាន់ឡើង។

មេធាវីមិនអាចទទួលការពិគ្រោះច្បាប់នៅទីកន្លែងសាធារណៈបានឡើយលើកលែងតែនៅសាលាខេត្តក្រុង និងឃុំ ដែលមានបន្ទប់សំរាប់ការពិគ្រោះច្បាប់នេះ ដើម្បីរក្សាការសំងាត់វិជ្ជាជិវៈ។

---

[33] មាត្រា ៥៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

## ២.២. ទំនួលខុសត្រូវចំពោះអតិថិជន

### ២.២.១. តក្តីភាពក្នុងការបំពេញបេសសកម្មជូនអតិថិជន

មេធាវីត្រូវមានការសីលធម៌ខ្ពស់ក្នុងការងារ ដោយធ្វើយ៉ាងណាអោយអតិថិជនមានការពេញចិត្ត និងជឿជាក់លើ ។ មេធាវីមានសេរីភាពទទួល ឬមិនទទួលជួយកូនក្តី បើខ្លួនយល់ថា មានការប៉ះពាល់ដល់សម្បជញ្ញៈរបស់ខ្លួន ។ ប៉ុន្តែបើសិនជាមេធាវីយល់ព្រមទទួលជួយកូនក្តីណាមួយហើយ មេធាវីត្រូវបំពេញបេសកកម្មរបស់ខ្លួនរហូតដល់ទីបំផុត អោយបានចប់សព្វគ្រប់ និងអោយអស់ពីសមត្ថភាព និងពីចិត្តពីថ្លើម របស់ខ្លួន ។ មេធាវីត្រូវចាត់ទុករឿងក្តីរបស់អតិថិជន ដូចជារឿងក្តីរបស់ខ្លួនផ្ទាល់ និងជាពិសេសគិតគូផលប្រយោជន៍របស់អតិថិជន អោយដូចជាផលប្រយោជន៍របស់ខ្លួនផ្ទាល់ដែរ ។

មេធាវី ទទួលជួយអតិថិជនរួចហើយជួនការអាចត្រូវបានបញ្ចប់ទៅវិញដោយសារតែអតិថិជនខ្លួនឯងឈប់ពឹងពាក់ខ្លួន ។ ពេលនេះមេធាវីត្រូវប្រគល់ជូនអតិថិជនវិញ នូវអ្វីៗ ដែលខ្លួនបានទទួលពីអតិថិជន ដូចជាសំណៅឯកសារច្បាប់ដើម... ។ល ។ ដោយជៀសវាងក្បត់អតិថិជនខ្លួនលាក់ទុកឯកសារ ឬទំលាយការសំងាត់ប្រាប់ទៅអតិថិជនម្ខាងទៀត ។ ម្យ៉ាងទៀត មេធាវីអាចសំរេចបញ្ចប់បេសកកម្មរបស់ខ្លួន ដែលបំពេញជូនអតិថិជនបានដែរ ដោយសារតែមានបុព្វហេតុប៉ះពាល់សម្បជញ្ញៈរបស់ខ្លួន តែត្រូវជូនដំណឹងទៅអតិថិជនខ្លួនបានដឹងក្នុងពេលវេលាមួយដែលផ្តល់លទ្ធភាពអោយអតិថិជននេះ អាចបង្ការផលប្រយោជន៍របស់ខ្លួនបាន ដូចជាការរកមេធាវីថ្មីដើម្បីការពារ ឬ រៀបចំឯកសារនានា ដើម្បីធ្វើកិច្ចការនេះដោយខ្លួនឯង ។

បេសកម្មទាំងឡាយ ដែលចាត់តាំងដោយប្រធានគណៈមេធាវី មេធាវីត្រូវតែទទួលយក ។ ប៉ុន្តែបើមានហេតុផលបញ្ជាក់ថា មានការប៉ះពាល់ដល់សម្បជញ្ញៈរបស់ខ្លួន មេធាវី អាចប្រកែកមិនទទួលយកបាន ។

មេធាវីត្រូវប្រកែកមិនព្រមទទួលជួយ កិច្ចប្រតិបត្តិការទាំងឡាយណា ឬ អំពើទាំងឡាយណា ដែលផ្ទុយពីវិធានវិជ្ជាជីវៈ និងផ្ទុយពីការតម្រូវ នៃសម្បជញ្ញៈរបស់ខ្លួន ។

មេធាវីមិនត្រូវលាក់លៀមនឹងកូនក្តីនូវអ្វីដែលខ្លួនយល់ថា គួរប្រាប់ដល់កូនក្តី ដើម្បីជាប្រយោជន៍ស្របច្បាប់របស់កូនក្តី ។ មេធាវីមិនត្រូវប្រើល្បិចកេងបន្លំទាញផលប្រយោជន៍ពីអតិថិជននោះទេ គឺត្រូវប្រកាន់នូវអត្តចរិតថ្លៃថ្នូរ មានសតិសម្បជញ្ញៈទទួលខុសត្រូវ ទៀងទាត់ មនុស្សធម៌ ឯករាជ្យ និងគោរពច្បាប់ ។

ដោយភាពភក្តីរបស់មេធាវីចំពោះកូនក្តី ច្បាប់បានកំណត់ហាមឃាត់មិនអោយមេធាវី ដែលជាអតីតមន្ត្រី

រាជការ ធ្វើអន្តរាគមន៍ការពារកូនក្តីប្រឆាំងនឹងក្រសួងមន្ទីររដ្ឋបាល ដែលខ្លួនស្ថិតនៅក្រោមឱវាទពីមុនបាន ។ ករណីនេះមេធាវីអាចធ្វើបទអន្តរាគមន៍វិញបានលុះត្រាតែផុតរយៈពេល ៥ ឆ្នាំ គិតពីថ្ងៃឈប់ពីមុខងាររបស់ខ្លួន ។ ច្បាប់កំណត់បែបនេះ ដើម្បីជៀសវាងនូវការខូចប្រយោជន៍របស់អតិថិជន ឬជាពិសេស ដើម្បីកុំអោយមេធាវីបានពត៌មានពីភាគីក្រសួងស្ថាប័ននោះ ដែលជាទំនាស់ផលប្រយោជន៍ក្នុងរឿងក្តី ដែលច្បាប់ហាមឃាត់ ។

នៅពេលដែលមេធាវីត្រូវអតិថិជនច្រើនគ្នាពឹងពាក់ ក្នុងរឿងក្តីតែមួយ ឬក្នុងការប្រតិបត្តិការតែមួយដូចគ្នា មេធាវីមិនត្រូវកាន់ជើងផ្តល់ប្រយោជន៍អោយតែអតិថិជនណាមួយឡើយ ។ អ្វីៗត្រូវតែជូនដំណឹងទៅភាគីទាំងអស់គ្រប់គ្នា ។ មេធាវីមិនអាចផ្តល់យោបល់ ឬ ជួយ ឬតំណាង ឬការពារភាគីច្រើនគ្នា បើប្រសិនជាមានកើតឡើងរវាងភាគីទាំងនោះ៖ នូវទំនាស់ផលប្រយោជន៍គ្នាណាមួយ ។ បើសិនជារឿងនេះកើតឡើងមែន ក្នុងពេលដែលមេធាវីជាឬ ធ្លាប់ជាទីប្រឹក្សារបស់ភាគី ច្រើនគ្នានោះ មេធាវីនឹងអាចទទួលការពារប្រយោជន៍ភាគីណាមួយបានលុះត្រាតែត្រូវជំរាបទៅភាគីឯទៀតៗអោយបានដឹងសិន ហើយត្រូវប្រុងប្រយ័ត្នកុំអោយបាត់បង់នូវភាពគួរសមថ្លៃថ្នូរ និងអាថ៌កំបាំងវិជ្ជាជីវៈ ផង ។[34]

ក្នុងរឿងតុលាការ មេធាវី ដែលបានផ្តល់ហាបល់ ឬបានជួយ ឬបានតំណាងភាគីណាមួយមិនអាចទៅអន្តរាគមន៍ជួយខាងគូរប្រឆាំង ក្នុងរឿងក្តីដដែល ឬក្នុងរឿង ដែលពាក់ព័ន្ធនឹងរឿងក្តីដដែលបានឡើយ ។

ក្នុងគ្រប់រឿងទាំងអស់ មេធាវីនឹងអាចធ្វើអន្តរាគមន៍ប្រឆាំងនឹងកូនក្តី ដែលខ្លួនធ្លាប់បានជួយពីលើកមុនបានតែក្នុងលក្ខខ័ណ្ឌតឹងរឹង នៃការគោរពអាថ៌កំបាំងវិជ្ជាជីវៈ និងភាពគួរសមថ្លៃថ្នូរប៉ុណ្ណោះ " ។

បទបញ្ញត្តិនេះ ត្រូវអនុវត្តន៍ទៅលើគ្រប់មេធាវីទាំងអស់ ដែលធ្វើការនៅក្នុងរចនាសម្ព័ន្ធតែមួយរួមគ្នាហើយនឹងទៅលើសហការី ឬ និយោជិតទាំងអស់ ។

មេធាវីតាំងឡាយ ដែលជាសមាជិក នៃក្រុមប្រមូលផ្តើមធ្យោបាយ អាចនឹងផ្តល់យោបល់ ឬជួយ ឬតំណាងភាគីនានា ដែលមានផលប្រយោជន៍ប្រឆាំងគ្នាបាន លុះត្រាតែមានការយល់ព្រមពីអតិថិជនរៀងៗខ្លួន និងក្នុងលក្ខខ័ណ្ឌ នៃការគោរពអាថ៌កំបាំង នៃវិជ្ជាជីវៈ[35] មេធាវី នៃអតិថិជនមួយអាចនឹងទំនាក់ទំនងជាមួយនឹងអតិថិជនជាបដិបក្សរបស់អតិថិជនខ្លួនបានលុះត្រាតែមានការយល់ព្រមពីអតិថិជនខ្លួន ។ បើសិនជាអថិជនម្ខាងទៀតនោះ មានមេធាវី មេធាវីមុននឹងអាចជួបអតិថិជននោះ បានត្រូវមានការយល់ព្រមពីមេធាវីរបស់គេ ឬជួបនៅ

[34] យោងតាមមាត្រា ១៩ នៃក្រមសីលធម៌មេធាវី

[35] មាត្រា ២០ នៃក្រមសីលធម៌មេធាវី

ចំពោះមុខមេធាវីរបស់គេ ឬអាចជួបនៅចំពោះមុខភាគីសាមីទាំងអស់ និងមេធាវីរបស់គេ ។ នេះជាចំនុចចង់អោយមេធាវីមានភាពស្មោះត្រង់នឹងកូនក្តីរបស់ខ្លួនជៀសវាងមេធាវីត្រូវរ៉ូវគ្នានឹងកូនក្តីម្ខាងទៀត ឬធ្វើអំពើអ្វីមួយមិនសមរម្យ ។

## ២.២.២. ភាតព្វកិច្ចរបស់មេធាវីចំពោះ អតិថិជន

មេធាវី និងកូនក្តីចងកាតព្វកិច្ចរវាងគ្នាដោយសារតែកិច្ចសន្យាផ្តល់សេវាច្បាប់ រវាងមេធាវី និងកូនក្តីតែប៉ុណ្ណោះ ។ មេធាវីត្រូវបំពេញការងាររបស់ខ្លួនជូនអតិថិជន ទៅតាមកាតព្វកិច្ច ដែលបានកំណត់នៅក្នុងកិច្ចសន្យាផ្តល់សេវាច្បាប់ ។ មេធាវីត្រូវយល់ដឹងពីថា ខ្លួនជាម្ចាស់នៃមធ្យោបាយការពាររបស់អតិថិជនខ្លួន ។ នៅក្នុងកិច្ចសន្យាផ្តល់សេវាមេធាវីត្រូវកំណត់ផងដែរអំពីប្រាក់កំរៃសេវារបស់ខ្លួនអោយបានច្បាស់ ដូចជាការកំណត់ជាទឹកប្រាក់សរុបផ្តាច់តែម្តង ឬ គិតកំរៃជាម៉ោង ជាខែជាដើម ។ បើមានការមិនចុះសំរុងនឹងគ្នា មេធាវី និងអតិថិជនអាចសុំអោយប្រធានគណៈមេធាវីធ្វើការសំរុះសំរួលបាន ។

ដើម្បីបំពេញ ការងារការពារអោយអតិជនរបស់ខ្លួនបានត្រឹមត្រូវ មេធាវីត្រូវមានលិខិតពឹងពាក់ពីកូនក្តី ឬលិខិតប្រគល់សិទ្ធិពីកូនក្តី ដែលលិខិតទាំងនេះ ត្រូវតែទទួលបានពីកូនក្តីដោយផ្ទាល់ ។ មេធាវីមិនអាចទទួលរឿងក្តីមួយតាមរយៈតតីយជនបានឡើយ ។

យោងតាមមាត្រា ២៨ នៃក្រមសីលធម៌បានចែងថា " មេធាវី ដែលត្រូវគេអោយឈប់ធ្វើរឿងក្តីនោះត្រូវឆ្លើយតបយ៉ាងរហ័ស និងបញ្ជូនមកនូវអ្វីៗទាំងអស់របស់សំណុំរឿង ដែលគ្មានសិទ្ធិអ្វីនឹងខាយាំងទុកតទៅទៀតឡើយ " ។ ត្រង់នេះមានន័យថា មេធាវីមានកាតព្វកិច្ចប្រគល់នូវរាល់ឯកសារដើមទាំងឡាយ ដែលខ្លួនទទួលពីកូនក្តី នៅពេលដែលខ្លួនឈប់ធ្វើការអោយកូនក្តីតទៅទៀត ។ ការបង្ខាំងទុកនូវឯកសាររបស់កូនក្តីមេធាវីនោះនឹងប្រឈមមុខទណ្ឌកម្មវិន័យ និងទណ្ឌកម្មផ្សេងទៀត ។

មេធាវី ដែលទទួលការពារក្តីអោយអតិថិជនហើយ ត្រូវខិតខំបំពេញការងាររបស់ខ្លួនអោយអស់ពីសមត្ថភាព និងដោយយកចិត្តទុកដាក់ដូចជារឿងក្តីផ្ទាល់ខ្លួនដែរ ។ ថ្វីត្បិតតែកិច្ចសន្យាផ្តល់សេវារវាងមេធាវី និងកូនក្តីជាប្រភេទកិច្ចសន្យា នៃមធ្យោបាយ ប៉ុន្តែគោលដៅ នៃកិច្ចសន្យានេះ៖ គឺចង់បានសំរេចនូវលទ្ធផល ។ ដូចនេះមេធាវី ត្រូវខិតខំប្រឹងប្រែងអោយអស់ពីសមត្ថភាពខ្លួនរកគ្រប់មធ្យោបាយតាមផ្លូវច្បាប់ ដើម្បីទទួលបាននូវផលប្រយោជន៍ជូនកូនក្តី ។ ទោះបីក្នុងករណីយ៉ាងណាក៏ដោយ មេធាវីមិនអាចធានាពីលទ្ធផល និងទទួលខុស

ត្រូវពីលទ្ធផលទេ លើកលែងតែកូនក្តីរកឃើញនូវកំហុសឆ្គងរបស់មេធាវីដែលមិនគោរពបានត្រឹមត្រូវតាមកាតព្វកិច្ចនៃវិជ្ជាជីវៈរបស់ខ្លួន ។

ដើម្បីអោយមេធាវីទទួលខុសត្រូវចំពោះការខាតបង់ផលប្រយោជន៍ របស់ខ្លួនបានអតិថិជនត្រូវលើកបង្ហាញនូវធាតុផ្សំទាំងបីដូចខាងក្រោម៖

- **មានកំហុសរបស់មេធាវី** : មេធាវីធ្វើកិច្ចការរបស់ខ្លួនមិនពោរពកាតព្វកិច្ចវិជ្ជាជីវៈ បានត្រឹមត្រូវ ដោយមានការខ្ជីខ្ជាធ្វេសប្រហែស ឬ មិនព្រមបំពេញ ដែលជាហេតុធ្វើអោយខូចប្រយោជន៍ដល់កូនក្តី ។ការខូចប្រយោជន៍ នេះមិនមានទាក់ទិនដល់កំហុសណាផ្សេងពីកំហុសរបស់មេធាវីឡើយ ។

<u>ឧទាហរណ៍ :</u> មេធាវី ដែលទទួលរៀបចំពាក្យបណ្តឹងជូនអតិថិជន ដែលជិតផុតអាជ្ញាយុកាលប្តឹង ។ ប៉ុន្តែមេធាវីនោះធ្វេសប្រហែស មិនបានរៀបចំដាក់ពាក្យបណ្តឹងទាន់ពេល ធ្វើអោយហួសអាជ្ញាយុកាលអាចប្តឹងបាន ដែលជាហេតុនាំអោយខូចផលប្រយោជន៍របស់កូនក្តី ។ ករណីកូនក្តីត្រូវរកអោយឃើញថាការហួសអាជ្ញាយុកាលនេះបណ្តាលមកពីមេធាវីមិនបានបំពេញការងាររបស់ខ្លួនអោយបានឆាប់តាមលទ្ធភាពរបស់ខ្លួន ដែលអាចធ្វើបាន ។ អតិថិជន បានមកពឹងពាក់ខ្លួនមុនពេលវេលា ដែលត្រូវផុតអាជ្ញាយុកាល នៃបណ្តឹង ។ ទង្វើនេះជាកំហុសរបស់មេធាវី ។កំហុសរបស់មេធាវីមានដូចជាការធ្វើសប្រហែសបណ្តាលអោយផុតអាជ្ញាយុកាល នៃបណ្តឹង ការធ្វេសប្រហែសមិនបានចូលរួមក្នុងនីតិវិធីរបស់តុលាការ ការធ្វេសប្រហែសមិនធ្វើអោយបាត់ឯកសារសំខានៗនៃរឿងក្តី និងការធ្វេសប្រហែសក្នុងការគ្រប់គ្រងឯកសារ និងអាថ៌កំបាំងវិជ្ជាជីវៈ ។

- **មានការខូចខាត ឬខូចប្រយោជន៍** : ដើម្បីអោយមេធាវីទទួលខុសត្រូវចំពោះខ្លួនបាន អតិថិជនត្រូវបង្ហាញអោយឃើញពីការខូចប្រយោជន៍របស់ខ្លួន។ បើគ្មានការខូចប្រយោជន៍ ក៏មិនអាចអោយមេធាវី ទទួលខុសត្រូវណាមួយបានដែរ ។

- **មានចំណងទាក់ទងរវាងកំហុស និងការខូចប្រយោជន៍** : ការខូចប្រយោជន៍ត្រូវតែចេញដោយផ្ទាល់ ពីកំហុសរបស់មេធាវី ពោលគឺការខូចប្រយោជន៍ចេញពីលទ្ធផល នៃកំហុស ។ បើសិនជាការខូចប្រយោជន៍នេះមិនមែនចេញពីកំហុសនេះទេ នោះមេធាវីក៏មិនត្រូវទទួលខុសត្រូវដែរ ។

### ២.២.៣. ទំនួលខុសត្រូវផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌ

ទង្វើរបស់មេធាវី ដែលមានកំហុសឆ្គងផ្នែកវិជ្ជាជីវៈ តំរូវអោយមេធាវីទទួលខុសត្រូវចំពោះអតិថិជនពីរយ៉ាង៖

**ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី៖** ក្នុងករណីដែលមេធាវីណាម្នាក់ធ្វើការងារដោយធ្វេសប្រហែស ដែលបណ្តាលអោយមានការខូចខាតប្រយោជន៍របស់អតិថិជន មេធាវីនោះ ត្រូវប្រឈមមុខនឹងការទទួលខុសត្រូវសងសំណងរដ្ឋប្បវេណី លើការខូចខាតនោះ។ មេធាវីនោះអាចត្រូវអតិថិជនខ្លួនប្តឹងទៅគណៈមេធាវី និងទៅតុលាការរដ្ឋប្បវេណីដើម្បីទាមទារសំណងអន្តរាយ ដែលខ្លួនទទួលរងដោយសារកំហុសរបស់មេធាវីរូបនោះ ។ ហេតុដូចនេះហើយ បានជាច្បាប់តំរូវអោយមេធាវីម្នាក់ៗបង់ប្រាក់ធានារ៉ាប់រង ការទទួលខុសត្រូវរបស់ខ្លួនក្នុងវិជ្ជាជីវៈ ។

**ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ៖** ក្នុងការប្រកបវិជ្ជាជីវៈ របស់ខ្លួនមេធាវី ត្រូវប្រឈមមុខនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្នុងករណីដែលមេធាវីរំលោភលើការសំងាត់នៃវិជ្ជាជីវៈមេធាវី ។ ដូចដែលមាត្រា ៧៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បានចែងកំណត់ច្បាស់ថា “ ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ៥៨ ( មាត្រាចែងពាក់ព័ន្ធនឹងការសំងាត់នៃវិជ្ជាជីវៈមេធាវី) ត្រូវផ្តន្ទាទោសតាមបទបញ្ញត្តិ នៃ ច្បាប់ព្រហ្មទណ្ឌ “ ។

**គួរកត់សំគាល់ថា** នៅក្នុងច្បាប់ព្រហ្មទណ្ឌ ដែលកំពុងអនុវត្តសព្វថ្ងៃនេះជាពិសេស ច្បាប់ព្រហ្មទណ្ឌអន្តរកាលមិនមានមាត្រាណាមួយចែងពី បទល្មើសស្តីពីការរំលោភលើការសំងាត់វិជ្ជាជីវៈទេ។ ដូចនេះ នៅពេលបច្ចុប្បន្នមិនមានមាត្រាច្បាប់ណាមួយផ្តន្ទាទោសលើជនដែលប្រព្រឹត្តបំពានការសំងាត់វិជ្ជាជីវៈមេធាវីទេ គឺបានត្រឹមតែដាក់ទណ្ឌកម្មផ្នែករដ្ឋបាលប៉ុណ្ណោះ។

## ២.៣. ទំនួលខុសត្រូវចំពោះគណៈមេធាវី

### ២.៣.១. កាតព្វកិច្ចបង់ភាគទាន

មេធាវីគ្រប់រូប ដែលជាសមាជិកគណៈមេធាវី ត្រូវមានកាតព្វកិច្ចបង់ភាគទានជូនគណៈមេធាវី ជារៀងរាល់ត្រីមាស ដើម្បីគណៈមេធាវីយកថវិកាទេទៅបំរើកិច្ចការរដ្ឋបាលរបស់គណៈមេធាវី ។ គណៈមេធាវីជា ស្ថាប័នមួយឯករាជ្យទាំងការគ្រប់គ្រងរដ្ឋបាល និងស្វយ័តហិរញ្ញវត្ថុ ដែលចំណូលរបស់ខ្លួនបានមកពីភាគទានរបស់សមាជិកនិងប្រាក់អំណោយរបស់សប្បុរសជន រាជរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ ។ គណៈមេធាវីជាអង្គការមិនធ្វើកម្មភាពរកកំរៃទេ ។ មកទល់បច្ចុប្បន្ននេះ គណៈមេធាវីបានចំណូលទាំងស្រុងពីភាគទានរបស់សមាជិករបស់ខ្លួនដែលត្រូវមានកាតព្វកិច្ចបង់ជារៀងរាល់ត្រីមាស ( បីខែ) ចំនួន ៣០ ដុល្លារ ( សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវីនាសម័យប្រជុំថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០០៦) ដែលកាលពីមុនគឺ ៣ខែ ៥០ ដុល្លារអាមេរិក។ សមាជិកណាខកខានមិនបានបង់ភាគទានចំនួន ២ ត្រីមាសឡើងទៅ នឹងត្រូវទទួលរងទណ្ឌកម្មហាមឃាត់មិនអោយប្រកបវិជ្ជាជីវៈ មួយរយៈពេលមិនអោយលើសពី ២ ឆ្នាំ ។ ក្នុងរយៈពេលហាមឃាត់នេះ៖ មេធាវី

ដែលទទួលរងទណ្ឌកម្មនេះៈនឹងត្រូវនៅជាប់ កាតព្វកិច្ចបង់ភាគទានដដែល ។ ការសុំចូលប្រកបវិជ្ជាជីវៈវិញ មេធាវីនេះ ត្រូវជំរះបាក់បំណុលរបស់គណៈមេធាវីអោយអស់សិន ។

### ២.៣.២. ភាតព្វកិច្ចការពារក្តីជូនជនក្រីក្រ

មេធាវីទាំងអស់ ដែលជាសមាជិករបស់គណៈមេធាវី ត្រូវមានកាតព្វកិច្ចការពារក្តីជូនជនក្រីក្រ តាមបែបបទ នៃបទបញ្ជាផ្ទៃក្នុង ហើយអោយដូចជាការជួយការពារអតិថិជនរបស់ខ្លួន ។ មេធាវី ដែលត្រូវបានចាត់តាំងអោយជួយការពារជនក្រីក្រ ត្រូវទទួលបាននូវប្រាក់ឧបត្ថម្ភ ឬប្រាក់សោហ៊ុផ្សេងៗដូចជាសោហ៊ុយស្នាក់នៅសោហ៊ុយធ្វើដំណើរ និងសោហ៊ុយអាហារ។ បន្ទុកនៃការចំណាយទាំងនេះត្រូវស្ថិតនៅក្នុងបេឡាពិសេស ដែលបានមកពីអំណោយ ឬប្រាក់ជំនួយ ដែលឯកជន អង្គការអន្តរជាតិ ឬរដ្ឋាភិបាល នៃប្រទេសផ្សេងៗ ផ្តល់មកអោយ ដើម្បីការពារជនក្រីក្រ ។

ដែលហៅថា ជនក្រីក្រ គឺជន ដែលគ្មានទ្រព្យសម្បត្តិ គ្មានប្រាក់ចំណូល ឬ ដែលមានប្រាក់ចំណូលមិនគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់ជីវភាព ។ ការកំណត់អំពីភាពក្រីក្រ ត្រូវធ្វើឡើងដោយប្រធានតុលាការ និងក្រឡាបញ្ជីនាយកក្រោយពីបានធ្វើការស៊ើបអង្កេតដល់មូលដ្ឋាន ។

មេធាវីស្ម័គ្រចិត្តត្រូវបំពេញការងារអោយអស់ពីសមត្ថភាព ដើម្បីជួយការពារក្តីជូនអតិជន ដែលចាត់តាំងដោយប្រធានគណៈមេធាវី ។ ក្នុងករណីដែលមេធាវីរូបនេះ មិនបានបំពេញកិច្ចការចាំបាច់តាមដំណើរការនីតិវិធីដែលត្រូវប្រព្រឹត្តទេ ប្រធានគណៈមេធាវី អាចនឹងដកឈ្មោះចេញពីបញ្ជីមេធាវីស្ម័គ្រចិត្ត ហើយអាចនឹងចោទប្រកាន់ពីបទវិន័យដល់មេធាវីនោះផង ។

### ២.៣.៣. ភាតព្វកិច្ចចំពោះក្រុមប្រឹក្សាគណៈមេធាវី និងប្រធានគណៈមេធាវី

មេធាវីម្នាក់ៗជាអ្នកទទួលខុសត្រូវចំពោះកេរ្តិ៍ឈ្មោះរបស់គណៈមេធាវីចំពោះ ឬទ្ធិអំណាច របស់ប្រធានគណៈមេធាវី និងអំពីប្រសិទ្ធិផល នៃក្រុមប្រឹក្សាគណៈមេធាវី ។ មេធាវី ត្រូវទទួលរ៉ាប់រង ដោយរវាសរវៃ និងហ្មត់ចត់នូវបេសកកម្ម និងសេវារួម ដែលបានប្រគល់អោយដោយគណៈមេធាវី ។

មេធាវី ដែលត្រូវគេប្តឹងអំពីកំហុស ឬ អំពីបទព្រហ្មទណ្ឌ ដែលទាក់ទិននឹងការប្រកបវិជ្ជាជីវៈ ឬ ដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈ ត្រូវអោយដំណឹងភ្លាមទៅប្រធានគណៈមេធាវី ។ មេធាវី ត្រូវឆ្លើយតបទៅនឹងការសុំទាំងឡាយ ឬអធិបញ្ញាទាំងឡាយរបស់ប្រធានគណៈមេធាវី ឬ ប្រតិភូរបស់ប្រធានគណៈមេធាវីដោយគ្មានបង្អែបង្អង់ ។

### ២.៣.៤. បទវិន័យ

មេធាវីទាំងឡាយណា ដែលប្រព្រឹត្តល្មើសនឹងវិធាន នៃវិជ្ជាជីវៈ និងគោលការណ៍ទាំងឡាយ នៃសច្ចាប្រណិធានរបស់ខ្លួន ដូចជាការមិនគោរពនូវច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បទបញ្ជាផ្ទៃក្នុង នៃគណៈមេធាវី និងក្រមសីលធម៌នៃមេធាវី នឹងត្រូវទទួលរងនូវការចោទប្រកាន់ពីបទវិន័យ និងទទួលទណ្ឌកម្មវិន័យ ពីក្រុមប្រឹក្សាគណៈមេធាវី ។ចំពោះមេធាវី ដែលប្រព្រឹត្តល្មើសនឹងការសំងាត់វិជ្ជាជីវៈ នឹងប្រឈមមុខនឹងបទវិន័យផង ទោសព្រហ្មទណ្ឌផង។នឹងត្រូវទទួលទណ្ឌកម្មវិន័យដែរ ចំពោះមេធាវីណា ដែលប្រព្រឹត្តអំពើណា ដែលប៉ះពាល់ដល់សីលធម៌ ឬ កិត្តិយសមេធាវី ទោះបីប្រព្រឹត្តក្រៅពីការប្រកបវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ។ ការចោទប្រកាន់ និងការដាក់វិន័យត្រូវធ្វើដោយក្រុមប្រឹក្សាគណៈមេធាវីខ្លួនឯងដែលមាននីតិវិធីក្នុងមាត្រា ៦០ ៦១ និង ៦២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។ ទណ្ឌកម្មជាបទវិន័យមានដូចតទៅ៖

- ការព្រមាន
- ការស្តីបន្ទោស
- ការហាមឃាត់ប្រកបវិជ្ជាជីវៈមេធាវីមួយរយៈ ដែលពុំអាចលើសពី ២ ឆ្នាំ
- ការលុបឈ្មោះចោលពីបញ្ជី នៃគណៈមេធាវី ឬ ពីបញ្ជី នៃមេ ធាវីកម្មសិក្សា ឬការហូតងារកិត្តិយស ។
- ចំពោះទណ្ឌកម្មទាំងនេះ៖ ទណ្ឌកម្មហាមរត់ប៊ុនអោយកបវិជ្ជាជីវៈមេធាវី ក្រុមប្រឹក្សាអាចសំរេច ព្យួរ
- បានដោយទុកពេលអោយសាកល្បងក្នុងរយៈពេល ៥ ឆ្នាំ ៖ មាត្រា ៦៤ នៃច្បាប់លក្ខន្តិកៈមេធាវី) ។
- គ្រប់ទណ្ឌកម្មទាំងអស់ ក្រុមប្រឹក្សាអាចសំរេចបន្ថែមទណ្ឌកម្មហាមឃាត់មិនអោយបំពេញជាប្រធាន
- ឬជាសមាជិកក្រុមប្រឹក្សាគណៈមេធាវី ក្នុងរយៈពេលមិនអោយលើសពី ៥ ឆ្នាំ ។ ហើយអាចសំរេចថា
- ត្រូវផ្សាយជាសាធារណៈ ផងដែរ ។

## ២.៤. ការធានារ៉ាប់រងវិជ្ជាជីវៈមេធាវី

មេធាវីត្រូវបង្ហាញថាខ្លួនបានបង់ប្រាក់ធានារ៉ាប់រងតាមរយៈគណៈមេធាវី សំរាប់ធានារ៉ាប់រងការទទួលខុសត្រូវក្នុងវិជ្ជាជីវៈ និងធានារ៉ាប់រងការសងមូលនិធិ និងរបស់មានតំលៃទាំងឡាយ ដែលខ្លួនបានទទួលបន្ទុក ។ ប្រាក់ធានានេះត្រូវគិតបញ្ចូលក្នុងប្រាក់បង់ភាគទាន ដែលកំណត់ដោយគណៈមេធាវី ។

មេធាវី ត្រូវមានគណនេយ្យវិជ្ជាជីវៈមួយដោយឡែកពីគណនេយ្យផ្ទាល់ខ្លួន ។ ការទទូទាត់ ប្រើមូលនិធិ ឬវត្ថុបញ្ញើ ត្រូវធ្វើឡើងក្នុងគណនេយ្យមួយដោយឡែក ។

មេធាវីត្រូវបង្ហាញបញ្ជីគណនេយ្យវិជ្ជាជីវៈរបស់ខ្លួន និងត្រូវបង្ហាញបញ្ជីគណនេយ្យផ្ទាល់ខ្លួន ប្រសិនបើមាន ដល់អ្នកត្រួតពិនិត្យ ចាត់តាំងឡើងដោយក្រុមប្រឹក្សាគណៈមេធាវី ។

ការដែលកំណត់អោយមានការបង់ប្រាក់ធានារ៉ាប់រង និងមានគណនេយ្យវិជ្ជាជីវៈដោយឡែក គឺដើម្បីធានានូវផលប្រយោជន៍របស់អតិថិជន និងជាពិសេសពេលមានការធ្វេសប្រហែសកើតឡើង គេអាចទូទាត់សំណងតាមរយៈ ក្រុមហ៊ុនធានារ៉ាប់រង ។

# ជំពូកទី៥

# តួនាទី និងការទទួលខុសត្រូវរបស់សារការី

## ផ្នែកទី១ ៖ តួនាទីរបស់សារការី

### ១.១. សញ្ញាណទូទៅទាក់ទង និងវិជ្ជាជីវៈសារការី

វិជ្ជាជីវៈសារការី នេះមានភាពស្រដៀងគ្នាច្រើនទៅ នឹងវិជ្ជាជីវៈមេធាវី ក៏ប៉ុន្តែសារការីជាមន្ត្រីសារធារណៈ ដែលទទួលអំណាចសាធារណៈពីរដ្ឋដើម្បីផ្តល់យថាភូតភាព ដល់រាល់លិខិតគតិយុត្ត ហើយ សារការីពុំទទួល បានប្រាក់ខែ ឬ ទទួលបានប្រាក់ឧបត្ថម្ភជំនួយពីរដ្ឋឡើយ ប៉ុន្តែត្រូវនៅក្រោមការត្រួតពិនិត្យ និងការដាក់ពិន័យពីរដ្ឋ។ ប៉ុន្តែសារការីជាអ្នកប្រកបវិជ្ជាជីវៈសេរីដោយអនុវត្តសកម្មភាពរបស់ខ្លួនក្នុងក្របខណ្ឌមន្ទីរសារការី និងទទួល បានកម្រៃពីសេវាសារការី ហើយសេវាកម្មមួយចំនួនរបស់សារការីរួមមានដូចជា៖ ផ្តល់យថាភូតភាព និងធ្វើការ បញ្ជាក់ (ហត្ថលេខា ឬស្នាមមេដៃ សេចក្តីចម្លងតាមច្បាប់ដើម) លើឯកសារគតិយុត្ត និងកិច្ចសន្យានានា ផ្តល់ យថាភូតលើកិច្ចសន្យាផ្ទេរសិទ្ធិកម្មសិទ្ធិ ផ្តល់យថាភូតភាពលើឯកសារកម្ចី និងឯកសារប្រតិភោគលើអចលនវត្ថុ អាពាហ៍ពិពាហ៍ជាមួយជនបរទេស សុំកូន កិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ ប្រទានកម្ម និងមរតក សាសន៍(បណ្តាំមត៌ក) ព្រមទាំងរក្សាទុកច្បាប់ដើមនៃបណ្តាំមត៌ក ការជម្រះបញ្ជី និងបែងចែកទ្រព្យនៅពេល លែងលះ និងពេលចាប់ផ្តើមសន្តតិកម្ម(មរណភាព) ការចុះបញ្ជីក្រុមហ៊ុន និងនីតិបុគ្គលផ្សេងទៀត ការបកប្រែ ភាសាពីភាសាបរទេសមកភាសាខ្មែរ និងពីភាសាខ្មែរទៅភាសាបរទេសដែលមានបញ្ជាក់ដោយសារការី និង ចេញច្បាប់ចម្លងនៃលិខិតយថាភូត។ល។[36]

ម៉្យាងវិញទៀត ដោយយោងទៅតាមសទ្ទានុក្រម ផ្នែករដ្ឋប្បវេណី នៅឆ្នាំ ២០០៧ ពាក្យថាសារការី មាន ន័យថា មន្ត្រីសាធារណៈ ដែលមានមុខងារធ្វើលិខិតយថាភូតបញ្ជាក់អំពីលក្ខណៈ ពិតប្រាកដត្រឹមត្រូវ ធានា រ៉ាប់រងអំពីកាលបរិច្ឆេទតម្កល់ រក្សាទុក និងចេញសេចក្តីចម្លងយថាភូតនៃលិខិតទាំងឡាយណាដែលត្រូវតែឲ្យ មានការបញ្ជាក់។[37]ចំណែកឯតួនាទី និងភារកិច្ចរបស់សារការី ក៏មានការកំណត់នៅក្នុងអនុក្រឹត្យស្តីពី ការទទួល

[36] សូមបញ្ជាក់ថាខ្លឹមសារនៃសេវាកម្មដែលមានការរៀបរាប់ខាងលើ មានកំណត់ក្នុង ក្រមរដ្ឋប្បវេណី ២០០៧ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦ និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ២០១១ នៃព្រះរាជាណាចក្រកម្ពុជា។

[37] សទ្ទានុក្រម ផ្នែករដ្ឋប្បវេណី នៅឆ្នាំ ២០០៧ ទំព័រទី ២២

ស្គាល់មន្ទីរសារការី នៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះខ្ញុំសូមលើកយកការកំណត់នៅតួនាទី និងភារកិច្ចនៅក្នុង អនុក្រឹត្យ ស្តីពី ការបង្កើតមន្ទីសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជាមកបង្ហាញ ។

តួនាទី និងភារកិច្ចរបស់សារការី ដែលបានកំណត់នៅក្នុងមាត្រា៤ របស់មន្ទីសារការីមេគង្គនោះ មានដូចត ទៅ៖

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្ត ទាំង ឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និង ការគ្រប់គ្រងចាត់ចែងទ្រព្យ សម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាព ចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និង នីតិបុគ្គលគ្រប់ប្រភេទ
- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយ តាមច្បាប់តម្រូវ ឬតាម ការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឱ្យស្ថាប័នអនុវត្តធ្វើការនុវត្តដោយបង្ខំនូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបានយថាភូតភាព ពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានាតាមច្បាប់តម្រូវ ឬ តាមស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ធានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ធ្វើសំណើចុះបញ្ជី ឬចុះលេខាចារឹកទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯតោភាគីផ្សេងៗ មតកសាសន៍
- និងលិខិតស្នាមគ្រប់ប្រភេទចេញច្បាប់ចម្លងនៃលិខិតយថាភូត
- និង ទទួលធ្វើកិច្ចការផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមានជាដើម។

តាំងពីមានការបង្កើតឲ្យមានការបណ្តុះបណ្តាលវិជ្ជាជីវៈមកឃើញមានបេក្ខជនជាច្រើនចាប់អារម្មណ៍វិជ្ជា ជីវៈសារការីនិងដាក់ពាក្យប្រលងរហូតទទួលបានមុខងារជាសារការីជាច្រើនរូបដែលជួយជម្រុញឲ្យមានកំណើន ច្រើននៃសារការីដើម្បីចូលរួមចំណែកក្នុងការពង្រឹងវិស័យយុត្តិធម៌តាមរយៈការបម្រើសេវាកម្មដែលបានរៀបរាប់ ខាងលើ ក្នុងគោលបំណងធានាការពារអ្នកវិនិយោគទុន អ្នកជំនួញ ពាណិជ្ជករ និងពលរដ្ឋគ្រប់ៗរូបឱ្យជៀសផុត ពីជម្លោះទៅតុលាការពីការកេងប្រវ័ញ្ច ការក្លែងបន្លំ ការឆបោក និងអំពើទុច្ចរិតគ្រប់យ៉ាងដែលអាចកើតមានឡើង

នៅក្នុង កិច្ចសន្យាលក់ដូរ ទិញ ជួល បញ្ចាំ ហ៊ីប៉ូតែក និងមតកសាសន៍ ឱ្យស្របតាមទម្រង់បែបបទជាយថាភូត។ ដើម្បីឲ្យយល់កាន់តែច្បាស់អំពីតួនាទី និងភារកិច្ចរបស់សារការី យើងសូមបកស្រាយនៅក្នុង**ផ្នែក**( **១.២. តួនាទីរបស់សារការី** )។

## ១.២. តួនាទីរបស់សារការី

### ១.២.១. តួនាទីតាក់តែងលិខិតយថាភូត

តួនាទីចម្បងរបស់សារការីគឺតាក់តែងលិខិតយថាភូត។ បើយោងទៅតាមសេចក្តីព្រាងច្បាប់សារការី ដែលមិនទាន់បានអនុម័តដាក់ឲ្យប្រើប្រាស់នៅឡើយនោះ បានបញ្ជាក់ថា លិខិតសារការីរួមមាន លិខិតយថាភូត និងលិខិតបញ្ជាក់ ដែលលិខិតទាំងពីនេះមានអនុភាពខុសគ្នាត្រង់ថា លិខិតយថាភូតជាលិខិតអនុវត្ត ចំណែកឯលិខិតបញ្ជាក់របស់សារការីមិនអាចអនុវត្តបានទេ។

លិខិតយថាភូត គឺជាលិខិតដែលធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈដែលត្រូវបាន អនុញ្ញាតឲ្យប្រតិបត្តិមុខងារនេះ។ បើតាមន័យចង្អៀត លិខិតយថាភូតជាលិខិតទាំងឡាយដែលរៀបចំឡើង ដោយសារការី។[38] លិខិតយថាភូត សម្តៅទៅលើលិខិតដែលកំណត់នៅក្នុងមាត្រា៣៣៦ (ការបង្កើតកិច្ចសន្យា ដោយសំណើរ និងស្នើការ), មាត្រា៥១៦ (ការបង្កើតកិច្ចសន្យាលក់ទិញ) និងមាត្រា៨៦២ (អានុភាពនៃការ ចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី ដែលជាលិខិតដែលត្រូវធ្វើឡើងដោយសារការី ឬលិខិតឯកជនដែលសារ ការីចុះនិទ្ទេសថាលិខិតនោះមានភាពត្រឹមត្រូវច្បាប់ និងការចុះកាលបរិច្ឆេទ និងហត្ថលេខាក្រោយពេលខ្លួន បញ្ជាក់ថា លិខិតនេះមានភាពត្រឹមត្រូវតាមច្បាប់។ ប៉ុន្តែ ចំពោះលិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើរ និងស្នើការ) និងមាត្រា ៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រម រដ្ឋប្បវេណី លិខិតដែលមានមន្ត្រីមានសមត្ថកិច្ចធ្វើឡើង ដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជីក៏ជាលិខិតយថាភូតដែរ។

ចំណែកឯ លិខិតយថាភូតដែលកំណត់នៅក្នុងមាត្រា ៨៤៥ (ការតតាំងនៃហ៊ីប៉ូតែក)នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី។ បន្ថែមពីនេះទៀត លិខិត យថាភូតដែលកំណត់នៅក្នុងមាត្រា ១១៧២ (បុគ្គលដែលមិនអាចក្លាយជាសក្សីជាអាទិ៍) មាត្រា ១១៧៣ (មរតកសាសន៍ដោយលិខិតយថាភូត) និងមាត្រា១១៨១(បទប្បញ្ញត្តិពិសេសចំពោះមរតកសាសន៍របស់ជន

[38]សទ្ទានុក្រមផ្នែករដ្ឋប្បវេណីនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ទំព័រទី១៩

ជាតិខ្មែរដែលរស់នៅបរទេស) នៃក្រុមរដ្ឋប្បវេណីសំដៅទៅលើលិខិតដែលត្រូវបានធ្វើឡើងដោយសារការី ឬ កុងស៊ុលតាមបញ្ញត្តិនៃមាត្រានីមួយៗខាងលើនេះ។[39]

សូមបញ្ជាក់ថាលិខិតគតិយុត្តឬកិច្ចសន្យាដែលបានរៀបរាប់ខាងលើនេះគឺ ត្រូវធ្វើឡើងក្រោមទម្រង់ជាលិខិតយថាភូតដោយសារការី។ ហេតុដូច្នេះ យើងខ្ញុំនិងរៀបរាប់បញ្ជាក់ប្រភេទនៃលិខិតគតិយុត្តរបស់សារការីដោយផ្អែកទៅតាមច្បាប់ដែលមានចែងពីសមត្ថកិច្ចផ្តាច់មុខរបស់វិជ្ជាជីវៈសារការី ដែលចាំបាច់ធ្វើឡើងក្រោមទម្រង់ជាលិខិតយថាភូតដោយសារការីនៅដូចខាងក្រោម៖

រាល់កិច្ចសន្យាដែលមានកម្មវត្ថុធ្វើអនុប្បទាន ឬធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ ជាអាទិ៍។ កិច្ចសន្យា ដែលមានកម្មវត្ថុធ្វើអនុប្បទាន ឬធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុមានដូចជា ការលក់ទិញអចលនវត្ថុ៦៤, ការដូរអចលនវត្ថុ៦៥, ប្រទានកម្មអចលនវត្ថុ៦៦, កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន ដែលមានកម្មវត្ថុធ្វើអនុប្បទាន ឬធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ, នវកម្មដែលមានកម្មវត្ថុធ្វើអនុប្បទាន ឬធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ, កិច្ចសន្យាក្រុមហ៊ុនដែលមានកម្មវត្ថុធ្វើអនុប្បទាន ឬធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ, លក្ខន្តិកៈក្រុមហ៊ុនដែលមានការដាក់ភាគទុនជាអចលនវត្ថុ, កិច្ចសន្យាធនលាភសាមយិកមួយជីវិតដែលមានកម្មវត្ថុជាអចលនវត្ថុ, ការសះជាដែលមានកម្មវត្ថុជាការផ្ទេរអចលនវត្ថុ, កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលមានកម្មវត្ថុ ឬមានការដាក់ជាទ្រព្យរួមនូវអចលនវត្ថុជាដើម។

រាល់កិច្ចសន្យាដែលមានកម្មវត្ថុជាប្រាតិភោគប្រត្យក្សលើអចលនវត្ថុ ជាអាទិ៍។ កិច្ចសន្យាដែលមានកម្មវត្ថុជាប្រាតិភោគប្រត្យក្សលើអចលនវត្ថុ មានដូចជា កិច្ចសន្យាបញ្ចាំអចលនវត្ថុ, កិច្ចសន្យាពាក់ពន្ធ នឹងការចាត់ចែងការបញ្ចាំអចលនវត្ថុ រួមមាន ការបញ្ចាំបន្ត អនុប្បទាននូវការបញ្ចាំ ការបោះបង់នូវការបញ្ចាំ ការបោះបង់លំដាប់នៃការបញ្ចាំ, កិច្ចសន្យាបង្កើតហ៊ីប៉ូតែក, កិច្ចសន្យាពាក់ព័ន្ធនឹងការចាត់ចែងហ៊ីប៉ូតែក រួមមាន ហ៊ីប៉ូតែកបន្ត អនុប្បទាននូវហ៊ីប៉ូតែក ការបោះបង់នូវហ៊ីប៉ូតែក ការបោះបង់លំដាប់នៃហ៊ីប៉ូតែក និងការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែកជាអាទិ៍។

រាល់លិខិតឯកតោភាគីដែលមានកម្មវត្ថុជាកាចាត់ចែងទ្រព្យក្រោយមរណភាពុំ។ លិខិតឯកតោភាគីដែលមានកម្មវត្ថុជាកាចាត់ចែងទ្រព្យក្រោយមរណភាពមានដូចជា មតកសាសន៍ដោយលិខិតយថាភូត, មតក

[39]មាត្រា៩ នៃច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី ២០១១

សាសន៍ដោយលិខិតយថាភូតនៃបុគ្គលដែលមិនអាចនិយាយបាន, អច្ច័យទានដែលមានកម្មវត្ថុជាអចលនវត្ថុជាដើម។

### ១.២.១.១. ការតាក់តែងលិខិតមតកសាសន៍

ដើម្បីឲ្យអ្នកអានងាយយល់កាន់តែច្បាស់នោះ យើងខ្ញុំសូមលើកយកមតកសាសន៍ជាលិខិយថាភូតមកបង្ហាញ ថ្វីបើក្នុងពេលបច្ចុប្បន្ននេះដោយសារច្បាប់សារការីមិនទាន់បានអនុម័តនៅឡើយ ដូចនេះ ចំពោះទម្រង់នៃលិខិតយថាភូតមិនត្រូវបានកំណត់យកគោលការណ៍ណាមួយដើម្បីយកមកអនុវត្តនោះទេ ប៉ុន្តែ បើយោងទៅតាមសន្ទានុក្រមចំណុច១១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានកំណត់និងចែងថា “មតកសាសន៍ គឺជាលិខិតបណ្តាំ ដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ ដែលបានកំណត់ដោយច្បាប់ ដើម្បីសំដែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍បន្ទាប់ពីមរណភាព” ។ មតកសាសន៍ គឺជាលិខិតបណ្តាំដែលមតកជនកាលនៅរស់បានធ្វើដើម្បីកំណត់ចំណែកមត៌ក ឬវិធីបែងចែកមត៌កទៅអោយសន្តតិជន ឬ អច្ច័យលាភី និងកំណត់អំពីបុគ្គលការតាក់តែងលិខិតស្នាម និងការបញ្ជាក់ពីភាពត្រឹមត្រូវនៃលិខិតរួមទាំងមតកសាសន៍ផងនោះគឺជាតួនាទីយ៉ាងសំខាន់របស់សារការី។ ដើម្បីឲ្យមានសុពលភាព មតកសាសន៍ត្រូវធ្វើឡើងដោយគោរពទៅតាមទម្រង់ដែលបានកំណត់ដោយក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ។

ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានកំណត់ និងបែងចែកអំពីទម្រង់ជាទូទៅនៃមតកសាសន៍ ជាបី ប្រភេទ គឺ មតកសាសាន៍ ជាលិខិតយថាភូត, មតកសាសសន៍ជាលិខិតសម្ងាត់ និងមតកសាសន៍ជាលិខិតឯកជន។ ដូច្នេះ ខ្ញុំសូមលើកយកមតកសាសន៍ជាលិខិយថាភូតមកបង្ហាញខាងនៅចំណុច (១.២.១.២ មតកសាសន៍ជាលិខិតយថាភូត)ខាងក្រោមនេះ។

### ១.២.១.២. មតកសាសន៍ជាលិខិតយថាភូត

តាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មាត្រា ១១៧៣ មតកសាសន៍ ជាលិខិតយថាភូត គឺជាមតកសាសន៍ដែលតាក់តែងឡើងដោយសារការីបន្ទាប់ពីមានការប្រាប់ដោយផ្ទាល់មាត់ពីសំណាក់ម្ចាស់បណ្តាំ ដោយមានការចូលរួមពីសាក្សី តាមការកំណត់តាមទម្រង់ដែលមានដូចខាងក្រោម៖

- ត្រូវមានវត្តមានសាក្សីយ៉ាងតិច ២នាក់ ។
- ម្ចាស់បណ្តាំត្រូវប្រាប់ដោយផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍ចំពោះសារការី។
- សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះជាលាយល័ក្ខណ៍ អក្សរ ហើយត្រូវសូត្រឲ្យម្ចាស់បណ្តាំ និងសាក្សីស្តាប់។

បន្ទាប់ពីម្ចាស់បណ្តាំ និងសាក្សីបានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខអក្សរនោះត្រឹមត្រូវហើយជននីមួយៗនោះត្រូវចុះហត្ថលេខា ដើម្បីបញ្ជាក់អំពីឈ្មោះ អាយុ និងលំនៅឋាន និងជាចុងក្រោយ សារការីត្រូវសរសេរថ្ងៃ ខែ ឆ្នាំ ហើយនឹងត្រូវចុះហត្ថលេខា។

### ១.២.១.៣. ការប្រឹក្សាយោបល់

ការប្រឹក្សាយោបល់ គឺជាការប្រាប់ពីទម្រង់ផ្លូវច្បាប់ដោយសារការីទៅម្ចាស់បណ្តាំនៅក្នុងការតាក់តែងមតកសាសន៍ដើម្បីកុំឲ្យមានការបំពានទម្រង់ច្បាប់ណាមួយ។ ហើយការប្រឹក្សាយោបល់នោះទៀតសោត សារការីត្រូវប្រាប់អំពីរបៀបនៃការបែងចែកទ្រព្យរបស់ ម្ចាស់បណ្តាំទៅសន្តតិជននិងអច្ច័យលាភីឲ្យបានច្បាស់លាស់ ដើម្បីកុំឲ្យមានការបំពានភាគបម្រុង ដែលជាមូលហេតុនាំឲ្យមានវិការៈនៃមតកសាសន៍។ សារការីត្រូវសិក្សាអំពីទ្រព្យសកម្ម និងទ្រព្យអកម្មរបស់ម្ចាស់បណ្តាំមុនធ្វើការតាក់តែងមតកសាសន៍។សារការី ជាការចាំបាច់ត្រូវតែជូនដំណឹងដល់ភាគីទាំងអស់អំពីធាតុសំខាន់ៗមួយចំនួនដែលចាំបាច់ដែលនឹងត្រូវធ្វើនៅក្នុងលិខិត ដែលជនានុជនមានបំណងនឹងធ្វើនោះ ចំពោះមុខខ្លួន ។ការប្រឹក្សារបស់សារការី គឺជាកាតព្វកិច្ចដែលត្រូវផ្តល់ឲ្យជនានុជននូវឱវាទ ឬការប្រឹក្សាយោបល់ដែលមានលក្ខណៈច្បាស់លាស់ ដោយគិតគូរពីផលប្រយោជន៍ដែលមានជូនដល់ជនានុជនទាំងអស់ដែរ ។ ករណីយកិច្ចរបស់សារការី គឺត្រូវបំភ្លឺឲ្យដំណឹង និងទូន្មានគូសញ្ញាអំពីលិខិតដែលអ្នកនេះបានធ្វើ ឬមានបំណងចង់ធ្វើ ហើយដោយខ្លួនជាមន្ត្រីសាធារណៈត្រូវពិនិត្យឲ្យដឹងថា សេចក្តីកំណត់ចុះក្នុងលិខិតទាំងនោះត្រឹមត្រូវតាមការពិត។

ក្នុងការអនុវត្តជាក់ស្តែងការតាក់តែងលិខិតគតិយុត្ត ឬ លិខិតយថាភូត ផ្សេងៗ រួមទាំងមតកសាសន៍ជាលិខិតយថាភូតផងដែរ សារការីត្រូវធ្វើការប្រឹក្សាយោបល់ដល់ជនានុជន អំពីលិខិតស្នាមដែលបានស្នើសុំអោយធ្វើ សារការីមិនត្រឹមតែពន្យល់អំពីផលប្រយោជន៍ជូនដល់ជនានុជននោះទេ សារការីត្រូវពន្យល់អំពីផលប៉ះពាល់ រួមទាំងបញ្ហាផ្សេងៗដែលអាចទទួលយកបាន ឬកើតទៅថ្ងៃខាងមុខ ក្នុងការធ្វើមតកសាសន៍ ដើម្បីជៀសវាងការដែលមានបញ្ហាទៅពេលក្រោយ ដែលនឹងនាំអោយមានវិវាទ និងការខូចខាត ផ្សេងៗដែលអាចកើតឡើងដោយការភាន់ច្រលំ ការធ្វើសប្រហែសក្នុងការតាក់តែង។

### ១.២.១.៤. ការតាក់តែង

បើយើងក្រលែកទៅមើលបញ្ញត្តិស្តីពីមតកសាសន៍ មានបញ្ញត្តិជាច្រើន បាននិយាយពីទម្រង់នៃលិខិតមតកសាសន៍។ ប៉ុន្តែសូមលើឡើងនៅបញ្ញត្តិមួយចំនួនដែលពាក់ព័ន្ធសារការីមកនិយាយមតកសាសន៍ជាលិខិតយថាភូត គឺជាមតកសាសន៍ដែលតាក់តែងឡើងដោយសារការីផ្ទាល់ហើយត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅ

ចំពោះសារការី ដោយម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍ចំពោះសារការី ហើយសារការីត្រូវសរសេរនូវអត្ថបទនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឲ្យម្ចាស់បណ្តាំ និងសាក្សីពីរនាក់ស្តាប់ នៅពេលដែលសារការីតាក់តែងមតកសាសន៍ជាលិខិតយថាភូតសារការីត្រូវគិតដល់ភាគបម្រុង ទ្រព្យសម្បត្តិសន្តតិជន ការកំណត់នូវចំណែក និងវិធីនៃការបែងចែកមត៌ក។ សារការីត្រូវសរសេរផងដែរនូវអច្ច័យទានទៅសន្តតិជន ឬតតិយជន ហើយព្រមទាំងកំណត់អភ័ព្វបុគ្គលនៃសន្តតិកម្ម មានការយល់ព្រមទទួល និងបោះបង់សន្តតិកម្ម ក្រៅពីនេះអាចជាការផ្តាច់មត៌កប្រសិនបើមាន។បន្ថែមទៀត សារការីក៏ត្រូវកំណត់អំពីបុគ្គលជាអ្នកទទួលបន្ទុកប្រតិបត្តិមតកសាសន៍ផងដែរប្រសិនបើម្ចាស់បណ្តាំបាន បង្ហាញឆន្ទៈ។

### ១.២.១.៥. ការចុះហត្ថលេខារបស់ម្ចាស់បណ្តាំ

ក្រោយពីបានតាក់តែងរួចហើយ សារការីត្រូវអានមតកសាសន៍នោះចំពោះម្ចាស់បណ្តាំ និងសាក្សីចំនួនពីររូប។ ក្រោយពីម្ចាស់បណ្តាំទទួលស្គាល់ថា មតកសាសន៍ដែលសារការីបានតាក់តែងមានភាពត្រឹមត្រូវហើយម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើមតកសាសន៍។ការចុះហត្ថលេខារបស់ម្ចាស់បណ្តាំ គឺជាលក្ខខណ្ឌចាំបាច់ក្នុងការដើម្បីបញ្ជាក់ពីភាពពិតប្រាកដនៃភាពត្រឹមត្រូវនៃមតកសាសន៍ បន្ទាប់ពីម្ចាស់បណ្តាំបានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវ។ ជាគោលបំណងនៃហត្ថលេខាគឺដើម្បីផ្តល់សច្ចានុមតិលើភាពត្រឹមត្រូវឈ្មោះ អាយុ ភេទ និងលំនៅឋាន រួមទាំងខ្លឹមសារនៃមតកសាសន៍ដែលត្រូវបានតាក់តែងដោយសារការីតាមរយៈការប្រាប់ផ្ទាល់មាត់ពីម្ចាស់បណ្តាំ ។ ហត្ថលេខានេះពុំអាចត្រូវបានជំនួសដោយស្នាមម្រាមដៃឡើយ ។ សារការីត្រូវពិនិត្យមើលលើការចុះហត្ថលេខារបស់ម្ចាស់បណ្តាំ នៅចំពោះមុខខ្លួនឲ្យបានត្រឹមត្រូវ។

### ១.២.១.៦. ការចុះហត្ថលេខារបស់សាក្សី

សាក្សី គឺជា ស្មរ ,បន្ទាល់ , បានដឹង បានលឺ បានឃើញ។ ដោយសារសាក្សីគឺជាបុគ្គលដែលសំខាន់នៅក្នុងការដឹងលឺ និងបានចូលរួមក្នុងការតាក់តែងលិខិតមតកសាសន៍ បន្ទាប់ពីសាក្សីបានទទួលស្គាល់ថាមតកសាសន៍ដែលសារការីបានតាក់តែងពិតជាត្រឹមត្រូវ សាក្សីត្រូវសរសេរឈ្មោះអាយុ ទីលំនៅ និង ចុងក្រោយ សាក្សីត្រូវធ្វើការចុះហត្ថលេខាលើមតកសាសន៍។

ចំពោះសាក្សីដែលនឹងចុះហត្ថលេខាលើមតកសាសន៍សារការីត្រូវពិនិត្យលើលក្ខណៈសម្បត្តិនៃបុគ្គលដែលនឹងធ្វើជាសាក្សី ដើម្បីឲ្យមានសភាពប្រាកដប្រជាថា បុគ្គលនោះមិនមែនជាសាក្សីដូចខាងក្រោម ៖

- អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលធម្មតា ។
- ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី ហើយ និងសហព័ទ្ធ និង ញាតិលោហិត

- ខ្សែផ្ទាល់ របស់ជនទាំងនោះ។

បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬជាលិខិតសម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និង និយោជិត របស់សារការី។[40]

### ១.២.១.៧. ការចុះហត្ថលេខារបស់សារការី

ហត្ថលេខា គឺជាការសរសេរឈ្មោះខ្លួនដោយដៃខ្លួនឯង តាមចំណាំដែលធ្លាប់តែសរសេររៀងមកយ៉ាងណាក៏ឲ្យទៅជាយ៉ាងនេះ។ មុននឹងសារការីចុះហត្ថលេខាលើលិខិតមតកសាសន៍សារការីត្រូវពិនិត្យមើលលើខ្លឹមសារនៃមតកសាសន៍ និងបានបញ្ជាក់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវ និងមានភាពច្បាស់លាស់។ បន្ទាប់មកសារការីត្រូវពិនិត្យទៅលើសាក្សីដែលបានចុះហត្ថលេខា មានសរសេរ ឈ្មោះ ភេទ អាយុ ត្រឹមត្រូវតាមក្រមរដ្ឋប្បវេណី។

ត្រា គឺជាប្រដាប់មានស្នាមចម្លាក់ជាគ្រឿងសម្គាល់សម្រាប់សម្គាល់លើសំបុត្រ, ចុតហ្មាយដីកា, បញ្ជី, សំបុត្រសន្យាផ្សេងៗតាមមុខងារ មុខក្រសួងបោះត្រា"។ ហើយត្រារបស់សារការីមានពីរប្រភេទ៖ ត្រាមន្ទីររបស់សារការី និង ត្រាឈ្មោះរបស់សារការីដែលបានបោះលើលិខិតនោះ ។[41]

ក្នុងករណីដែលសារការី ត្រូវបានចុះហត្ថលេខា សារការីគ្រាន់តែសរសេរនាមត្រកូល និងនាមខ្លួន និង ផ្តិតមេដៃជាការគ្រប់គ្រាន់ ហើយ"។

### ១.២.២.តួនាទីផ្តល់យថាភូតភាពនៃលិខិត

សារការីមានតួនាទី ផ្តល់នូវយថាភូតភាពនៃលិខិតគតិយុត្ត។ រាល់លិខិតគតិយុត្តដែលសារការីផ្តល់នូវយថាភូតភាពគឺត្រូវធ្វើឡើងក្រោមទម្រង់ជាលិខិតបញ្ជាក់ដោយសារការី តែមិនមែនជាលិខិតដែលអាចអនុវត្តបាន។

លិខិតបញ្ជាក់គឺជាលិខិតដែលសារការីផ្តល់នូវយថាភូតភាពចំពោះអត្តសញ្ញាណរបស់ភាគីដែលបានចុះហត្ថលេខាលើលិខិត ឬភាពត្រឹមត្រូវនូវច្បាប់ចម្លងទៅនឹងច្បាប់ដើមឬភាពត្រឹមត្រូវនៃការបកប្រែរបស់ឯកសារណាមួយ។ លិខិតបញ្ជាក់ មានអំណាចបន្ទាល់ និងកាលបរិច្ឆេទស្ថាពរ ប៉ុន្តែមិនមានជាលិខិតអនុវត្តទេ។ ហើយបើតាមការកំណត់នៃលិខិតគតិយុត្ត ដែលគួរតែ ត្រូវធ្វើឡើងក្រោមទម្រង់ជាលិខិតបញ្ជាក់ដោយសារការីមានដូច

---

[40] មាត្រា១១៧២ នៃក្រមរដ្ឋប្បវេណី២០០៧

[41] យោងតាមវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជជួនណាត

ជាៈលក្ខន្តិកៈនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត,ការកែប្រែលក្ខន្តិកៈនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត, លក្ខន្តិកៈនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត, ការកែប្រែលក្ខន្តិកៈនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត, លក្ខន្តិកៈនីតិបុគ្គលមូលនិធិ, មតកសាសន៍ដោយលិខិតសម្ងាត់,ឧបាទេសកម្មដោយការសង,អនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ, ការបញ្ចាំសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ, និងអនុប្បទានឋានៈក្នុងកិច្ចសន្យា ជាដើម។

សូមបញ្ជាក់ថា ក្នុងករណីដែលច្បាប់ ឬបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀតតម្រូវ លិខិតគតិយុត្តក្រៅពីលិខិតដូចបានរៀបរាប់ខាងលើនេះក៏ត្រូវធ្វើឡើងក្រោមទម្រង់ជាលិខិតសារការផងដែរ។ទោះបីមានបញ្ញត្តិនៃកថាខណ្ឌខាងលើក៏ដោយភាគីនៃលិខិតក៏អាចស្នើសុំឲ្យសារការីផ្តល់យថាភូតភាពឬធ្វើការបញ្ជាក់លើលិខិតគតិយុត្តផ្សេងទៀតបានដែរនេះជាការបញ្ជាក់ក្នុងសេចក្តីព្រាងច្បាប់សារការី។

### ១.២.៣. ឆានារ៉ាប់រងអំពីកាលបរិច្ឆេទ

សារការី មានសមត្ថកិច្ចធានាកាលបរិច្ឆេទនៃកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយ ធានាការចុះបញ្ជីកិច្ចសន្យា ឬលិខិតគតិយុត្តនៅស្ថាប័នដែលមានសមត្ថកិច្ចតាមការកំណត់របស់ច្បាប់ ធ្វើការរក្សាទុកកិច្ចសន្យា ឬលិខិតគតិយុត្ត និងផ្តល់នូវឯកសារចម្លងយថាភូត និងឯកសារចម្លងយថាភូតដែលភ្ជាប់នូវរូបមន្តអនុវត្តនៃកិច្ចសន្យា ឬលិខិតគតិយុត្តដែលខ្លួនបានទទួល និងរៀបចំតាក់តែង។

ការបញ្ជាក់ហត្ថលេខា និងកាលបរិច្ឆេទ ទៅលើឯកសារមួយចំនួនដែលជាលិខិតគតិយុត្តិ ឬក៏កិច្ចសន្យានោះ នាពេលបច្ចុប្បន្នមិនទាន់មានវិសាលភាពទូលំទូលាយនៅឡើយទេ។ ជាការពិតការបញ្ជាក់ហត្ថលេខាពិតជាមានសារសំខាន់ដែលជាពិសេសគឺត្រូវធ្វើនៅចំពោះមុខសារការី ដើម្បីឲ្យសារការីបញ្ជាក់ថាពិតជាត្រឹមត្រូវពិតប្រាដកមែន ដូចជាកិច្ចសន្យាមួយចំនួនដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នា និងធ្វើនៅចំពោះមុខសារការីហើយសារការីជាសាក្សីនិងបញ្ជាក់ទៅល្ើកិច្ចសន្យានោះ ដើម្បីឲកិច្ចសន្យាមានសុពលភាពក្នុងការអនុវត្ត។ ម្យ៉ាងទៀតចំពោះការបរិច្ឆេទ លិខិតឯកជនដែលសារការី ឬក្រឡាបញ្ជីតុលាការចុះនិទ្ទេសអំពីកាលបរិច្ឆេទដែលខ្លួនត្រូវបានបង្ហាញលិខិតឯកជននេះ និងចុះហត្ថលេខាក្នុងករណីនេះ កាលបរិច្ឆេទស្ថាពរ។[42]

---

[42] មាត្រា៨ច្បាប់ស្តីពីអនុវត្តក្រមរដ្ឋប្បវេណី លិខិតដែលមានកាលបរិច្ឆេទស្ថាពរ។

### ១.២.៤. តម្កល់រក្សាទុក

យោងតាមតាគ្រា៣ ចំណុច ខ នៃអនុក្រឹត្យលេខ ៥០៥ អនក្រ.តត. ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា គឺធ្វើការបញ្ជាក់លើការិយបរិច្ឆេទ ទទួលតម្កល់ទុកឯកសារ និងចេញឲ្យនូវសេចក្តីដើម ឬសេចក្តីចម្លងនៃលិខិត ឬកិច្ចសន្យាទាំងឡាយនោះតាមមុខការ និងយោងតាមមាត្រា៤ នៃអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីអង្គរ ក៏ដូចជាអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីផ្សេងៗទៀត បានចែងអំពីសមត្ថកិច្ចរបស់សារការីការតម្កល់ទុក និងរក្សាទុកឯកសារច្បាប់ដើមនៃលិខិតគតិយុត្ត និងកិច្ចសន្យា

ផ្សេងៗ។[43]

### ១.២.៥. ចេញសេចក្តីចម្លងយថាភូតនៃលិខិតដែលត្រូវឲ្យមានការបញ្ជាក់

កន្លងមកយើងបានសង្កេតថ្មើញថារដ្ឋបាលស្រុក ខណ្ឌ ខេត្ត ក្រុង មានសមត្ថកិច្ចក្នុងការបញ្ជាក់ច្បាប់ចម្លងនៃលិខិតយថាភូតផ្សេងៗ ដែលប្រជាពលរដ្ឋគ្រប់រូបបានដឹងថា ច្បាប់ចម្លងដែលបានបញ្ជាក់នោះមានសុពលភាព និងអាចប្រើប្រាស់បានតាមការកំណត់នៃច្បាប់។ ម៉្យាងទៀតបើយោងតាមមាត្រា៣ ចំណុចខ នៃអនុក្រឹត្យលេខ ៥០៥ អនក្រ.តត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងយោងតាមមាត្រា៤ នៃអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីអង្គរ ក៏ដូចជាអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីផ្សេងៗទៀត បានចែងអំពីសមត្ថកិច្ចរបស់សារការី ក្នុងការចេញច្បាប់ចម្លងនៃលិខិតយថាភូតផ្សេងៗផងដែរថា។ យោងតាមការចុះកម្មសិក្សាផ្ទាល់ បានសង្កេតឃើញពីការចេញច្បាប់ចម្លងនៃលិខិតយថាភូតនេះមានដូចជា អត្តសញ្ញាណប័ណ្ណ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុសាលក្រមសញ្ញាបត្រ នឹងលិខិតគតិយុត្តផ្សេងៗទៀត ដែលមានច្បាប់ដើម។ ជាក់ស្តែងមិនទាន់មានបញ្ញត្តិណាមួយដែលចែងឲ្យបានច្បាស់លាស់ ទៅលើសមត្ថកិច្ចផ្តាច់មុខក្នុងការចេញច្បាប់ចម្លងនៃលិខិតយថាភូត ដូចនេះហើយច្បាប់ចម្លងដែលបានចេញដោយសារការី និងមានសុពលភាពដូចគ្នាទៅនឹងច្បាប់ចម្លង ដែលបានបញ្ជាក់ដោយរដ្ឋបាលស្រុក ខណ្ឌ ខេត្ត ក្រុង ដែរ។នៅក្នុងផ្នែក (១.២.៣. អានុភាពនៃលិខិតយថាភូត)យើងខ្ញុំនិងបកស្រាយ

[43] មាត្រា៣ ចំណុចខ អនុក្រឹត្យលេខ ៥០៥ អនក្រ.តត.ស្តីពី ការផ្តល់សមត្ថកិច្ចបន្ថែមសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា៤ ចំណុច៥ អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសារការីអង្គរ

អំពីអានុភាពនៃលិខិតយថាភូតដើម្បីជៀសវាងមានការយល់ច្រឡំថា រាល់លិខិតយថាភូត សុទ្ធតែជាលិខិតអានុវត្តបាន។

## ១.៣. អានុភាពនៃលិខិតយថាភូត

### ១.៣.១. អំណាចបន្ទាល់

លិខិតសារការីមានអំណាចបន្ទាល់ មានន័យថា លិខិតសារការី គឺជាភ័ស្តុតាងដែលមានតម្លៃខ្ពស់ជាងគេ ដែលមានតម្លៃគតិយុត្តតាមផ្លូវច្បាប់ដែលត្រូវតែជឿ លើកលែងតែលិខិតនោះជាលិខិតក្លែងក្លាយ។ រាល់លិខិតសារការី ត្រូវចាត់ទុកថាត្រឹមត្រូវ ពិតប្រាកដ និងស្របច្បាប់។ ការក្លែងបន្លំលិខិតសារការី ហត្ថលេខាសារការី ឬត្រារបស់មន្ទីសារការី គឺជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

### ១.៣.២. លិខិតដែលមានកាលបរិច្ឆេទស្ថាពរ

យោងទៅតាមមាត្រា ៨ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី លិខិតដែលមានកាលបរិច្ឆេទស្ថាពរដែលកំណត់ក្នុងកថាខណ្ឌទី៣ នៃមាត្រា ៤៥៩ (ឧបាទេសកម្មដោយការសង)កថាខណ្ឌទី២នៃមាត្រា៥០៣(លក្ខខណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) កថាខណ្ឌទី២នៃមាត្រា៨៤១(លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) និងកថាខណ្ឌទី២នៃមាត្រា៥០៣(លក្ខខណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរតាមបញ្ញត្តិនៃកថាខណ្ឌទី២នៃមាត្រា៤៥៩(ឧបាទេសកម្មដោយការសង) និងមាត្រា៥១៣(ការបង្កើតអនុប្បទានឋានៈក្នុងកិច្ចសន្យា)នៃក្រមរដ្ឋប្បវេណីសំដៅលើលិខិតខាងក្រោម:

**ក-** លិខិតយថាភូត។ចំពោះលិខិតយថាភូតកាលបរិច្ឆេទនៃការធ្វើលិខិតនោះត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ។

**ខ-** លិខិតឯកជនដែលសារការីឬក្រឡាបញ្ជីតុលាការចុះនិទ្ទេសអំពីកាលបរិច្ឆេទដែលខ្លួនត្រូវបានបង្ហាញលិខិតឯកជននេះនិងចុះហត្ថលេខា។ក្នុងករណីនេះកាលបរិច្ឆេទនោះត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ។

**គ-** លិខិតឯកជនដែលមានជនណាម្នាក់ក្នុងចំណោមជនដែលបានចុះហត្ថលេខាលើលិខិតនោះបានទទួលមរណភាព។ក្នុងករណីនេះថ្ងៃដែលជននោះទទួលមរណភាពត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ។

**ឃ-** លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាននៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរ។

ក្នុងករណីនេះកាលបរិច្ឆេទនៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្កាពរនោះត្រូវក្លាយជាកាលបរិច្ឆេទស្កាពរសម្រាប់លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាននោះ។

**ឧទាហរណ៍៖** ពាក់ព័ន្ធជាមួយហ៊ីប៉ូតែកពេលខ្លះទ្រព្យមួយមានម្ចាស់បំណុលពីរទៅបីនាក់ហេតុនេះពេលមានវិវាទកូនបំណុលមិនអាចសងបំណុលបាន ដូច្នេះម្ចាស់បំណុលត្រូវប្តឹងទៅតុលាការដើម្បីលក់ឡាយឡុងទ្រព្យនោះដើម្បីសងបំណុលហេតុនេះតុលាការនឹងពិនិត្យមើលថាម្ចាស់បំណុលមួយណាចុះហ៊ីប៉ូតែកមុនគេ។ ចឹងហ៊ីប៉ូតែកដែលសាការីបានតាក់តែងនឹងមានកាលបរិច្ឆេទច្បាស់លាស់ព្រមទាំងមានឋានៈលេខរៀងនៃម្ចាស់បំណុលនោះ។

### ១.៣.៣. លិខិតអនុវត្ត

លិខិតអនុវត្ត គឺជាឯកសារបញ្ជាក់អំពីសិទ្ធិទាមទារ ឲ្យផ្តល់តាវកាលិកណាមួយជាក់លាក់ដែលកំណត់នៅក្រោមនីតិឯកជន ហើយដោយផ្អែកលើឯកសារនេះ ច្បាប់ផ្តល់ ឱ្យនូវអំណាចបង្ខំឲ្យអនុវត្ត ដើម្បីសម្រេចនូវអត្ថន័យនៃសិទ្ធិ នោះ តាមរយៈការអនុវត្តដោយបង្ខំ។ លិខិតយថាភូតដែរបានតាក់តែងឡើងដោយសារការីទាំងអស់ មិនមែនសុទ្ធតែអាចអនុវត្តដោយបង្ខំបាននោះទេ។ លុះត្រាតែលិខិតយថាភូតដែលសារការីបានតាក់តែងនោះ បានបំពេញនូវលក្ខខណ្ឌដូចដែរបានចែងនៅចំណុច ច ក្នុងមាត្រា៣៥០និងមាត្រា៤៩៦ទើបជាលិខិត ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ គឺ លិខិតយថាភូតដែលធ្វើឡើងដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់មានកំណត់ ហើយ ដែល នៅក្នុងលិខិតនោះបានបញ្ជាក់សេចក្តីថ្លែងការណ៍ថា កូន បំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ។ ហើយព្រមទាំង លិខិតអនុវត្តដើម្បីសម្រេចសិទ្ធិប្រាតិភោគ រួមមាន (មាត្រា ៤៩៦)៖

- សាលក្រម ឬសាលដីកាស្ថាពរ ដែលបញ្ជាក់អំពី អត្ថិភាពនៃសិទ្ធិប្រាតិភោគ លើខិតដែលមានអានុភាពដូច សាលក្រមឬសាលដីកាស្ថាពរនោះ។
- លិខិតយថាភូតដែលធ្វើឡើងដោយសារការីហើយ ដែលបញ្ជាក់អំពីអតីភាពនៃសិទ្ធិប្រាតិភោគ។

## ផ្នែកទី២ ៖ ការទទួលត្រួវរបស់សារការី

### ២.១. កាតព្វកិច្ចផ្តល់យោបល់

ជូនដំណឹង ពន្យល់ដល់ភាគីនៃលិខិត អំពីកាតព្វកិច្ចនីមួយៗអានុភាពនៃលិខិតផ្ទៀងផ្ទាត់លក្ខខណ្ឌដែលច្បាប់តម្រូវ និងរាប់ឯកសារពាក់ព័ន្ធ។

### ២.២. ភាតព្វកិច្ចគោរពនូវការសម្ងាត់វិជ្ជាជីវៈ

មិនត្រូវផ្តល់នូវព័ត៌មានទៅបុគ្គលដ៏ទៃ ក្រៅពីគូភាគីនៃលិខិត សន្តតិជន សិទ្ធិវន្ត អាណត្តិគាហករបស់ពួកគេឬបុគ្គលដែលត្រូវបានអនុញ្ញាតដោយច្បាប់ឬតាមសេចក្តីសម្រេចដោយតុលាការ។

### ២.៣. ទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុ និងព្រហ្មទណ្ឌ

ទំនួលខុសត្រូវវិជ្ជាជីវៈចំពោះអតិថិជនតាមរយៈប្រាក់តម្កល់នៅធានាគារជាតិការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

### ២.៤. អង្គភាពគ្រប់គ្រង និងដាក់ពិន័យ

នាយកដ្ឋានសារការីដែលស្ថិតនៅក្រោមអគ្គនាយកដ្ឋានអភិវឌ្ឍវិស័យយុត្តិធម៌ នៃក្រសួងយុត្តិធម៌ ត្រូវដើរតួជាសេនាធិការឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងការគ្រប់គ្រង និងដាក់វិន័យ ក៏ដូចជាការងារផ្អាក ព្យួរ ឬបញ្ចប់ការប្រកបវិជ្ជាជីវៈសារការីស្របតាមច្បាប់កំណត់។

### ២.៥. ការធានាសុវត្ថិភាពគតិយុត្ត

តើប្រជាពលរដ្ឋអាចទទួលបានការពារសុវត្ថិភាពគតិយុត្តតាមរយៈសារការីដោយបែបណា ? ដោយសារការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជាផ្តោតទៅលើវិស័យសំខាន់ៗ ៣ ហេតុនេះសារការីអាចធានាសុវត្ថិភាពគតិយុត្តបានដោយៈ

- នៅក្នុងវិស័យគ្រួសារ (ការគ្រប់គ្រងបេតិកភណ្ឌគ្រួសារ)៖ ផ្តោតសំខាន់ទៅលើការពិគ្រោះយោបល់ដោះស្រាយវិវាទក្នុងគ្រួសារ(ដោយអព្យាក្រឹត្យមិនលម្អៀង), ក៏ដូចជាធានាសុវត្ថិភាពគតិយុត្តក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, ប្រទានកម្ម, អច្ច័យទាន, មរតកសាសន៍, កិច្ចសន្យាធានារ៉ាប់រងជីវិត, បរធនបាលកិច្ចជាដើមផងដែរ ។
- នៅក្នុងវិស័យអចលទ្រព្យ៖ ផ្តោតទៅលើការផ្ទេរកម្មសិទ្ធិ (ពាក់ព័ន្ធក្នុងកិច្ចសន្យាទិញលក់ ដូរ អំណោយ សិទ្ធិជួលអចិន្ត្រៃយ៍ សន្តិកម្ម) និងធានាសុវត្ថិភាពគតិយុត្តលើ សិទ្ធិប្រាតិភោគ សេវភាព ផលុបភោគ សិទ្ធិប្រើប្រាស់និងស្នាក់នៅផងដែរ ។
- នៅក្នុងវិស័យពាណិជ្ជកម្ម និងវិនិយោគ៖ ជាទីប្រឹក្សាយោបល់, តាក់តែងលិខិតបង្កើតនិងផ្លាស់, ប្តូរលក្ខន្តិកៈក្រុមហ៊ុន, បរធនបាលកិច្ចជាដើម ។

# ជំពូកទី៦

# ភាពខុសគ្នារវាងតួនាទីមេធាវី និងសារការី

## ផ្នែកទី១ ៖ វិជ្ជាជីវៈមេធាវី និងសារការី

### ១.១. វិជ្ជាជីវៈមេធាវី ឯករាជ្យ និងសេរី

មេធាវី និងសារការីសុទ្ធសឹងតែជាអ្នកជំនាញវិជ្ជាជីវៈក្នុងវិស័យច្បាប់។ បើតាមខ្លឹសារនៃមាត្រាតំបូងនៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី វិជ្ជាជីវៈមេធាវីគឺជា វិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបម្រើវិស័យយុត្តិធម៌។ហើយវិជ្ជាជីវៈនេះប្រព្រឹត្តទៅបានតែក្នុងក្របខ័ណ្ឌនៃគណៈមេធាវី តែប៉ុណ្ណោះ។ នៅក្នុងខ្លឹមសារនេះ វិជ្ជាជិវៈមេធាវីឯករាជ្យអាចបំពេញមុខងាររបស់ខ្លួនដោយគ្មានការកំហិតឬការជ្រៀតជ្រែកដែលមិនសមស្របពីព្រោះជាទូទៅពួកគេដើរតួនាទីដ៏សំខាន់ នៅក្នុងរដ្ឋបាលយុត្តិធម៌ត្រឹមត្រូវនិងក្នុងការបង្កើតនីតិរដ្ឋ និងមានសេរីភាព ពេញលេញក្នុងការជ្រើសរើសទីកន្លែងប្រកបវិជ្ជាជីវៈ សេរីភាពទទួល ឬមិនទទួលផ្តល់សេវាកម្មច្បាប់ជូនអតិថិជន សេរីភាពក្នុងការកំណត់កំរៃសេវា និងសេរីភាពក្នុងការជ្រើសរើសមធ្យោបាយបំពេញការងារដោយមិនស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យពី គណៈបក្សនយោបាយអង្គការសាសនា ឬអង្គការនានាផ្សេងទៀតប៉ុន្តែវាជាផ្នែកមួយនៃសង្គមស៊ីវិល និងជាអង្គការក្រៅរដ្ឋាភិបាលដែលត្រូវបានការពារដោយច្បាប់ជាក់លាក់មួយ( ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី )ដែលមានការគ្រប់គ្រងដោយគណៈមេធាវីនៃព្រះរាជាណាចក្រមកម្ពុជា ដែលមានភាពខុសគ្នា និងវិជ្ជាជិវៈសារការី។

### ១.២. វិជ្ជាជីវៈសារការី ជាមន្ត្រីសារធារណៈ

សារការីគឺជាមន្ត្រីសារធារណៈទទួលបាននូវអំណាចសាធារណៈ ដែលរាជរដ្ឋាភិបាលប្រគល់ឱ្យបំរើការងារផ្នែកច្បាប់ទទួលបន្ទុកធ្វើលិខិតស្នាមគតិយុត្តិ ដើម្បីអនុវត្តមុខងាររបស់ខ្លួនស្របតាមច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។ ក្នុងនាមជាមន្ត្រីសារធារណៈ សារការីពុំទទួលបានប្រាក់ខែ ឬ ទទួលបានប្រាក់ឧបត្ថម្ភជំនួយពីរដ្ឋឡើយ ប៉ុន្តែត្រូវនៅក្រោមការត្រួតពិនិត្យ និងការដាក់ពិន័យពីរដ្ឋ។ដូច្នេះ សារការីជាវិជ្ជាជីវៈឯករាជ្យត្រូវទទួលខុសត្រូវការងារនៅតាមមន្ទីរដោយខ្លួនឯង និងបានកម្រៃពីសេវាសារការី តាមរយៈការពិគ្រោះយោបល់បង្កើតលិខិតយថាភូត និងពិនិត្យលិខិតស្នាម។ ដោយយោងទៅតាម ព្រះរាជក្រម៩១០ ន.ស ព្រះរាជក្រឹត្យ១២៨ បបរ ស្តីពីបទប្បញ្ញត្តិទូទៅ និងអនុក្រឹត្យ៥០៥ រនក្រវតត ស្តីពីច្បាប់ស្តីពីការការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវី ដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

## ផ្នែកទី២ ៖ ការផ្តល់យោបល់

### ២.១. ការផ្តល់យោបល់របស់មេធាវី

ការផ្តល់យោបល់ក្នុងវិស័យច្បាប់របស់មេធាវីហាក់ដូចមានភាពស្រដៀងគ្នាទៅនិងសារការី។ បើយោងទៅតាមមាត្រា៣កថាខណ្ឌទី១នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បានចែងថា មេធាវីអាចផ្តល់យោបល់ក្នុងវិស័យគតិយុត្ត ហាក់ដូចជាមានវិសាលភាពទូលំលាយក្នុង ការផ្តល់យោបល់ក្នុងវិស័យគតិយុត្ត ដោយមិនបានកំណត់ ហើយយើងអាច សន្និដ្ឋាន ថាមេធាវីអាចប្រឹក្សាយោបល់ ឫផ្តល់យោបល់នៅក្នុងផ្នែកដែលទាក់ទងនិងច្បាប់ជាទូទៅ ឲ្យតែត្រឹមត្រូវតាមច្បាប់ និងតាមគន្លងច្បាប់ ដែលខុសពីសារការី។

### ២.២. ការផ្តល់យោបល់របស់សារការី

ការកំណត់អំពីតួនាទីក្នុងការផ្តល់ប្រឹក្សាយោបល់ តាមអនុក្រឹត្យស្តីពីការបង្កើតមន្ទីររបស់សារការី។ យើងក៏សូមលើកយកអនុក្រឹត្យស្តីពីការបង្កើតមន្ទីសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា នៅត្រង់មាត្រា៤ ចំណុចទី២ បានចែងថា មន្ទីសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា មានតួនាទី និងភារកិច្ច ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ ដែលបានកំណត់យ៉ាងច្បាស់។ ប៉ុន្តែសមញ្ញជន និងនិស្សិតច្បាប់ មានចម្ងល់អំពីតួនាទីមេធាវីនិងសារការីក្នុងការផ្តល់យោបល់ដែលទាក់ទងនិងច្បាប់ ដោយសារតែ មាត្រា៤នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីបានចែងថា ក្រៅពីមេធាវីដែលជាសមាជិកនៃគណៈមេធាវី គ្មានជនណាម្នាក់អាចប្រកបរបរយកកម្រៃក្នុងការពិគ្រោះច្បាប់ លើកលែងតែការពិគ្រោះច្បាប់ជាការងារបន្ទាប់បន្សំនៃមុខងាររបស់ខ្លួន ឫជាមុខងារដែលច្បាប់បានអនុញ្ញាត ប៉ុន្តែវិជ្ជាជិវៈសារការីដែលមិនទាន់មានច្បាប់កំណត់អំពីវិជ្ជាជីវៈផងនោះ តើអាចផ្តល់យោបល់ដែលទាក់ទងនិងច្បាប់បានទេ? ចុះបើបានដូចការកំណត់អំពីតួនាទីក្នុងមន្ទីសារការី អាចផ្តល់ប្រឹក្សាផ្តល់យោបល់នោះ ប្រាកដណាស់មន្ទីរបស់សារការីបានរំលោភបំពានច្បាប់ស្តីពីលក្ខន្តិកៈរបស់មេធាវី។

## ផ្នែកទី៣ ៖ អានុភាពនៃលិខិត

### ៣.១. លិខិតរបស់មេធាវី

នៅក្នុងការតាក់តែង លិខិតកិច្ចសន្យាដែលធ្វើដោយឡើងដោយមេធាវី គឺជាលិខិតឯកជន មិនមានតម្លៃស្មើនឹងសាលក្រមស្ថាពរទេ ។ លិខិតឯកជន សំដៅដល់លិខិតទាំងឡាយណា ដែលបង្កើតឡើងដោយបុគ្គលឯកជន ដោយមានការចុះហត្ថលេខា ឫស្នាមមេដៃ។ ហើយ បើកូនបំណុលមិនអនុវត្តកាតព្វកិច្ចម្ចាស់បំណុលមិន

អាចយកទៅអនុវត្តដោយបង្ខំបានទេ គឺត្រូវតែឆ្លងកាត់នីតិវិធីតុលាការដើម្បីសម្រេចសេចក្តី ដែលធ្វើឲ្យមានភាពខុសគ្នានៃលខិតដែលមានការតាក់តែងឡើងដោយសារការី។

### ៣.២. លិខិតរបស់សារការី

លិខិតរបស់សារការី មានគុណសម្បត្តិ៣៖ អំណាចបន្ទាល់ កាលបរិច្ឆេទស្ថាពរ និងអំណាចជាលិខិតអនុវត្ត។ អំណាចបន្ទាល់ មានន័យថា លិខិតសារការី គឺជាភ័ស្តុតាងដែលមានតម្លៃខ្ពស់ជាងគេ ដែលមានតម្លៃគតិយុត្តតាមផ្លូវច្បាប់ដែលត្រូវតែជឿ លើកលែងតែលិខិតនោះជាលិខិតក្លែងក្លាយ។ រាល់លិខិតសារការី ត្រូវចាត់ទុកថាត្រឹមត្រូវ ពិតប្រាកដ និងស្របច្បាប់។ ការក្លែងបន្លំលិខិតសារការី ហត្ថលេខាសារការី ឬត្រារបស់មន្ទីសារការី គឺជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ចំណែកឯលិខិតដែលមានកាលបរិច្ឆេទសាពរ បើយោងទៅតាមមាត្រា ៨ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី លិខិតដែលមានកាលបរិច្ឆេទស្ថាពរ ដែលកំណត់ក្នុងកថាខណ្ឌទី៣ នៃមាត្រា ៤៥៩ (ឧបាទសកម្មដោយការសង) កថាខណ្ឌទី២នៃមាត្រា៥០៣ (លក្ខខណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ)កថាខណ្ឌទី២នៃមាត្រា៨៤១ (លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ)និងកថាខណ្ឌទី២នៃមាត្រា៥០៣ (លក្ខខណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ)ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរតាមបញ្ញត្តិនៃកថាខណ្ឌទី២នៃមាត្រា៤៥៩ (ឧបាទេសកម្មដោយការសង) និង មាត្រា៥១៣(ការបង្កើតអនុប្បទានឋានៈក្នុងកិច្ចសន្យា)នៃក្រមរដ្ឋប្បវេណីសំដៅលើលិខិតខាងក្រោម:

**ក-** លិខិតយថាភូត។ ចំពោះលិខិតយថាភូតកាលបរិច្ឆេទនៃការធ្វើលិខិតនោះត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ។

**ខ-** លិខិតឯកជនដែលសារការីឬក្រឡាបញ្ជីតុលាការចុះនិទ្ទេសអំពីកាលបរិច្ឆេទដែលខ្លួនត្រូវបានបង្ហាញលិខិតឯកជននេះនិងចុះហត្ថលេខា។ ក្នុងករណីនេះកាលបរិច្ឆេទនោះត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ។

**គ-** លិខិតឯកជនដែលមានជនណាម្នាក់ក្នុងចំណោមជនដែលបានចុះហត្ថលេខាលើលិខិតនោះបានទទួលមរណភាព។ក្នុងករណីនេះថ្ងៃដែលជននោះទទួលមរណភាពត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ។

**ឃ-** លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាននៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរ។ ក្នុងករណីនេះកាលបរិច្ឆេទនៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរនោះ ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរសម្រាប់លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាននោះ។

ឧទាហរណ៍៖ ពាក់ព័ន្ធជាមួយហ៊ីប៉ូតែកពេលខ្លះទ្រព្យមួយមានម្ចាស់បំណុលពីរទៅបីនាក់ហេតុនេះពេលមានវិវាទកូនបំណុលមិនអាចសងបំណុលបានដូច្នេះម្ចាស់បំណុលត្រូវប្តឹងទៅតុលាការ ដើម្បីលក់ឡាយឡុងទ្រព្យនោះដើម្បីសងបំណុលហេតុនេះតុលាការនឹងពិនិត្យមើលថាម្ចាស់បំណុលមួយណាចុះហ៊ីប៉ូតែកមុនគេ។ ចឹងហ៊ីប៉ូតែកដែលសាការីបានតាក់តែងនឹងមានកាលបរិច្ឆេទច្បាស់លាស់ ព្រមទាំងមានឋានៈលេខរៀងនៃម្ចាស់បំណុលនោះ។ ជាពិសេស លិខិតដែលតាក់តែងឡើងដោយសារការីជាលិខិតអនុវត្ត។ លិខិតអនុវត្ត គឺជាឯកសារបញ្ជាក់អំពីសិទ្ធិទាមទារ ឲ្យផ្តល់តាវកាលិកណាមួយជាក់លាក់ ដែលកំណត់នៅក្រោមនីតិឯកជន ហើយដោយផ្អែកលើឯកសារនេះ ច្បាប់ផ្តល់ ឱ្យនូវអំណាចបង្ខំឲ្យអនុវត្ត ដើម្បីសម្រេចនូវអត្ថន័យនៃសិទ្ធិ នោះ តាមរយៈការអនុវត្តដោយបង្ខំ។ លិខិតយថាភូតដែរបានតាក់តែងឡើងដោយសារការីទាំងអស់ មិនមែនសុទ្ធតែអាចអនុវត្តដោយបង្ខំបាននោះទេ។ លុះត្រាតែលិខិតយថាភូតដែលសារការីបានតាក់តែងនោះ បានបំពេញនូវលក្ខខណ្ឌដូចដែរបានចែងនៅចំណុច ច ក្នុងមាត្រា៣៥០ និងមាត្រា៤៩៦ទើបជាលិខិត ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ គឺ លិខិតយថាភូតដែលធ្វើឡើងដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់មានកំណត់ ហើយ ដែល នៅក្នុងលិខិតនោះបានបញ្ជាក់សេចក្តីថ្លែងការណ៍ថា កូន បំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ។ ហើយព្រមទាំង លិខិតអនុវត្តដើម្បីសម្រេចសិទ្ធិប្រាតិភោគ រួមមាន (មាត្រា ៤៩៦)៖

- សាលក្រម ឬសាលដីកាស្ថាពរ ដែលបញ្ជាក់អំពី អត្ថិភាពនៃសិទ្ធិប្រាតិភោគ លើខិតដែលមានអានុភាពដូច សាលក្រមឬសាលដីកាស្ថាពរនោះ។
- លិខិតយថាភូតដែលធ្វើឡើងដោយសារការីហើយ ដែលបញ្ជាក់អំពីអាទិភាពនៃសិទ្ធិប្រាតិភោគ។

## ផ្នែកទី៤៖ វិសមិតភាពតួនាទី រវាងមេធាវីនិងសារការី

### ៤.១. សារការីមិនអាចតំណាងដោយអាណត្តិ និងការពារក្តីនៅតុលាការ

សារការីមិនអាចក្លាយជាអ្នកតំណាងដោយអាណត្តិ និងការពារក្តីនៅតុលាការ។ មូលហេតុដែលសារការីមិនអាចក្លាយជាតំណាងដោយអាណត្តិនោះ ជាគោលការណ៍ ជនដែលអាចក្លាយជាអ្នកតំណាងដោយអាណត្តិមានតែមេធាវីប៉ុណ្ណោះ ដើម្បីការពារផលប្រយោជន៍សាមីភាគីដែលជាអ្នកពឹងពាក់ ដោយក្នុងបណ្តឹងសិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ ត្រូវបង្កើតឡើងតាមរយៈការបង្ហាញឆន្ទៈរបស់ភាគី ដែលបានផ្តល់នូវសិទ្ធិក្នុងការតំណាងដោយអាណត្តិក្នុងរឿងក្តីនីមួយៗ។ ចំពោះជនដែលត្រូវធ្វើជាតំណាងត្រូវធ្វើកិច្ចសន្យា ឬលិខិតជាលាយល័ក្ខណ៍អក្សរដើម្បីកំណត់ឱ្យបានច្បាស់អំពីសិទ្ធិរបស់អ្នកតំណាង។យ៉ាងណាមិញក្នុងករណី

ដែលជននោះមិនមែនជាមេធាវីបានធ្វើសកម្មភាពបណ្តឹងក្នុងនាមជាអ្នកតំណាងដោយអាណត្តិ នោះគឺជាអំពើខុសច្បាប់ ហើយតុលាការត្រូវបំបាត់ចោលនូវការពាក់ព័ន្ធរបស់អ្នកនោះ ។ ប៉ុន្តែក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៣ ក៏បានទទួលស្គាល់ជនដែលអាចជ្រើសតាំង ក្រៅពីមេធាវីឱ្យធ្វើជាអ្នកតំណាងដោយអាណត្តិបានដូចមានខាងក្រោម៖

**ក៖** ករណីដែលក្រមនេះ ឬច្បាប់ដទៃទៀត អនុញ្ញាតឱ្យតតិយជនដែលមិនមែនជាមេធាវី ធ្វើសកម្មភាពបណ្តឹងជំនួសភាគី។

**ខ៖** ករណីដែលភាគីជារដ្ឋ ស្ថាប័ននីតិរដ្ឋបាល ឬស្ថាប័នរដ្ឋដទៃទៀត និង ដែលស្ថាប័ននោះ ឬអ្នកតំណាង នៃស្ថាប័ននោះ តែងតាំងបុគ្គលិកនៃស្ថាប័ននោះជាអ្នកតំណាង។

**គ៖** ករណីដែលតុលាការអនុញ្ញាតឱ្យមានការតំណាងដោយតតិយជនដែលមិនមែនជាមេធាវី ក្នុងរឿងក្តីដែលតម្លៃនៃបណ្តឹងតិចជាង ១.០០០.០០០ (មួយលាន) រៀល។

បន្ថែមពីនេះសកម្មភាពបណ្តឹងដែលធ្វើដោយអ្នកតំណាងដោយអាណត្តិ នឹងបង្កើតនូវអានុភាពដូចគ្នានឹងសកម្មភាពដែលធ្វើដោយភាគី ប៉ុន្តែអ្នកតំណាងដោយអាណត្តិមិនមែនជាភាគីនោះទេ ដូច្នេះមិនត្រូវទទួលបាននូវអានុភាពនៃសាលក្រម ឬសាលដីកាឡើយ។ម្យ៉ាងទៀតទោះបីជាធ្វើការជ្រើសតាំងអ្នកតំណាងដោយអាណត្តិក៏ដោយ ក៏ភាគីអាចចូលរួមក្នុងនីតិវិធីនៅតុលាការដោយខ្លួនឯងបាន ដូចមានចែងក្នុងមាត្រា ៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណីដូចខាងក្រោម៖

**១៖** ភាគីអាចធ្វើរាល់សកម្មភាពដែលទាក់ទងនឹងបណ្តឹង ដោយខ្លួនឯងផ្ទាល់ ឬឆ្លងតាមរយៈអ្នកតំណាងដោយអាណត្តិដែលខ្លួនបានជ្រើសតាំង។

**២៖** ទោះបីភាគីបានជ្រើសតាំងអ្នកតំណាងដោយអាណត្តិក៏ដោយ ក៏ភាគីនោះអាចចូលរួមទៅតុលាការ និងឆ្លើយទាញហេតុផលដោយខ្លួនឯងបានដែរ។

**៣៖** សកម្មភាពបណ្តឹងដែលជាអ្នកតំណាងដោយអាណត្តិបានធ្វើ ត្រូវបង្កើតអានុភាពដូចគ្នាជាមួយសកម្មភាពបណ្តឹងដែលភាគីបានធ្វើដោយផ្ទាល់ខ្លួន។

ចំពោះការពារក្តីនៅតុលាការវិញជាសមត្ថកិច្ចរបស់មេធាវីក្នុងការ ការពារក្តីកូនហើយ យើងសម្គាល់ឃើញគេប្រើពាក្យនេះសម្តៅក្នុងរឿងព្រហ្មទណ្ឌ។ មេធាវីអាចជួយការពារក្តីនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនីតិវិធីតុលាការ។

### ៤.២. មេធាវីមិនអាចតាក់តែងលិខិតយថាភូត

មេធាវីមិនអាចតាក់តែងលិខិតយថាភូតដែលជាសមត្ថកិច្ចរបស់សារការីបានទេ ពីព្រោះតួនាទីចម្បងរបស់សារការីគឺតាក់តែងលិខិតយថាភូតដែលទទួលបានអំណាចពីរដ្ឋ។ ឧទាហរណ៍មានដូចជា កិច្ចសន្យាអនុប្បទានកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់, អចលនវត្ថុ, ពិសេសកិច្ចសន្យាលក់ទិញ, ការដូរ, និងប្រទានកម្ម, ហ៊ីប៉ូតែក, មតកសាសន៍ដោយលិខិតយថាភូត ដែលតម្រូវដោយច្បាប់ ហើយតម្រូវការរបស់គូភាគី គឺចង់ឲ្យកិច្ចសន្យាគ្រប់ប្រភេទដែលគូភាគីចង់ឱ្យក្លាយជាលិខិតយថាភូត។ ពីព្រោះលិខិតយថាភូតជាលិខិតដែលត្រូវតែធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈដែលត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិមុខងារនេះ។

### ៤.៣. មេធាវីមិនអាចផ្តល់យថាភូតភាពទៅលើលិខិត

មេធាវីមិនអាច ផ្តល់នូវយថាភូតភាពទៅលើលិខិត ដូចសារការីបាននោះទេ ពីព្រោះសារការីមានតួនាទីផ្តល់នូវយថាភូតភាព ហើយរាល់លិខិតគតិយុត្តដែលត្រូវ ផ្តល់នូវយថាភូតភាព និងត្រូវធ្វើឡើងក្រោមទម្រង់ជាលិខិតបញ្ជាក់ដោយសារការី។

លិខិតបញ្ជាក់គឺជាលិខិតដែលសារការីផ្តល់នូវយថាភូតភាព ចំពោះអត្តសញ្ញាណរបស់ភាគីដែលបានចុះហត្ថលេខាលើលិខិត ឬភាពត្រឹមត្រូវនូវច្បាប់ចម្លងទៅនឹងច្បាប់ដើមឬភាពត្រឹមត្រូវនៃការបកប្រែរបស់ឯកសារណាមួយ។ លិខិតបញ្ជាក់ មានអំណាចបន្ទាល់ និងកាលបរិច្ឆេទស្ថាពរ ប៉ុន្តែមិនមានជាលិខិតអនុវត្តទេ។ ហើយបើតាមការកំណត់នៃលិខិតគតិយុត្ត ដែលគួរតែ ត្រូវធ្វើឡើងក្រោមទម្រង់ជាលិខិតបញ្ជាក់ដោយសារការីមានដូចជា៖ លក្ខន្តិកៈនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត,ការកែប្រែលក្ខន្តិកៈនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត, លក្ខន្តិកៈនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត, ការកែប្រែលក្ខន្តិកៈនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត, លក្ខន្តិកៈនីតិបុគ្គលមូលនិធិ, មតកសាសន៍ដោយលិខិតសម្ងាត់,ឧបាទេសកម្មដោយការសង,អនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ, ការបញ្ចាំសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ, និងអនុប្បទានឋានៈក្នុងកិច្ចសន្យា ជាដើម។

សូមបញ្ជាក់ថា ក្នុងករណីដែលច្បាប់ ឬបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀតតម្រូវ លិខិតគតិយុត្តក្រៅពីលិខិតដូចបានរៀបរាប់ខាងលើនេះក៏ត្រូវធ្វើឡើងក្រោមទម្រង់ជាលិខិតសារការផងដែរ។ ទោះបីមានបញ្ញត្តិនៃកថាខណ្ឌខាងលើក៏ដោយភាគីនៃលិខិតក៏អាចស្នើសុំឲ្យសារការីផ្តល់យថាភូតភាពឬធ្វើការបញ្ជាក់លើលិខិតគតិយុត្តផ្សេងទៀតបានដែរនេះជាការបញ្ជាក់ក្នុងសេចក្តីព្រាងច្បាប់សារការី។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការស្រាវជ្រាវ និងបានបង្ហាញនៅការអត្ថាធិប្បាយខាងលើរួចមកហើយ អំពីការកកើតជាថ្មីម្តងទៀតនៃវិជ្ជាជីវៈមេធាវីនិងសារការីក្នុងសង្គមនីតិរដ្ឋយើងនេះយើងបានសរសេរសម្រាយលម្អិតដោយមានការចាប់ផ្តើមពីការកកើតនៃវិជ្ជាជីវៈទាំងពីរ ព្រមទាំងធ្វើការបង្ហាញអំពីបែបបទនៃការប្រកបវិជ្ជាជីវៈ ដើម្បីឲ្យសមញ្ញជនឬនិស្សិតអ្នកអានបានយល់ពីមូលហេតុដើម្បីទទួលបានមុខងារនៃវិជ្ជាជីវៈនិងត្រៀមប្រលងប្រកួតប្រជែងនៅថ្ងៃខាងមុខ។ ជាពិសេសនោះ យើងខ្ញុំបានបកស្រាយអំពីតួនាទីមេធាវី និងសារការី ដើម្បីឲ្យងាយស្រួលប្រៀបធៀប វែកញែកពីភាពខុសគ្នារវាងតួនាទីមេធាវី និងតួនាទីសារការី និងបម្រើផលប្រយោជន៍ដល់សិស្សនិស្សិត អ្នកអាន សមញ្ញជន ឬអ្នកចង់ស្វែងរកសេវាកម្មច្បាប់ ដែលខ្លឹមសារអត្ថបទអាចផ្តល់ជាគំនិតក្នុងការសម្រេចចិត្តថានិងទៅពឹងពាក់មេធាវី ឬសារការី។

ប៉ុន្តែបើឆ្លងតាមបទពិសោធន៍នៃការស្រាវជ្រាវនេះ គឺអាស្រ័យទៅតាមតម្រូវការរបស់អតិថិជនថាខ្លួនពេញចិត្តមេធាវី ឬសារការី ព្រោះនៅឯការតុលាការមេធាវីគឺជាអ្នកតំណាងដោយអាណត្តិ និងការពារក្តីគ្រប់នីតិវិធីនៅតុលាការជាពិសេសកិច្ចការមួយទៀតដែលជាសមត្ថកិច្ចផ្តាច់មុខផងដែលនោះគឺការតាក់តែងនីតិវិធីសរសេរដើម្បីដាក់ជូនទៅតុលាការដូចជាពាក្យបណ្តឹងជាដើមរីឯសារការីវិញជាតួអង្គវិជ្ជាជីវៈច្បាប់ ដែលមិនអាចខ្វះបានក្នុងគ្រប់ករណីដែលជាឯកសាររៀបរៀងសរសេរដោយសារការីគឺនៅពេលដែលច្បាប់កំណត់ថាលិខិតឬឯកសារទាំងអស់នោះត្រូវតែធ្វើឡើងដោយសារការី។ ឧទាហរណ៍៖ កិច្ចសន្យាអនុប្បទានកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ អចលនវត្ថុ, ពិសេសកិច្ចសន្យាលក់ទិញ, ការដូរ និងប្រទានកម្ម, ហ៊ីប៉ូតែក, មតកសាសន៍ដោយលិខិតយថាភូតជាដើម ដែលលិខិត ឫកិច្ចសន្យានោះមានការតម្រូវរបស់ច្បាប់ វាជាសមត្ថកិច្ចផ្តាច់មុខរបស់សារការី និងជាតម្រូវការរបស់គូភាគី ដែលចង់ឲ្យកិច្ចសន្យាគ្រប់ប្រភេទដែលគូភាគី ក្លាយជាលិខិតយថាភូត។ ពីព្រោះលិខិតយថាភូតបានធានាមកនូវ តុល្យភាព ប្រសិទ្ធភាព និងសុវត្ថិភាពគតិយុត្ត ដល់គូភាគីនៃលិខិត តាមរយៈកាតព្វកិច្ចផ្ទៀងផ្ទាត់ឯកសារ ផ្តល់ប្រឹក្សាមិនលំអៀង តម្កល់រក្សាច្បាប់ដើមនៃលិខិតទុក។បន្ថែមពីនេះលិខិតរបស់សារការី មានគុណសម្បត្តិ ឬអានុភាពរហូតដល់ទៅ៣នោះគឺ អំណាចបន្ទាល់, កាលបរិច្ឆេទស្ថាពរ និងអំណាចជាលិខិតអនុវត្តផងដែរ។

សរុបសេចក្តីមក គោលបំណងនៅក្នុងសារណានេះគឺចង់បង្ហាញពីភាពខុសគ្នារវាងមេធាវីនិងសារការី ទៅដល់សិស្សនិស្សិតច្បាប់ ស្វែងយល់ពីវិជ្ជាជីវៈមេធាវីនិងសារការីនេះ និងទៅដល់អ្នកដែលចង់រកសេវាកម្មច្បាប់

ដើម្បីឲ្យគាត់ប្រើ និងជ្រើសរើសសេវាកម្មច្បាប់ឲ្យស្របទៅនិងអ្វីដែលជាតម្រូវការរបស់អតិថិជន ហើយវិជ្ជាជីវៈទាំងពីនេះមានគោលដៅតែមួយទេ គឺដើម្បីជួយចូលរួមបំរើវិស័យយុត្តិធម៌។

# អនុសាសន៍

ក្រោយពីបានបញ្ចប់ការសិក្សាស្រាវជ្រាវ ភាពខុសគ្នារវាងតួនាទីមេធាវី និងតួនាទីសារការីនៅកម្ពុជា មកខ្ញុំបាទ សង្កេតឃើញថាវិជ្ជាជីវៈទាំងពីរនេះមានពិតជាសារៈសំខាន់ណាស់ក្នុងការជួយជំរុញសេវាកម្មច្បាប់ ក៏ដូចជាជួយពង្រឹងវិស័យយុត្តិធម៌ ឲ្យកាន់តែប្រសើរឡើងពីមួយជំនាន់ទៅមួយជំនាន់។ ជាមួយគ្នានោះដែរ ខ្ញុំបាទចាប់អារម្មណ៍វិជ្ជាជីវៈមេធាវីដែលជាមូលេគុលតូចៗទៅប្រយុទ្ធប្រឆាំងនិងភាពអយុត្តិធម៌ក្នុងសង្គមចំណែកឯសារការីជាវិជ្ជាជីវៈមួយដែលសង្គមកម្ពុជាត្រូវការជាចាំបាច់ផងដែល។ ចំពោះវិជ្ជាជីវៈសារការី យើងខ្ញុំមានចំណុចមួយចំនួនដែលជួយជំរុញឲ្យដំណើរការលើវិជ្ជាមេធាវីមានភាពល្អប្រសើរជាងពេលបច្ចុប្បន្ននេះ ដែលមានការរៀបរាប់ដូចខាងក្រោម៖

ចំពោះវិជ្ជាជីវៈមេធាវី ការប្រឡងជ្រើសរើសមេធាវីត្រូវកើតចេញពីភាពត្រឹមត្រូវ និង យុត្តិធម៌ ដើម្បីធ្វើយ៉ាងណា អាចរើសបាននូវអ្នកដែលមានសមត្ថភាពពិតប្រាកដ។ ដូចគ្នានេះដែរ ការអនុញ្ញាតឱ្យចូលប្រកបវិជ្ជា ជីវៈមេធាវីតាមរយៈការស្នើសុំ ត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ ដោយបំពេញទៅតាមលក្ខខណ្ឌដែល បានកំណត់។ រីឯ ការបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីត្រូវតែធានាបាននូវប្រសិទ្ធភាព និងគុណភាពទាំងចំណេះ ដឹងនិង សីលធម៌វិជ្ជាជីវៈ។ហើយមេធាវីខ្លួនឯងផ្ទាល់ក៏ត្រូវខិតខំសិក្សាស្វែងយល់បន្ថែមឱ្យបានច្រើន ទាំងចំណេះដឹងផ្នែកច្បាប់និងសង្គម ជាពិសេសត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈភាពសុចរិត និងភាពស្មោះត្រង់ចំពោះអតិថិជន។ បន្ថែមពីនេះ នៅពេលធ្វើការផ្សះផ្សារវាងគូភាគីទាំងពីរ ទាំងការផ្សះផ្សាដោយមេធាវី និងការផ្សះផ្សា ដោយតុលាការ មេធាវីគួរខិតខំឱ្យអស់ពីសមត្ថភាពក្នុងការពន្យល់ណែនាំ និង សម្របសម្រួលឱ្យ គូភាគីទាំងសងខាងមានការសះជានឹងគ្នា ដើម្បីឱ្យអាចរក្សាបាននូវផលប្រយោជន៍នគូភាគីទាំង សងខាង ហើយមេធាវីត្រូវខិតខំឱ្យអស់ពីសមត្ថភាពក្នុងការស្វែងរក និងប្រមូលភស្តុតាងដាក់ទៅតុលាការ ដើម្បីគាំទ្រលើអំណះអំណាងរបស់ខ្លួនដែលបានលើកឡើង ធ្វើយ៉ាងណាដើម្បីអាចការពារបាននូវ ផលប្រយោជន៍នៃកូនក្តីរបស់ខ្លួន។ ម៉្យាងវិញទៀត មេធាវីមិនត្រូវប្រើមធ្យោបាយទុច្ចរិត ឬខុសច្បាប់ ណាមួយដើម្បីឱ្យបានឈ្នះក្តីនោះឡើយ និងត្រូវប្រកាន់នូវគោលការណ៍សិលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ម៉្យាងវិញទៀត ចំពោះវិជ្ជាជីវៈសារការីវិញ ប្រជាពលរដ្ឋភាគច្រើនពុំទាន់បានយល់ដឹងអំពីសិទ្ធិកាតព្វកិច្ចរបស់សារការីនៅឡើយ ដោយសារវិជ្ជាជីវៈនេះទើបនឹងចាប់កំណើតជាថ្មីម្តងទៀត ក្នុងនីតិរដ្ឋថ្មីនេះ ដូចនេះស្ថាប័នរដ្ឋ ឬស្ថាប័នពាក់ព័ន្ធ គួរតែបង្កើនការផ្សព្វផ្សាយគ្រប់រូបភាពទាក់ទងនឹងអត្ថប្រយោជន៍ដែលទទួលបានពីការ

ទទួលសេវាកម្ម ការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់សារការីទៅដល់ប្រជាពលរដ្ឋទាំងអស់។ ម៉្យាងទៀតទោះបីជាក្នុងពេលបច្ចុប្បន្ននេះ សារការីមានចំនួនកើនឡើងជាបន្តបន្ទាប់ក៏ពិតមែន ប៉ុន្តែមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការក្នុងពេលបច្ចុប្បន្ននោះទេ។ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងពេលបច្ចុប្បន្ន ស្ថាប័នរដ្ឋគួរតែមានការបណ្តុះបណ្តាលសារការីបន្ថែមទៀត។ បន្ថែមពីលើការបណ្តុះបណ្តាលវិជ្ជាជីវៈសារការីនេះផងដែរ យើងការបានសង្កេតឃើញថាមានបញ្ញត្តិអំពីសមត្ថកិច្ចរបស់សារការីមួយចំនួនដែលបានចែង មានភាពត្រួតស៊ីគ្នាជាមួយសមត្ថកិច្ចរបស់ស្ថាប័នរដ្ឋមួយចំនួនដូចជាភូមិ សង្កាត់ ខណ្ឌ ដែលជារដ្ឋបាលថ្នាក់ក្រោមជាតិ។ មិនតែប៉ុណ្ណោះប្រទេសកម្ពុជាយើងពុំទាន់មានបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈសារការីនោះទេ នេះជាកត្តាមួយដែលធ្វើឲ្យសារការីពិបាកក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន នេះហេតុផលចម្បងមួយដែលស្ថាប័ននីតិបញ្ញត្តិ ក្រសួង ស្ថាប័នរដ្ឋ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតគួរធ្វើការគិតគូរ និង ពិចារណាក្នុងការពន្លឿននៅ ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការី ដែលបច្ចុប្បន្ននៅតែជាសេចក្តីព្រាងច្បាប់នៅឡើយ ពីព្រោះច្បាប់នេះពិតជាមានសារៈសំខាន់ណាស់ក្នុងការកំណត់រចនាសម្ព័ន្ធ ការគ្រប់គ្រង ពិសេសការកំណត់នូវដែនសមត្ថកិច្ចនៃការរអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់សារការីឲ្យបានច្បាស់លាស់និងកាន់តែមានភាពងាយស្រួលក្នុងការអនុវត្ត។

# បញ្ជីឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានជាតិ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣

២. ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដែលប្រកាសឱ្យប្រើកាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥

៣. បទបញ្ជាផ្ទៃក្នុងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី

៤. ក្រមសីលធម៌មេធាវី ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២

៥. ព្រះរាជក្រមលេខ ៩១០នស ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ ១៩៥៤

៦. ព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥

៧. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧

៨. ក្រមនីតិវិធីរដ្ឋប្បវេណី នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

៩. ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០០១

១០. ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤,៣០ សីហា ២០០១

១១. ព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធី១៣ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

១២. អនុក្រឹត្យលេខ ៥០៥ អនក្រ.តត ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃ

១៣. គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, ០៤ ធ្នូ ២០០១

១៤. អនុក្រឹត្យស្តីពីការបង្កើតសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

១៥. អនុក្រឹត្យលេខ ១៨៤ អនក្រ.បក ស្តីពីការទទួលស្គាល់មន្ទីសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា, ២៣ កញ្ញា ២០០៨

១៦. អនុក្រឹត្យ ៥០៥ អនក្រ/តត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ តែង តាំង លោក បែនសុន សម៉យ

១៧. ប្រកាសរបស់ក្រសួងយុត្តិធម៌, លេខ៤៧ ក.ប្រក/១២, ១៦ កុម្ភៈ ២០១២

១៨. ប្រកាសរបស់ក្រសួងយុត្តិធម៌, លេខ៣ ២ កយ.ប្រក ៦ ២ , ០៣ ឧសភា ២០១២

១៩. ប្រកាសរបស់ទីស្តីការគណៈរដ្ឋមន្ត្រី, លេខ១៧ ប្រក, ២៨ កុម្ភៈ ២០១៣

**សេចក្តីសម្រេច សេចក្តីណែនាំ និងលិខិតនានា**

១. សេចក្តីណែនាំលេខ១៥៥៤/គម/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ របស់គណៈមេធាវី ស្តីពីកាតព្វកិច្ចរបស់គ្រូកម្មសិក្សានិង កម្មសិក្សាការី

២. សេចក្តីសម្រេចលេខ ២៩៤/សសគម/១៩ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មការវិន័យនៃក្រុមប្រឹក្សាគណៈមេធាវី

៣. ផែនការយុទ្ធសាស្ត្រ របស់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ២០១៩-២០២០

៤. ព្រឹត្តិបត្រ មេធាវី ច្បាប់ ចេញប្រចាំត្រីមាសទី១ ឆ្នាំ១៩៩៩លេខ១របស់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

**ឯកសារជាសៀវភៅ និងអត្ថបទផ្សេងៗ**

១. មេធាវី ប៊ុន ហុន, ក្រមសីលធម៌ និង ការទទួលខុសត្រូវចំពោះវិជ្ជាជីវៈមេធាវី, សីហា, ២០០៩

២. កុយនាម, ដំណើរការក្តីនៅក្នុងតុលាការនៅកម្ពុជា

៣. វិទ្យាស្ថានខ្មែរដើម្បីលិទ្ធិប្រជាធិបតេយ្យ, តួនាទីរបស់មេធាវី, ទំព័រ ៣៩

៤. មេធាវី អៀវ ប៊ុនផង, បច្ចេកទេសសវនាការនៃមេធាវីព្រហ្មទណ្ឌរាជធានីភ្នំពេញ, ២០១១

៥. មេធាវី អៀវ ប៊ុនវ៉ែង, បច្ចេកទេសសវនាការនៃមេធាវីរដ្ឋប្បវេណី,រាជធានីភ្នំពេញ, ២០១១

៦. សេចក្តីផ្តើមនៃនីតិកម្ពុជា

៧. ហ៊ី សោភា, នីតិវិធីរដ្ឋប្បវេណី

៨. លី តៃសេង, មេធាវី និង សីលធម៌

៩. វចនានុក្រមរបស់សម្តេចព្រះសង្ឃរាជជួនណាត

១០. សទ្ទានានុក្រមផ្នែករដ្ឋប្បវេណីនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

**គេហៈទំព័រ**

១. សេង ឪណា, ការ ដាក់ អាណាព្យាបាល បារាំង នៅ កម្ពុជា នៅ ឆ្នាំ ១៨៦៣, ចុះផ្សាយនៅថ្ងៃ ០៩ ខែកម្ភះ ឆ្នាំ ២០១៤ និង កែប្រែថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៥ https://www.rfi.fr/km/french-protectorate-over-cambodia

២. ភិន សុភី, ប្រវត្តិទាមទារឯករាជ្យពីបារាំង ដោយព្រះបាទនរោត្តមសីហនុ៩វិច្ឆិកា, ចុះផ្សាយនៅថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០២០ https://vayofm.com/news/detail/105576-841121735.html

៣.   ក្រុមប្រឹក្សាអាជ្ញាកណ្តាល https://www.arbitrationcouncil.org/about-ac/arbitration-council/?lang=km

៤. សាលាត្រាជូ វាក្យស័ព្ទច្បាប់នៃពាក្យសាការី https://salatraju.com/lexique

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធ១.** ព្រះរាជក្រមលេខៈ នសរកម០៨៩៥ ប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៥

**ឧបសម្ព័ន្ធ២.** អនុក្រឹត្យលេខៈ ៥០៥ អនក្រ.តត ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១

**ឧបសម្ព័ន្ធ៣.** អនុក្រឹត្យលេខៈ ១៤៤ អនក្រ.បក ស្តីពីការទទួលស្គាល់ មន្ទីសារការី អេស ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨

**ឧបសម្ព័ន្ធ៤.** អនុក្រឹតលេខៈ ២០៣ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសាការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦

**ឧបសម្ព័ន្ធ៥.** ប្រកាស លេខៈ ៣២ កយ.ប្រក/១២ ស្តីពីការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២

**ឧបសម្ព័ន្ធ៦.** អនុក្រឹត្យលេខៈ ១១៧ អនក្រ.បក ស្តីពីការបង្កើតសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨

# ឧបសម្ព័ន្ធ១.

## ព្រះរាជក្រមលេខៈ នសរកម០៨៩៥ ប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

នស/រកម/០៨៩៥/០៦

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

******

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១និងនាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរនិងអំពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីលក្ខន្តិកៈមេធាវី ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់
ស្តីពី
# លក្ខន្តិកៈមេធាវី

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

មាត្រា ១.-

វិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបំរើវិស័យយុត្តិធម៌ ។

វិជ្ជាជីវៈមេធាវីប្រព្រឹត្តទៅបានតែក្នុងក្របខ័ណ្ឌនៃគណៈមេធាវី ។

មាត្រា ២.-

មេធាវីអាចតំណាងកូនក្តីតាមការយល់ព្រមពីកូនក្តី ឬជួយការពារកូនក្តីនៅគ្រប់ សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធីលើកលែងតែមានបទបញ្ញត្តិច្បាប់ចែងផ្ទុយពីនេះ ជាពិសេសក្នុងរឿង រដ្ឋប្បវេណី ពាណិជ្ជកម្ម រដ្ឋបាល ការងារ សង្គមកិច្ច ។

ក្នុងរឿងព្រហ្មទណ្ឌ មេធាវីជួយការពារជនជាប់ចោទ ហើយមិនអាចតំណាងជន ជាប់ចោទបានឡើយ លើកលែងតែក្នុងករណីអនុវត្តបទបញ្ញត្តិពិសេសនៃច្បាប់ ។ មេធាវីអាចតំណាងអ្នកទទួលខុសត្រូវក្នុងបទរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីបាន ។

មេធាវីអាចជួយការពារកូនក្តីបានដែរនៅចំពោះមុខក្រុមប្រឹក្សាវិន័យ ។

មាត្រា ៣.-

មេធាវីផ្តល់យោបល់ និងតាក់តែងលិខិតស្នាមផ្សេងៗក្នុងវិស័យគតិយុត្ត ។

មេធាវីអាចត្រូវបានចាត់តាំងដោយតុលាការ ឬចៅក្រមឲ្យបំពេញមុខងារជាអ្នក

ផ្សះផ្សា ឬជាអ្នកសម្រុះសម្រួល ។ មេធាវីនឹងអាចត្រូវបានចាត់តាំងជាអាជ្ញាកណ្ដាល បាន លុះត្រាតែមាន ច្បាប់អនុញ្ញាត ។

មាត្រា ៤.-

ក្រៅពីមេធាវីដែលជាសមាជិកនៃគណៈមេធាវី គ្មានជនណាម្នាក់អាចប្រកបមុខរបរយកកម្រៃក្នុងការពិគ្រោះច្បាប់ ឬតាក់តែងលិខិតស្នាមគតិយុត្តបានឡើយ លើកលែងតែការ ពិគ្រោះច្បាប់ ឬការតាក់តែងលិខិតស្នាមនោះជាការងារបន្ទាប់បន្សំនៃមុខរបររបស់ខ្លួន ឬជាមុខងារដែលច្បាប់បានអនុញ្ញាត ។

មាត្រា ៥.-

មេធាវីបរទេសដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីប្រទេសក្រៅ ឬដែលប្រទេសដើមរបស់ខ្លួនទទួលស្គាល់ឲ្យប្រកបវិជ្ជាជីវៈមេធាវី មានសិទ្ធិចូលរួមប្រកបវិជ្ជាជីវៈជាមួយមេធាវីខ្មែរហើយអមមេធាវីខ្មែរនៅចំពោះមុខតុលាការ ឬស្ថាប័នដទៃទៀតនៃព្រះរាជាណាចក្រ-កម្ពុជា ។ មេធាវីទាំងនោះពុំអាចតំណាងកូនក្ដីបានឡើយ ។

មាត្រា ៦.-

មេធាវីបរទេសអាចប្រកបវិជ្ជាជីវៈនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែមានការយល់ព្រមពីក្រុមប្រឹក្សាគណៈមេធាវីខ្មែរ ផ្អែកលើលក្ខណៈសម្បត្តិគ្រប់គ្រាន់ របស់មេធាវីនោះ ហើយលុះត្រាតែប្រទេសដើមរបស់មេធាវីបរទេសនោះ ផ្ដល់លទ្ធភាពដូចគ្នាដល់មេធាវីខ្មែរផងដែរ ។ ការយល់ព្រមអាចត្រូវដកហូតវិញបាន បើមានការប្រព្រឹត្តិខុសក្នុងការ ប្រកបវិជ្ជាជីវៈលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

សេចក្ដីសម្រេចមិនអនុញ្ញាត ឬដកហូតការអនុញ្ញាតរបស់ក្រុមប្រឹក្សាគណៈមេធាវី មិនឲ្យប្រកបវិជ្ជាជីវៈ ត្រូវជូនដំណឹងក្នុងរយៈពេល ១៥ ថ្ងៃ ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងទៅសាមីខ្លួន ។ សេចក្ដីសម្រេចនេះអាចប្ដឹងឧទ្ធរណ៍បាន ក្នុងរយៈពេល ២ ខែ ក្រោយពីបានទទួលដំណឹង ។

មាត្រា ៧.-

មេធាវីបរទេសដែលត្រូវបានអនុញ្ញាតឲ្យប្រកបវិជ្ជាជីវៈនេះ ពុំអាចធ្វើសកម្មភាព ទាក់ទាញកូនក្តី ឬផ្សព្វផ្សាយពាណិជ្ជកម្មបានឡើយ ។

## ជំពូកទី ២
## ការរៀបចំវិជ្ជាជីវៈមេធាវី
### ផ្នែកទី ១
### គណៈមេធាវី

មាត្រា ៨.-

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាអង្គការប្រមូលផ្តុំមេធាវីទាំងអស់ដែលតាំងការិយាល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ មេធាវីម្នាក់ៗត្រូវជាសមាជិកពេញសិទ្ធិនៃគណៈមេធាវី ក្រោយពីចុះឈ្មោះក្នុងបញ្ជី គណៈមេធាវី ។

មាត្រា ៩.-

គណៈមេធាវីត្រូវបានដឹកនាំដោយប្រធានមួយរូប និងគ្រប់គ្រងដោយក្រុមប្រឹក្សាគណៈមេធាវី ។ ប្រធានគណៈមេធាវី ត្រូវបានបោះឆ្នោតជ្រើសតាំងសំរាប់អាណត្តិ ២ ឆ្នាំ ។ អាណត្តិនេះអាចត្រូវបានបន្តតែមួយអាណត្តិទៀតដោយវិធិបោះឆ្នោត ។

មាត្រា ១០.-

សមាជិកនៃក្រុមប្រឹក្សាគណៈមេធាវីមាន :

- ចំនួន ៥ នាក់ ក្នុងករណីគណៈមេធាវី មានសមាជិកមិនលើសពី ៣០ នាក់
- ចំនួន ៩ នាក់ បើមានសមាជិកពី ៣១ នាក់ ទៅ ៥០ នាក់
- ចំនួន ១៣ នាក់បើមានសមាជិកពី ៥១ នាក់ទៅ ២០០ នាក់
- ចំនួន ១៩ នាក់ បើមាន សមាជិកពី ២០១ នាក់ ទៅដល់ ៥០០ នាក់
- ចំនួន ២៧ នាក់ បើមានសមាជិកពី ៥០១ នាក់ទៅ ១.០០០ នាក់
- ចំនួន ៣៣ នាក់ បើមានសមាជិកលើសពី ១០០១ នាក់ ។

មាត្រា ១១.-

សមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ត្រូវបានបោះឆ្នោតជ្រើសតាំងសំរាប់អាណត្តិ ៣ ឆ្នាំ ។ អាណត្តិនេះអាចបន្តម្តងទៀតបាន ប៉ុន្តែមិនអាចបន្តភ្ជាប់ពីចប់អាណត្តក្តាមនោះទេ ។ ផុតរយៈពេល ៣ ឆ្នាំ ក្រោយពីចប់អាណត្តិ ទើបអតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវី អាចឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសតាំងជាថ្មីបាន ។ ប្រធានគណៈមេធាវី អាចត្រូវបានបោះឆ្នោតជ្រើសតាំងឲ្យធ្វើជាសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវីបានក្រោយបានចប់អាណត្តិរបស់ខ្លួន ដោយមិន បាច់រង់ចាំផុតរយៈពេល ៣ ឆ្នាំទេ ។

មាត្រា ១២.-

បើប្រធានគណៈមេធាវី ឬសមាជិកណាម្នាក់នៃក្រុមប្រឹក្សាគណៈមេធាវីទទួលមរណភាពឬឈប់ពីមុខងារក្នុងអាណត្តិរបស់ខ្លួន នោះត្រូវរៀបចំការបោះឆ្នោតជ្រើសតាំងអ្នកជំនួស ដើម្បីបញ្ចប់អាណត្តិនោះ ។

មាត្រា ១៣.-

គណៈមេធាវីមិនស្ថិតនៅក្រោមគណៈបក្សនយោបាយណាមួយ ឬអង្គការសាសនាណាមួយ ឬអង្គការនានាផ្សេងទៀតឡើយ ។

ការសម្តែងមនោគមវិជ្ជា សាសនា ឬនយោបាយ ត្រូវហាមឃាត់ ។

គណៈមេធាវីមានថវិកាស្វយ័ត ប៉ុន្តែមិនអាចធ្វើសកម្មភាពយកផលចំណេញបានឡើយ ។

## ផ្នែកទី ២

### ការបោះឆ្នោត

មាត្រា ១៤.-

ប្រធានគណៈមេធាវី និងសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ត្រូវបានបោះឆ្នោតជ្រើសតាំងដាច់ដោយឡែកពីគ្នា ក្នុងមហាសន្និបាតនៃគណៈមេធាវី ។ អ្នកដែលមានសិទ្ធិបោះឆ្នោត គឺមេធាវីទាំងអស់ដែលបានចុះឈ្មោះក្នុងបញ្ជីនៃ

គណៈមេធាវី ហើយដែលឥតបានបាត់បង់សិទ្ធិបោះឆ្នោតដោយទណ្ឌកម្ម វិន័យណាមួយឡើយ ។

មាត្រា ១៥.-

អ្នកដែលអាចឈរឈ្មោះឲ្យគេបោះឆ្នោត ជ្រើសតាំងជាប្រធានគណៈមេធាវីបានគឺមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីបានរយៈពេល ៣ ឆ្នាំ យ៉ាងតិច ហើយដែលឥត បានបាត់បង់សិទ្ធិបោះឆ្នោតដោយទណ្ឌកម្មវិន័យណាមួយឡើយ ។

អ្នកដែលអាចឈរឈ្មោះបោះឆ្នោត ជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាគណៈមេធាវីបាន គឺមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីបានរយៈពេល ២ ឆ្នាំយ៉ាងតិចហើយដែលឥតបានបាត់បង់សិទ្ធិបោះឆ្នោតទាំងនោះ ។

មាត្រា ១៦.-

ការបោះឆ្នោតត្រូវបានរៀបចំឡើងដោយមហាសន្និបាតនៃគណៈមេធាវី ២ ឆ្នាំម្តង ចំពោះប្រធានគណៈមេធាវី និង ៣ ឆ្នាំម្តង ចំពោះសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ។

ការបោះឆ្នោតនេះ ត្រូវប្រព្រឹត្តជាសម្ងាត់ និងជាឯកនាមហើយអាចធ្វើជាពីរលើកបាន ។ ការបោះឆ្នោតលើកទី១ប្រព្រឹត្តទៅដោយយកតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិក គណៈមេធាវីទាំងមូល និងលើកទី ២ ដោយយកតាមសម្លេងភាគច្រើននៃសមាជិកវត្តមាន ។ ក្នុងករណីមានសម្លេងស្មើគ្នា មេធាវីដែលមានវ័យចាស់ជាងគេ ត្រូវបានជ្រើសតាំង ។

មាត្រា ១៧.-

បែបបទនៃការបោះឆ្នោត ការកោះអញ្ជើញមករួមប្រជុំ និងកូរ៉ុមត្រូវបានកំណត់ ដោយបទបញ្ជាផ្ទៃក្នុង ។ មេធាវីដែលមានសិទ្ធិបោះឆ្នោត ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចប្តឹងតវ៉ាអំពីការបោះឆ្នោតនេះ ទៅសាលាឧទ្ធរណ៍បាន ។

ពាក្យបណ្តឹងនេះ ត្រូវធ្វើឡើងដោយមេធាវីក្នុងរយៈពេល ១៥ ថ្ងៃក្រោយការបោះឆ្នោត ឬដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្នុងរយៈពេល ១៥ ថ្ងៃ

គិតពីថ្ងៃទទួល ដំណឹងស្តីពីលទ្ធផលនៃការបោះឆ្នោតនោះ ។

## ជំពូកទី ៣
## មហាសន្និបាត

មាត្រា ១៨.-

មហាសន្និបាតសាមញ្ញនៃគណៈមេធាវីប្រព្រឹត្តទៅមួយឆ្នាំម្តង ដែលផ្តើមធ្វើឡើងដោយប្រធានគណៈមេធាវីតាមរបៀបវារៈដែល ត្រូវបានសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី ។

មហាសន្និបាតអាចធ្វើសំណូមពរ ឬញត្តិទៅក្រុមប្រឹក្សាគណៈមេធាវី ដែលត្រូវដោះស្រាយក្នុងរយៈពេល ៣ ខែ ។

មហាសន្និបាតវិសាមញ្ញអាចប្រជុំបាន បើមានមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជី ចំនួន ៣០% បានស្នើសុំដោយមានភ្ជាប់របៀបវារៈជាមួយផង យ៉ាងតិច ១៥ ថ្ងៃ មុនថ្ងៃប្រជុំ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃមហាសន្និបាតគណៈមេធាវី ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី ។

## ជំពូកទី ៤
## ក្រុមប្រឹក្សាគណៈមេធាវី

មាត្រា ១៩.-

ក្រុមប្រឹក្សាគណៈមេធាវីពិនិត្យដោះស្រាយគ្រប់បញ្ហា ដែលពាក់ព័ន្ធទៅការអនុវត្តវិជ្ជាជីវៈមេធាវី ។ ក្រុមប្រឹក្សាគណៈមេធាវីធានាការបំពេញភារកិច្ច និងការពារសិទ្ធិរបស់មេធាវី ។ ក្រុមប្រឹក្សាគណៈមេធាវីមានភារកិច្ចជាអាទិ៍ដូចតទៅ ៖

- ធ្វើបទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌
- សំរេចឲ្យចុះឈ្មោះធ្វើកម្មសិក្សា និងចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី

- សំរេចលើការស្នើសុំអនុញ្ញាតទាំងឡាយដែលធ្វើឡើងដោយមេធាវី
- ពិនិត្យកិច្ចព្រមព្រៀងនិងឯកសារទាំងឡាយដែលមេធាវីមានកាតព្វកិច្ចត្រូវដាក់ឲ្យពិនិត្យហើយបញ្ចេញមតិណែនាំលើកិច្ចព្រមព្រៀង និងឯកសារ ទាំងនោះ
- ត្រួតពិនិត្យការកាន់កាប់ទៀងទាត់នៃបញ្ជីគណៈមេធាវីរបស់មេធាវី
- ធានាការគោរពវិន័យ និងការដាក់វិន័យ
- ធានារ៉ាប់រងការរៀបចំ និងការគ្រប់គ្រងសេវាទូទៅរបស់គណៈមេធាវី
- គ្រប់គ្រងទ្រព្យសម្បត្តិ និងថវិការរបស់គណៈមេធាវី កំណត់ចំនួនទឹកប្រាក់ភាគទានរបស់មេធាវីម្នាក់ៗ និងបង់ប្រាក់ធានារ៉ាប់រងសំរាប់វិជ្ជាជីវៈមេធាវី
- គ្រប់គ្រងបេឡានៃមូលនិធិរបស់គណៈមេធាវី
- បញ្ចេញមតិលើបញ្ហាទាំងឡាយដែលទាក់ទងវិស័យយុត្តិធម៌ និងសិទ្ធិរបស់មេធាវី ក្នុងវិស័យការពារ ជាអាទិ៍នៅពេលដែលមានការអញ្ជើញពីអាជ្ញាធរសាធារណៈ ។

មាត្រា ២០.-

ក្រុមប្រឹក្សាគណៈមេធាវីអាចរួមប្រជុំបាន លុះត្រាតែមានសមាជិករបស់ខ្លួនចូលរួម លើសពីពាក់កណ្តាល ។ ក្រុមប្រឹក្សាគណៈមេធាវីសំរេចសេចក្តីតាមមតិភាគច្រើន ។

មាត្រា ២១.-

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវីដែលមានលក្ខណៈជាបទបញ្ជាត្រូវជូនដំណឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយ មានចុះសេចក្តីថាបានទទួល ។ ចំពោះសេចក្តីសំរេចដាក់វិន័យក៏ដូចជាសេចក្តីសំរេចលើការចុះឈ្មោះ ឬការសុំឲ្យនៅក្រៅបញ្ជីរបស់មេធាវី ក៏ត្រូវធ្វើដូច្នេះដែរ ។ សេចក្តីសំរេចផ្សេងក្នុងវាក្យខ័ណ្ឌខាងលើត្រូវផ្តល់ជាពត៌មានដល់សមាជិកនៃគណៈមេធាវី តាមមធ្យោបាយសមស្រប ។

មាត្រា ២២.-

រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវីលើមេធាវីណាម្នាក់ ត្រូវជូនដំណឹងទៅមេធាវីនោះតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានចុះសេចក្តីថាបានទទួល ។

មាត្រា ២៣.-

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ដែលមិនមែនជាមុខនាទីរបស់ខ្លួនឬផ្ទុយនឹងបទបញ្ញត្តិច្បាប់ជាធរមានឬបទបញ្ជាអាចត្រូវបដិសេធចោល ដោយសាលាឧទ្ធរណ៍ក្រោយពីមានការប្តឹងពីអគ្គព្រះរាជអាជ្ញារមសាលាឧទ្ធរណ៍ ។

មាត្រា ២៤.-

មេធាវីអាចប្តឹងអំពីសេចក្តីសំរេចណាមួយរបស់ក្រុមប្រឹក្សាគណៈមេធាវីដែលធ្វើឲ្យ ខាតប្រយោជន៍ដល់វិជ្ជាជីវៈរបស់ខ្លួនបាន ។ បើសេចក្តីសំរេចឥតត្រូវបានឲ្យដំណឹងដល់មេធាវី មេធាវីនោះត្រូវសុំឲ្យក្រុមប្រឹក្សាគណៈមេធាវីពិនិត្យសេចក្តីសំរេចនោះសាជាថ្មីម្តងទៀតមុននឹងប្តឹង ។ ក្រុមប្រឹក្សាគណៈមេធាវីត្រូវសំរេចលើសេចក្តីស្នើសុំនោះក្នុងរយៈពេល ២ ខែ ក្រោយពីបានអញ្ជើញមេធាវីនោះឲ្យបញ្ចេញយោបល់របស់ខ្លួន ។ សេចក្តីសំរេចថ្មីត្រូវបានជូនដំណឹងទៅសាមីខ្លួន ។ បើគ្មានការសំរេចសាជាថ្មីក្នុងរយៈពេលដូចកំណត់ខាងលើនេះទេ ត្រូវចាត់ទុកសេចក្តីសំរេចមុននោះជាអសាបង់ ។

មាត្រា ២៥.-

ពាក្យបណ្តឹងទាំងឡាយមិនសុខចិត្តនឹងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ត្រូវបញ្ជូនទៅសាលាឧទ្ធរណ៍ ។ គេអាចដាក់ពាក្យបណ្តឹងទៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ឬតាមលិខិតអនុសិដ្ឋមានចុះសេចក្តីថាបានទទួល ។ រយៈពេលប្តឹងឧទ្ធរណ៍គឺ ២ ខែ ចាប់ពីថ្ងៃទទួលដំណឹង ។

មាត្រា ២៦.-

ក្រុមប្រឹក្សាគណៈមេធាវីត្រូវដាក់ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ

និងផ្សព្វផ្សាយជាសាធារណៈជារៀងរាល់ឆ្នាំ នូវរបាយការណ៍សំអិតស្តីពីសកម្មភាពការងាររបស់គណៈមេធាវី ។ ក្រុមប្រឹក្សាគណៈមេធាវីត្រូវបង្ហាញស្ថានភាពហិរញ្ញវត្ថុនិងផ្តល់ព័ត៌មានផ្សេងៗជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បើមានសំណូមពរពីក្រសួងនេះ ។

## ផ្នែកទី ៥
## ប្រធានគណៈមេធាវី

**មាត្រា ២៧.-**

ប្រធានគណៈមេធាវីមានតួនាទី ៖

- ជាអ្នកដឹកនាំគណៈមេធាវី
- ជាអធិបតីនៃមហាសន្និបាតគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវី
- ជាអ្នកធានាផលប្រយោជន៍វិជ្ជាជីវៈ និងផលប្រយោជន៍របស់សមាជិកទាំងអស់
- ជាអ្នកផ្សះផ្សា ហើយបើមានការចាំបាច់និងតាមសំណើរបស់គូភាគី ធ្វើអាជ្ញាកណ្តាល ក្នុងវិវាទដែលកើតឡើងរវាងមេធាវីនិងមេធាវី រវាងមេធាវីនិងអតិថិជន
- ជាតំណាងវិជ្ជាជីវៈមេធាវីចំពោះមុខតតិយជននិងអាជ្ញាធរសាធារណៈ
- ជាតំណាងគណៈមេធាវីក្នុងរឿងក្តីដែលទាក់ទងគណៈមេធាវីក្រោយពីមានការអនុញ្ញាតពីក្រុមប្រឹក្សាគណៈមេធាវី ។

ក្នុងការបោះឆ្នោត សំឡេងរបស់ប្រធានគណៈមេធាវីឥតមានឧត្តមានុភាពទេ ។

**មាត្រា ២៨.-**

ប្រធានគណៈមេធាវីអាចផ្ទេរអំណាចណាមួយ ឬអំណាចទាំងអស់ទៅឲ្យសមាជិកណាម្នាក់ ឬច្រើននាក់នៃក្រុមប្រឹក្សាគណៈមេធាវីបាន ក្នុងរយៈពេលមានកំណត់ ។

ក្នុងករណីមានធុរៈ ប្រធានគណៈមេធាវីត្រូវជំនួសដោយសមាជិកនៃ

ក្រុមប្រឹក្សា គណៈមេធាវី ដែលមានវ័យចាស់ជាងគេ ។

## ផ្នែកទី ៦
## មូលនិធិនៃគណៈមេធាវី

មាត្រា ២៩.-

មូលនិធិនៃគណៈមេធាវីបានមកពីការបង់ភាគទាននៃសមាជិកទាំងអស់ និង វិភាគទានផ្សេងៗ ។ នៅក្នុងមូលនិធិនេះត្រូវបង្កើតឲ្យមានបេឡាពិសេសមួយ សំរាប់ផ្តល់ប្រាក់កំរៃ ដល់មេធាវីដែលការពារជនក្រីក្រ ។

បេឡាពិសេសនេះអាចទទួលអំណោយ ឬប្រាក់ជំនួយដែលឯកជន អង្គការ អន្តរជាតិ ឬរដ្ឋាភិបាលនៃប្រទេសផ្សេងៗ ផ្តល់មកឲ្យដើម្បីការពារជនក្រីក្រ ។

មេធាវីទាំងអស់មានកាតព្វកិច្ចជួយការពារជនក្រីក្រ តាមបែបបទនៃបទបញ្ជាផ្ទៃក្នុង ហើយឲ្យដូចជាជួយការពារអតិថិជនរបស់ខ្លួន ។

មាត្រា ៣០.-

ដែលហៅថាជនក្រីក្រ គឺជនដែលគ្មានទ្រព្យសម្បត្តិ គ្មានប្រាក់ចំណូល ឬដែលមានប្រាក់ចំណូលមិនគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់ជីវភាព ។

ការកំណត់អំពីភាពក្រីក្រ ត្រូវធ្វើឡើងដោយប្រធានតុលាការ និងក្រឡាបញ្ជី នាយកក្រោយពីបានធ្វើការស៊ើបអង្កេតដល់មូលដ្ឋាន ។

# ជំពូកទី ៣
## ការទទួលឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី បញ្ជីគណៈមេធាវី

### ផ្នែកទី ១
### លក្ខខណ្ឌ

មាត្រា ៣១.-

ជនដែលអាចចូលប្រកបវិជ្ជាជីវៈជាមេធាវីបាន ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមនេះ ៖

១- ត្រូវមានសញ្ជាតិជាខ្មែរ

២- ត្រូវមានបរិញ្ញាប័ត្រច្បាប់ ឬសញ្ញាប័ត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមមូល ។

៣- ត្រូវមានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ។ វិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវីនេះត្រូវចេញឲ្យដោយមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

៤- មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ ឬ ផ្តន្ទាទោសជាបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ ។ មិនត្រូវមានធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

មាត្រា ៣២.-

មិនចាំបាច់មានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងមិនចាំបាច់មានបរិញ្ញាប័ត្រច្បាប់ ៖

- ចៅក្រម ដែលបានបំពេញការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ៥ ឆ្នាំ និងអតីតចៅក្រម ដែលមានសញ្ញាប័ត្រមធ្យមសិក្សាច្បាប់ហើយដែលបានបំរើក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ២ ឆ្នាំ ។

មិនចាំបាច់មានវិញ្ញាបនប័ត្រខាងវិជ្ជាជីវៈមេធាវី ៖

- អ្នកមានបរិញ្ញាបត្រច្បាប់ ហើយដែលបានបំពេញការងារក្នុងវិស័យច្បាប់ ឬតុលាការ លើសពី ២ ឆ្នាំ
- មេធាវីដែលមានសញ្ជាតិដើមជាខ្មែរ ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី នៅប្រទេស ក្រៅ
- អ្នកមានសញ្ញាបត្របណ្ឌិតច្បាប់ ។

## ផ្នែកទី ២
## ការទទួលឱ្យប្រកបវិជ្ជាជីវៈមេធាវី

មាត្រា ៣៣.-

ការយល់ព្រមឲ្យប្រកបវិជ្ជាជីវៈមេធាវីត្រូវសំរេចដោយក្រុមប្រឹក្សាគណៈ មេធាវី ក្រោយពីបានត្រួតពិនិត្យលើការបំពេញល័ក្ខខ័ណ្ឌសព្វគ្រប់ដែលមាន កំណត់ក្នុងច្បាប់នេះនិងក្រោយពីមានយោបល់របស់អគ្គព្រះរាជអាជ្ញាអមសាលា ឧទ្ធរណ៍ ។

សេចក្តីសំរេចត្រូវឲ្យដំណឹងដល់សាមីខ្លួន និងដល់អគ្គព្រះរាជអាជ្ញាអម សាលាឧទ្ធរណ៍ ។

ក្រុមប្រឹក្សាគណៈមេធាវីមិនអាចសំរេចមិនយល់ព្រមដោយគ្មានការកោះ អញ្ជើញសាមីខ្លួនឲ្យចូលមកបញ្ចេញយោបល់ជាមុនយ៉ាងតិច១០ថ្ងៃបានឡើយ ។ ការកោះអញ្ជើញនេះ ត្រូវធ្វើតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយ មានសេចក្តីបញ្ជាក់ថាបានទទួល ។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី អាចត្រូវបានប្តឹងតវ៉ាតាម ល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងមាត្រា ២៥ ខាងលើ ។

មាត្រា ៣៤.-

មេធាវីដែលត្រូវបានទទួលឲ្យប្រកបវិជ្ជាជីវៈ ត្រូវធ្វើសច្ចាប្រណិធានជាមុននៅ ចំពោះមុខសាលាឧទ្ធរណ៍ ដោយមានវត្តមានប្រធានគណៈមេធាវី ហើយដែល មានសេចក្តីដូច តទៅ ៖

"ខ្ញុំសូមសច្ចាប្រណិធានថា នឹងអនុវត្តវិជ្ជាជីវៈរបស់ខ្ញុំ ដោយសេចក្តីថ្លៃថ្នូរ ដោយសតិសម្បជញ្ញៈ ដោយសេចក្តីទៀងត្រង់ ដោយមនុស្សធម៌

ដោយស្មារតីឯករាជ្យ និងដោយគោរពវិជ្ជាជីវៈ និងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី ៣
## កម្មសិក្សា

**មាត្រា ៣៥.-**

មេធាវីដែលទើបបានចុះឈ្មោះ ត្រូវធ្វើកម្មសិក្សារយៈពេល ១ ឆ្នាំ តាមបែបបទ ដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវី លើកលែងតែមេធាវីណាដែលមានការអនុញ្ញាតឲ្យរួចផុតពីកម្មសិក្សា ។ បែបបទនៃកម្មសិក្សាមានជាអាទិ៍ដូចតទៅ ៖

- ត្រូវទទួលការបំពាក់បំប៉នជាបន្ថែម ដែលរៀបចំឡើងដោយគណៈមេធាវី
- ត្រូវចូលរួមបំពេញការងារឲ្យពិតប្រាកដជាសហការីក្នុងការិយាល័យមេធាវីណាមួយ ។

**មាត្រា ៣៦.-**

កម្មសិក្សាប្រព្រឹត្តទៅក្រោមការត្រួតពិនិត្យរបស់មេធាវីម្នាក់ដែលក្រុមប្រឹក្សាគណៈមេធាវីចាត់តាំងជាប្រធានទទួលខុសត្រូវលើកម្មសិក្សានោះ ។

**មាត្រា ៣៧.-**

ក្រោយបញ្ចប់កម្មសិក្សា ក្រុមប្រឹក្សាគណៈមេធាវីសំរេចពីការចុះឈ្មោះក្នុងបញ្ជី គណៈមេធាវីដោយផ្អែកលើរបាយការណ៍របស់ប្រធានទទួលខុសត្រូវលើកម្មសិក្សា ។ ក្រុមប្រឹក្សាគណៈមេធាវី អាចសំរេចឲ្យធ្វើកម្មសិក្សាបន្តទៀតបានតែមិនឲ្យលើសពី ១ ឆ្នាំ ឡើយ ចំពោះកម្មសិក្សាការីណាដែលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ ។ ការសំរេចមិនចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាត់ទុកជាការលុបឈ្មោះមេធាវីនោះចោល ។ ការសំរេចមិនចុះឈ្មោះក្នុងបញ្ជីឬការ បន្តកម្មសិក្សា ពុំអាចធ្វើទៅបានឡើយបើគ្មានការកោះអញ្ជើញសាមីខ្លួនឲ្យមកបញ្ចេញយោបល់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៣៣

សេចក្តីសំរេចនេះអាចនឹងប្តឹងតវ៉ាបានតាមលក្ខខ័ណ្ឌ និងនីតិវិធីដែលមានចែង ក្នុងមាត្រា ២៤ និង ២៥ ។

មាត្រា ៣៨.-

រៀលរាល់ឆ្នាំ ក្រុមប្រឹក្សាគណៈមេធាវីបញ្ចប់បញ្ជីគណៈមេធាវី និងបញ្ជីមេធាវីកម្មសក្សា ហើយផ្ញើបញ្ជីនោះជូនអគ្គព្រះរាជអាជ្ញា និងសាលាជម្រះក្តីទាំងអស់ ។

បញ្ជីនោះមានដូចតទៅ ៖

- ឈ្មោះមេធាវីដែលបានចុះក្នុងបញ្ជីគណៈមេធាវី និងអាស័យដ្ឋានរបស់មេធាវីនោះ
- ឈ្មោះ និងអាស័យដ្ឋានរបស់មេធាវីកម្មសិក្សា ។

មាត្រា ៣៩.-

លេខរៀងនៃការចុះឈ្មោះរបស់មេធាវី ត្រូវកំណត់តាមកាលបរិច្ឆេទដែលបានធ្វើសច្ចាប្រណិធានហើយត្រូវបានកំណត់ដោយ ក្រុមប្រឹក្សាគណៈមេធាវីដែលបានសំរេចឲ្យចុះឈ្មោះ ។

## ផ្នែកទី ៤
## ការដាក់នៅក្រៅបញ្ជី

មាត្រា ៤០.-

ដោយមានមូលហេតុសមស្រប មេធាវីអាចសុំនៅក្រៅបញ្ជីនៃគណៈមេធាវីបាន សំរាប់រយៈពេលពីរឆ្នាំម្តងៗជាអតិបរមា ។

មាត្រា ៤១.-

ក្រុមប្រឹក្សាគណៈមេធាវីអាចសំរេចដាក់មេធាវីណាម្នាក់នៅក្រៅបញ្ជី បើមេធាវីនោះ ស្ថិតនៅក្នុងស្ថានភាពវិសមិតភាព ឬបើមេធាវីនោះពុំអាចប្រកបវិជ្ជាជីវៈ របស់ខ្លួនបាន ។

ក្នុងករណីមានបណ្ដឹងមិនសុខចិត្តនឹងសេចក្ដីសំរេចខាងលើនោះ ត្រូវអនុវត្ត នីតិវិធី ដែលមានចែងក្នុងមាត្រា ៣៣ ។

មាត្រា ៤២.-

មេធាវីដែលត្រូវបានដាក់ឲ្យនៅក្រៅបញ្ជី ពុំអាចប្រកបវិជ្ជាជីវៈរបស់ខ្លួន ហើយក៏ពុំអាចប្រើប្រាស់ឋានៈជាមេធាវីបានឡើយ និងត្រូវបានរួចពីកាតព្វកិច្ច ទាំងឡាយដែលទាក់ទងទៅ នឹងវិជ្ជាជីវៈនេះ ក៏ប៉ុន្តែត្រូវស្ថិតនៅក្រោម ការគ្រប់គ្រងរបស់គណៈមេធាវី ។

ការដាក់ឲ្យនៅក្រៅបញ្ជីពុំអាចរារាំងការចោទប្រកាន់ខាងវិន័យឡើយ ។

## ផ្នែកទី ៥
## ឋានៈជាមេធាវីកិត្តិយស

មាត្រា ៤៣.-

ក្រុមប្រឹក្សាគណៈមេធាវីអាចផ្ដល់ងារជាមេធាវីកិត្តិយសជូនមេធាវីដែលឈប់ ប្រកបវិជ្ជាជីវៈមេធាវី ក្រោយពីបានប្រកបវិជ្ជាជីវៈរយៈពេល ១៥ ឆ្នាំយ៉ាងតិច ។

មាត្រា ៤៤.-

មេធាវីកិត្តិយសនៅតែជាសមាជិកនៃគណៈមេធាវីដដែល ហើយអាចចូលរួម ក្នុងមហាសន្និបាតមេធាវី មានសិទ្ធិផ្ដល់យោបល់ ព្រមទាំងចូលរួមក្នុង ពិធីផ្សេងៗ ។

ដោយឡែក មេធាវីកិត្តិយសអាចផ្ដល់យោបល់ដល់អតិថិជន ហើយអាច ត្រូវបានចាត់តាំងជាអ្នកផ្សះផ្សា ជាអ្នកសម្រុះសម្រួល ឬជាអ្នកអាជ្ញាកណ្ដាល ។

មាត្រា ៤៥.-

ក្រុមប្រឹក្សាគណៈមេធាវី អាចដកហូតងារជាមេធាវីកិត្តិយសនេះបាន បើមានហេតុដែលធ្វើឲ្យប៉ះពាល់ដល់កិត្តិយស ឬសេចក្ដីថ្លៃថ្នូររបស់មេធាវីនោះ ។ ក្នុងករណីនេះត្រូវអនុវត្តនីតិ វិធី ដែលមានចែងក្នុងមាត្រា ៣៣ ។

# ជំពូកទី ៤
## បែបបទនៃការប្រកបវិជ្ជាជីវៈ

## ផ្នែកទី ១
### ការប្រកបវិជ្ជាជីវៈមេធាវីជាឯកត្តជន ឬជាសមូហភាព

**មាត្រា ៤៦.-**

មេធាវីអាចប្រកបវិជ្ជាជីវៈជាឯកត្តជនបាន ឬនៅក្នុងក្របខ័ណ្ឌជាក្រុម ឬក្រុមហ៊ុនមេធាវីណាមួយដែលបង្កើតឡើងត្រឹមត្រូវតាមច្បាប់ ។

ក្រុមហ៊ុននេះត្រូវមានលក្ខណៈជាក្រុមហ៊ុនស៊ីវិល ហើយមានសុទ្ធតែមេធាវីជាសមាជិក ។ មេធាវីកិត្តិយសអាចនៅជាសមាជិកនៃក្រុមហ៊ុនដើមរបស់ខ្លួនបាន ។

សិទ្ធិវន្ត គឺអ្នកដែលមានសិទ្ធិទទួលមរតកពីមេធាវី ដែលបានទទួលមរណភាពអាចបន្តកាន់កាប់ភាគហ៊ុននោះបានក្នុងរយៈពេល ៣ឆ្នាំជាអតិបរមា ។ ផុតរយៈពេល ៣ ឆ្នាំ នោះ ត្រូវលក់ភាគហ៊ុននោះទៅឲ្យមេធាវីណាម្នាក់ឬទៅឲ្យក្រុមហ៊ុននោះវិញ ។

**មាត្រា ៤៧.-**

ក្រុម និងក្រុមហ៊ុនមេធាវីទាំងឡាយ ត្រូវបានគ្រប់គ្រងដោយច្បាប់គ្រប់គ្រងក្រុមនិងក្រុមហ៊ុន លើកលែងតែបទបញ្ញត្តិនៃបទបញ្ជានោះប៉ះពាល់ដល់គោលការណ៍គ្រប់គ្រងវិជ្ជាជីវៈមេធាវី ។

**មាត្រា ៤៨.-**

មេធាវីទាំងឡាយត្រូវបានអនុញ្ញាតឲ្យចុះកិច្ចព្រមព្រៀងជាមួយសមាជិកនៃវិជ្ជាជីវៈសេរីដទៃទៀត ដើម្បីប្រមូលផ្តុំមធ្យោបាយជាមួយគ្នា ។ ការធ្វើកិច្ចព្រមព្រៀងនេះមិនត្រូវឲ្យប៉ះពាល់ដល់វិធាននៃវិជ្ជាជីវៈមេធាវី ជាអាទិ៍ប៉ះពាល់ដល់ការគោរពការសម្ងាត់នៃវិជ្ជាជីវៈនេះ ។

មាត្រា ៤៩.-

រាល់កិច្ចព្រមព្រៀងដែលមេធាវីខ្មែរណាម្នាក់បានចុះជាមួយមេធាវីខ្មែរណាម្នាក់ទៀត ឬជាមួយមេធាវីបរទេស ឬក៏ជាមួយសមាជិកនៃវិជ្ជាជីវៈសេរីណាមួយ ត្រូវតែដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងយល់ព្រម ហើយជូនពត៌មានដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ ក្នុងករណីនេះត្រូវអនុវត្តនីតិវិធីដែលមានចែងក្នុងមាត្រា ៣៣ ។

## ផ្នែកទី ២
## កិច្ចសហការ

មាត្រា ៥០.-

មេធាវីអាចប្រកបវិជ្ជាជីវៈក្នុងលក្ខណៈជាសហការីរបស់មេធាវីម្នាក់ទៀត ។

មាត្រា ៥១.-

មេធាវីជាសហការីបំពេញកិច្ចការផ្សេងៗក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់សហភាគា ។ គេពុំអាចបំពេញកិច្ចការបានទេ បើគ្មានការយល់ព្រមពីសហភាគា ប៉ុន្តែគេមានសិទ្ធិពេញទីក្នុងការជ្រើសរើសមធ្យោបាយធ្វើការងាររបស់គេ។គេអាចសុំមិនទទួលបំពេញ បេសកកម្មណាមួយ ដែលគេយល់ថាផ្ទុយនឹងសម្បជញ្ញៈរបស់គេ ។

មាត្រា ៥២.-

ក្នុងករណីណាក៏ដោយ កិច្ចសហការមិនអាចរារាំងមិនឲ្យសហការីមេធាវីបង្កើតការិយាល័យផ្ទាល់របស់គេ ឬរារាំងមិនឲ្យគោរពកាតព្វកិច្ចនិងវិធាននៃវិជ្ជាជីវៈមេធាវីបានឡើយ ។ គេធ្វើការក្នុងនាមគេផ្ទាល់ កាលណាគេការពារកូនក្តីគេផ្ទាល់ខ្លួន ។

កិច្ចសន្យានៃកិច្ចសហការត្រូវរៀបចំឡើង ហើយផ្ញើជូនក្រុមប្រឹក្សាគណៈមេធាវី ។

# ជំពូកទី ៥
## វិធាននៃវិជ្ជាជីវៈ បទវិន័យ

### ផ្នែកទី ១
### វិសមិតភាព

មាត្រា ៥៣.-

វិជ្ជាជីវៈមេធាវីមានវិសមិតភាពជាមួយនឹងមុខងារសាធារណៈ និងការប្រកបមុខរបរពាណិជ្ជកម្ម ទោះការប្រកបនោះដោយប្រយោលក្តី ឬដោយផ្ទាល់ក្តី ។

មាត្រា ៥៤.-

មេធាវីដែលបានទទួលតួនាទីក្នុងរាជរដ្ឋាភិបាល ឬទទួលអាណត្តិជាអ្នកតំណាងរាស្ត្រនៃរដ្ឋសភា អាចនៅជាសមាជិកនៃគណៈមេធាវីបាន ប៉ុន្តែត្រូវឈប់ប្រកបវិជ្ជាជីវៈនេះរហូតដល់ចប់តួនាទី ឬអាណត្តិនោះ ។

មាត្រា ៥៥.-

មេធាវីដែលជាអតីតមន្ត្រីរាជការ អាចធ្វើបទអន្តរាគមន៍ការពារក្តីប្រឆាំងនឹងក្រសួងមន្ទីររដ្ឋបាលដែលខ្លួនស្ថិតនៅក្រោមឱវាទពីមុនបាន លុះត្រាតែផុតរយៈពេល ៥ ឆ្នាំ គិតពីថ្ងៃឈប់ពីមុខងាររបស់ខ្លួន ។

### ផ្នែកទី ២
### បទវិន័យ

មាត្រា ៥៦.-

វិធាននៃវិជ្ជាជីវៈមេធាវីត្រូវបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវី ។ វិធាននេះធានាការគោរពដោយមេធាវីនូវគោលការណ៍ទាំងឡាយនៃសច្ចាប្រណិធានរបស់ខ្លួន ។

មាត្រា ៥៧.-

គ្រប់អំពើទាក់ទាញ ប្រកាសផ្សាយជាឯកត្តជន ឬទទូចសុំការពាររបស់មេធាវី ចំពោះអតិថិជនត្រូវហាមឃាត់ ។

មានតែការប្រកាសផ្សាយវិជ្ជាជីវៈជាសមូហភាពទេ ដែលអនុញ្ញាតឲ្យធ្វើបាន ។ ការប្រកាសផ្សាយនេះ ត្រូវធ្វើឲ្យបានត្រឹមត្រូវ ហើយមិនត្រូវឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មេធាវី ឡើយ ។

មាត្រា ៥៨.-

មេធាវីត្រូវតែរក្សាការសម្ងាត់ជាដាច់ខាត ។ មេធាវីកំណត់តាមសតិសម្បជញ្ញៈរបស់ខ្លួន និងដោយមានការយល់ព្រមពីអតិថិជនផងនូវអ្វីដែលខ្លួនត្រូវលើកឡើង ដើម្បីការពារ ផលប្រយោជន៍របស់អតិថិជនដែលខ្លួនទទួលបន្ទុក ។

មេធាវីពុំអាចបំពារបំពានលើការសម្ងាត់នៃវិជ្ជាជីវៈបានឡើយ ហើយក៏មិនអាច ត្រូវបានបង្ខំឲ្យបំពារបំពានលើការសម្ងាត់នៃវិជ្ជាជីវៈរបស់ខ្លួនទោះបីនៅមុខតុលាការក៏ដោយ ។

ត្រូវទុកជាការសម្ងាត់នៃវិជ្ជាជីវៈ ការពិគ្រោះយោបល់ និងការផ្តល់យោបល់ ឯកសារក្រៅផ្លូវការទាំងឡាយ ដែលមេធាវីតាក់តែងឡើងសំរាប់អតិថិជន របស់ខ្លួន លិខិតស្នាមទាំងឡាយដែលមេធាវី និងអតិថិជនរបស់ខ្លួន លិខិតស្នាមទាំងឡាយដែលមេធាវី និងអតិថិជន ផ្ញើទាក់ទងគ្នា ។

## ផ្នែកទី ៣
## ទណ្ឌកម្មជាបទវិន័យ

មាត្រា ៥៩.-

ត្រូវទទួលទណ្ឌកម្មជាបទវិន័យ ចំពោះមេធាវីណាដែលប្រព្រឹត្តល្មើសនឹងវិធាននៃវិជ្ជាជីវៈ ឬប្រព្រឹត្តអំពើណាមួយដែលប៉ះពាល់ដល់សីលធម៌ ឬកិត្តិយសមេធាវី ទោះបីប្រព្រឹត្តក្រៅពីការប្រកបវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ ។

មាត្រា ៦០.-

ការចោទប្រកាន់ត្រូវបានធ្វើឡើងដោយក្រុមប្រឹក្សាគណៈមេធាវីខ្លួនឯងផ្ទាល់ ឬដោយមានពាក្យបណ្តឹងពីតតិយជន ឬដោយមានពាក្យបណ្តឹងពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ ក្រុមប្រឹក្សាគណៈមេធាវីចាត់មេធាវីម្នាក់ឲ្យធ្វើជាអ្នករាយការណ៍ ។ ការប្តឹងត្រូវជូនដំណឹងជាមុនទៅសាមីខ្លួនដែលត្រូវដឹងពីសំណុំរឿងនៃការប្តឹងនោះ និងអាចបញ្ចេញយោបល់ការពារខ្លួនបាន ។ បើមានការស៊ើបអង្កេត ក៏ត្រូវផ្តល់ពត៌មាននោះទៅសាមីខ្លួនដែរ ។ របាយការណ៍ត្រូវផ្ញើជូនសាមីខ្លួនជាមួយនឹងលិខិតកោះអញ្ជើញ ហើយសំណុំរឿងក៏ត្រូវដាក់ឲ្យ សាមីខ្លួនពិនិត្យដែរ ។ លិខិតកោះអញ្ជើញត្រូវតែផ្ញើតាមលិខិតអនុសិដ្ឋដោយមានចុះសេចក្តីថា បានទទួល ឬជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១៥ ថ្ងៃ យ៉ាងតិចមុនថ្ងៃប្រជុំ ។ សាមីខ្លួនអាចជ្រើសរើសយកមេធាវីម្នាក់ឲ្យការពារខ្លួនបាន ។ ប៉ុន្តែសាម័ខ្លួនពុំអាចអវត្តមានដោយ ឲ្យជនណាម្នាក់ធ្វើជាតំណាងជួសខ្លួនបានឡើយ បើគ្មានការអនុគ្រោះយល់ព្រមជាពិសេស ជាមុនដោយមានមូលហេតុសមស្របទេ ។

បើគ្មានការឆ្លើយតបទៅនឹងបណ្តឹងរបស់អគ្គព្រះរាជអាជ្ញា ឬរបស់តតិយជនក្នុង រយៈពេល ២ ខែទេ ការមិនឆ្លើយតបពីក្រុមប្រឹក្សាគណៈមេធាវីត្រូវចាត់ទុកជាការបដិសេធបណ្តឹងនោះ ។ ការបដិសេធនេះអាចត្រូវបានប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ២ ខែ ចាប់ពីថ្ងៃផុតរយៈ ពេល ២ ខែខាងលើ ។

មាត្រា ៦១.-

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវីដែលមានមូលហេតុច្បាស់លាស់ត្រូវបានជូនដំណឹងទៅសាមីខ្លួន និងអគ្គព្រះរាជអាជ្ញាក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសំរេចតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានចុះសេចក្តីថាបានទទួល ។

មាត្រា ៦២.-

ការប្តឹងឧទ្ធរណ៍អាចធ្វើឡើងដោយសាមីខ្លួន ឬដោយអគ្គព្រះរាជអាជ្ញាទៅសាលាឧទ្ធរណ៍ក្នុងថិរៈវេលា និងតាមទម្រង់ដែលមានចែងក្នុងមាត្រា ២៥ ។ បណ្តឹងឧទ្ធរណ៍ត្រូវជំនុំជំរះជាសម្ងាត់ លើកលែងតែមានសេចក្តីសំរេចផ្ទុយ

ពីនេះរបស់សហេមេឧទរណ៍ តាមការស្នើសុំច្បាស់លាស់ពីមេធាវីដែលត្រូវចោទ ។ គណៈមេធាវីមិនមែនជាភាគីក្នុងរឿងក្តីនេះទេ ប៉ុន្តែប្រធានគណៈមេធាវីត្រូវតែបញ្ចេញយោបល់កត់សំគាល់របស់ខ្លួន ហើយអគ្គព្រះរាជអាជ្ញាត្រូវធ្វើការសន្និដ្ឋាននៅពេលនោះ ។

មាត្រា ៦៣.-

ទណ្ឌកម្មជាបទវិន័យ មានដូចតទៅ ៖

- ការព្រមាន
- ការស្តីបន្ទោស
- ការហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈពេលដែលពុំអាចលើសពី ២ ឆ្នាំ
- ការលុបឈ្មោះចោលពីបញ្ជីនៃគណៈមេធាវី ឬពីបញ្ជីនៃមេធាវីកម្មសិក្សា ឬការ ហូតងារកិត្តិយស ។

មាត្រា ៦៤.-

ទោសហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈពេលអាចព្យួរបាន ។ ប៉ុន្តែបើក្នុងរយៈពេល ៥ ឆ្នាំ ក្រោយពីបានប្រកាសទោសព្យួរនេះ មេធាវីនោះត្រូវបានផ្តន្ទាទោសវិន័យថ្មីមួយទៀត ក្នុងករណីនេះត្រូវអនុវត្តទោសហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈដោយយកទោសថ្មីទៅបូកជាមួយ ទោសចាស់ដែលបានព្យួរ ។

មាត្រា ៦៥.-

គ្រប់ទណ្ឌកម្ម អាចត្រូវបានបន្ថែមទណ្ឌកម្មហាមឃាត់មិនឲ្យបំពេញជាប្រធានគណៈមេធាវី ឬជាសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ក្នុងរយៈពេលមិនលើសពី ៥ ឆ្នាំ ។ សេចក្តីសំរេចដាក់ទណ្ឌកម្មនេះត្រូវកំណត់ផងដែរ អំពីការផ្សាយជាសាធារណៈ បើជាការចាំបាច់ត្រូវផ្សាយ ។

មាត្រា ៦៦.-

ក្រុមប្រឹក្សាគណៈមេធាវីអាចផ្អាកពីមុខងារជាបណ្តោះអាសន្ន ចំពោះមេធាវីណា ដែលបានត្រូវចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ឬពីបទវិន័យណាមួយដោយបញ្ញត្តិ ឬតាមបណ្តឹងរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ បើគ្មាន

សេចក្តីសម្រេចពីក្រុមប្រឹក្សាគណៈមេធាវីឆ្លើយ តបទៅនឹងការការប្តឹងរបស់អគ្គព្រះរាជអាជ្ញាក្នុងរយៈពេល ២០ ថ្ងៃ នោះនឹងត្រូវចាត់ទុកជាការបដិសេធបណ្តឹងនោះ ។

មាត្រា ៦៧.-

ការផ្អាកពីមុខងារជាបណ្តោះអាសន្នពុំអាចសម្រេចបានឡើយ បើគ្មានការកោះអញ្ជើញសាមីខ្លួនឲ្យចូលមកបញ្ចេញយោបល់របស់ខ្លួន ។ ការកោះអញ្ជើញត្រូវធ្វើឡើងតាមរយៈលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានចុះសេចក្តីថាបានទទួលហើយដែលត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងតិច ៥ ថ្ងៃ មុនថ្ងៃប្រជុំ ។ ការផ្អាកពីមុខងារជាបណ្តោះអាសន្នអាច ត្រូវប្តឹងឧទ្ធរណ៍បានក្នុងលក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦២ ។ ការប្តឹងឧទ្ធរណ៍ពុំអាចផ្អាកការអនុវត្តន៍សេចក្តីសម្រេចខាងលើបានឡើយ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធានា និងឃ្លាំមើលការអនុវត្តន៍ទណ្ឌកម្មខាងវិន័យ និងការផ្អាកពីមុខងារជាបណ្តោះអាសន្ន ។

## ផ្នែកទី ៤
## កំរៃ

មាត្រា ៦៨.-

មេធាវីទទួលកំរៃទៅតាមការឯកភាពគ្នាជាមួយអតិថិជន តាមទំហំការងារ តាមទំហំ សមត្ថភាពដែលបានបញ្ចេញក្នុងការងារនោះ តាមការលំបាកនៃការងារ តាមលទ្ធផលដែលសម្រេចបាន ឬតាមតារាងប្រាក់ម៉ោងកំណត់ដោយ គណៈមេធាវីរៀងរាល់ឆ្នាំ ។ មេធាវីត្រូវចេញបង្កាន់ដៃ ឲ្យអតិថិជននៅពេលបានប្រាក់កំរៃ ។

មាត្រា ៦៩.-

ការតវ៉ាអំពីកំរៃ ក្រៅពីប្តឹងទៅតាមនីតិវិធីរដ្ឋប្បវេណី អាចប្តឹងទៅប្រធានគណៈមេធាវីជាអាជ្ញាកណ្តាលសម្រេចបាន បើមានការយល់ព្រមពីភាគីទំនាស់ ។ សេចក្តីសម្រេចត្រូវឲ្យដំណឹងទៅសាមីខ្លួន តាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់

ផ្ទាល់ដៃដោយមានចុះសេចក្តីថាបានទទួល ។ បណ្តឹងឧទ្ធរណ៍ត្រូវធ្វើក្នុងរយៈពេល ២ ខែ ក្រោយថ្ងៃទទួលបណ្តឹង ។ ពាក្យបណ្តឹងត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ឬផ្ញើតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ ផ្ទាល់ដៃដោយមានចុះសេចក្តីថាបានទទួល ។ បណ្តឹងឧទ្ធរណ៍នេះត្រូវជំនុំជំរះដោយប្រធានសាលាឧទ្ធរណ៍ ឬដោយអ្នកទទួលសិទ្ធិពីប្រធានសាលាឧទ្ធរណ៍ ។

## ជំពូកទី ៦

## គណនេយ្យ ការប្រើប្រាស់មូលនិធិ

## ការធានា ប្រាក់ធានារ៉ាប់រង

មាត្រា ៧០.-

មេធាវីដែលបានចុះឈ្មោះនៅក្នុងបញ្ជីគណៈមេធាវី មិនអាចត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់មូលនិធិរបស់អតិថិជន ឬមូលនិធិទុកសំរាប់អតិថិជនក្នុងពេលដែលខ្លួនបំពេញបេសកកម្មឲ្យអតិថិជនទេ ។ មូលនិធិនេះបានមកពីប្រាក់ធានាក្តី និងបានមកពីប្រាក់សំណងដែលឈ្នះក្តី ។ មេធាវីត្រូវដាក់មូលនិធិនេះក្នុងគណនីពិសេសមួយដែលបើកឡើងដោយគណៈមេធាវី ហើយមាន ឈ្មោះថា «បេឡាទូទាត់របស់គណៈមេធាវី» ។

មេធាវីពុំអាចរក្សាទុកមូលនិធិនេះនៅក្នុងបេឡានោះឲ្យលើសពីថិរៈវេលាចាំបាច់ ដើម្បីសំរេចកិច្ចការដែលអតិថិជនប្រគល់ឲ្យនោះទេ ។ គេពុំអាចកាត់យកកំរៃដែលគេត្រូវទទួល ក្នុងការសំរេចលទ្ធផលការងារពីមូលនិធិខាងលើនេះឡើយ លើកលែងតែមានការយល់ព្រមជា លាយលក្ខណ៍អក្សរពីអតិថិជន ។

មេធាវីអាចយកមូលនិធិដែលអតិថិជនបានតម្កល់ទុកសំរាប់បង់ប្រដាប់ក្តី និងកំរៃ អ្នកជំនួយការយុត្តិធម៌ទៅបង់ជំនួសអតិថិជនបាន ។

មាត្រា ៧១.-

មេធាវីអាចត្រូវបានតែងតាំងជាអ្នកទទួលទុកបញ្ញើ តាមការព្រមព្រៀងពីភាគី ឬពីចៅក្រម ។ កិច្ចព្រមព្រៀង ឬសេចក្តីសំរេចអំពីការទទួលទុកបញ្ញើត្រូវកំណត់បែបបទ ជាពិសេស បែបបទនៃការប្រាក់ ព្រមទាំងបែបបទបញ្ចប់ទទួល

ទុកបញ្ជី ។ មូលនិធិ ឬវត្ថុទាំងឡាយ ត្រូវរក្សាទុកក្នុងបេឡាទូទាត់របស់គណៈមេធាវី ។

មាត្រា ៧២.-

មេធាវីត្រូវមានគណនេយ្យវិជ្ជាជីវៈមួយដោយឡែកស្របតាមច្បាប់ និងបទបញ្ជាផ្ទៃក្នុង ។ ការទូទាត់ប្រើមូលនិធិ ឬវត្ថុបញ្ញើត្រូវធ្វើឡើងក្នុងគណនេយ្យមួយដោយឡែក ។

មេធាវីត្រូវបង្ហាញបញ្ជីគណនេយ្យវិជ្ជាជីវៈរបស់ខ្លួន និងត្រូវបង្ហាញបញ្ជីគណនេយ្យផ្ទាល់ខ្លួនប្រសិនបើមាន ដល់អ្នកត្រួតពិនិត្យ ចាត់តាំងឡើងដោយក្រុមប្រឹក្សាគណៈមេធាវី។

មាត្រា ៧៣.-

មេធាវីត្រូវបង្ហាញថាខ្លួនបានបង់ប្រាក់ធានារ៉ាប់រងតាមរយៈគណៈមេធាវីសំរាប់ ធានារ៉ាប់រងការទទួលខុសត្រូវរបស់ខ្លួនក្នុងវិជ្ជាជីវៈ និងធានារ៉ាប់រងការសងមូលនិធិ និងរបស់មានតម្លៃទាំងឡាយដែលខ្លួនបានទទួលទុក ។ ប្រាក់ធានានោះត្រូវគិតបញ្ចូលក្នុងប្រាក់បង់វិភាគ-ទាន ដែលកំណត់ដោយគណៈមេធាវី ។

## ជំពូកទី ៧

## ការជំនួស ការខាររដ្ឋបាល

មាត្រា ៧៤.-

មេធាវីដែលអាក់ខានប្រកបវិជ្ជាជីវៈរបស់ខ្លួនជាបណ្ដោះអាសន្ន អាចចាត់តាំងអ្នកជំនួសម្នាក់ដោយមានការយល់ព្រមពីប្រធានគណៈមេធាវី ។ បើគ្មានការចាត់តាំងជំនួសទេនោះ ប្រធានគណៈមេធាវីចាត់តាំងអ្នកជំនួសដោយបញ្ញត្តិ ។

មាត្រា ៧៥ -

សេចក្ដីសំរេចហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈកាល ឬផ្អាកការប្រកប

វិជ្ជាជីវៈជាបណ្ដោះអាសន្ន ឬដាក់នៅក្រៅបញ្ជីគណៈមេធាវី ត្រូវចាត់តាំងមេធាវីម្នាក់ឲ្យគ្រប់គ្រងការិយាល័យមេធាវីជំនួស ។ បើអ្នកគ្រប់គ្រងការិយាល័យនោះមានធុរៈ ប្រធានគណៈមេធាវីត្រូវចេញសេចក្ដីសំរេចចាត់តាំងអ្នកជំនួស ។

មាត្រា ៧៦ -

បើមេធាវីម្នាក់ទទួលមរណភាព ឬឈប់ប្រកបវិជ្ជាជីវៈរបស់ខ្លួន ប្រធានគណៈមេធាវីចាត់តាំងមេធាវីម្នាក់ឲ្យទទួលបន្ទុកចាត់ការលើសំណុំរឿង ដែលនៅសល់ និងជម្រះបញ្ជីគណនេយ្យ រួចបិទការិយាល័យ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

មាត្រា ៧៧.-

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ១ ២ ៣ ៤ ៥ ៦ ៧ ១៣ និង ៥៧ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ រៀលទៅដល់ ៥.០០០.០០០ រៀល ។ បើបទល្មើសនោះ ប្រព្រឹត្តឡើងដោយជនបរទេស ជននោះអាចត្រូវបណ្ដេញចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាថែមទៀត ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យទ្វេមួយជាពីរ និងអាចត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៣ ដល់ ៦ ខែ ។

បើមានបទល្មើសខាងលើនេះ ក្រុមប្រឹក្សាគណៈមេធាវីអាចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបាន ។

មាត្រា ៧៨.

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ៥៨ ត្រូវផ្ដន្ទាទោសតាមបទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ ។

# ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

មាត្រា ៧៩.-

តួនាទីការពារកូនក្តីរបស់មេធាវីក្នុងរឿងព្រហ្មទណ្ឌអាចត្រូវបំពេញបានដោយអ្នកការពារក្តី ដែលមិនមែនជាមេធាវី តាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

មាត្រា ៨០.-

អាចត្រូវបានជ្រើសរើសឲ្យប្រឡងចូលរៀនក្នុងវគ្គបណ្តុះបណ្តាលមេធាវី ៖

- អ្នកការពារកូនក្តីដែលមានលទ្ធភាពបំពេញមុខងារនេះ ហើយដែលបំពេញមុខងារនេះពិតប្រាកដ និងជាប់រហូត ២ ឆ្នាំមក នៅតាមតុលាការខេត្ត ក្រុង ។ អ្នកការពារកូនក្តីទាំងនេះ ត្រូវមានកម្រិតចេះដឹងឧត្តមសិក្សាពី ២ ឆ្នាំឡើងទៅ ។
- មន្ត្រីរាជការដែលបានបម្រើការងាររដ្ឋ ២ ឆ្នាំ យ៉ាងតិច ហើយដែលមានសញ្ញាប័ត្រមធ្យមសិក្សានីតិសាស្ត្រ ។

អ្នកដែលមានបរិញ្ញាប័ត្រច្បាប់ ឬសញ្ញាប័ត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមមូល មិនចាំបាច់ប្រឡងទេ ។

មាត្រា ៨១.-

អាចទទួលឲ្យចុះឈ្មោះ ក្នុងបញ្ជីសំរាប់ឲ្យប្រឡងចូលរៀនក្នុងវគ្គបណ្តុះបណ្តាលមេធាវីបាន ស្របតាមមាត្រាខាងលើ អ្នកដែលមិនដែលត្រូវបានផ្តន្ទាទោសជាក់ពន្ធនាគារពីបទល្មើសព្រហ្មទណ្ឌណាមួយ

មាត្រា ៨២.-

វគ្គបណ្តុះបណ្តាលមានរយៈពេលយ៉ាងតិច ៨ ខែ ។ កម្មវិធី និងបែបបទនៃវគ្គបណ្តុះបណ្តាលព្រមទាំងកម្មវិធី និងបែបបទនៃការប្រឡង ដើម្បីត្រួតពិនិត្យ លទ្ធផលនៃការបណ្តុះ បណ្តាលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងករណីដែលមិនទាន់មានក្រុមប្រឹក្សាគណៈមេធាវី ។

អ្នកដែលប្រឡងជាប់ នឹងត្រូវទទួលវិញ្ញាបនប័ត្រសម្បទា សំរាប់ប្រកបវិជ្ជាជីវៈមេធាវី ។

មាត្រា ៨៣.-

មិនចាំបាច់មានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងមិនចាំបាច់ធ្វើកម្មសិក្សា ចំពោះ ៖

- អ្នកមានបរិញ្ញាប័ត្រច្បាប់ ឬអ្នកមានសញ្ញាប័ត្រច្បាប់ ដែលបានប្រកាសថាមានតម្លៃសមមូល ហើយបានបំរើការងារក្នុងវិស័យច្បាប់ ឬតុលាការរយៈពេល ២ ឆ្នាំ យ៉ាងតិច
- អ្នកមានសញ្ញាប័ត្របណ្ឌិតច្បាប់
- ចៅក្រម ឬអតីតចៅក្រមដែលបានបំរើការងារក្នុងវិជ្ជាជីវៈរយៈពេលយ៉ាងតិច ២ ឆ្នាំ ។

មាត្រា ៨៤.-

មុនពេលបង្កើតបានគណៈមេធាវី អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានភារកិច្ចទទួលនិងពិនិត្យពាក្យសុំប្រកបវិជ្ជាជីវៈមេធាវី ហើយកោះអញ្ជើញអ្នកដែលបានបំពេញលក្ខខណ្ឌសព្វគ្រប់ ឲ្យមកធ្វើសច្ចាប្រណិធានចំពោះមុខសាលាឧទ្ធរណ៍ដើម្បីបំពេញឋានៈជាមេធាវី និងចូលរួមមហាសន្និបាតបង្កើតគណៈមេធាវី ។

មាត្រា ៨៥.-

មហាសន្និបាតត្រូវរៀបចំបោះឆ្នោត ក្រោមការទទួលខុសត្រូវរបស់មេធាវីដែលមានវ័យចាស់ជាងគេ ដើម្បីជ្រើសរើសប្រធានគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវី

មាត្រា ៨៦.

មួយឆ្នាំក្រោយមកទៀត ត្រូវរៀបចំការបោះឆ្នោតជ្រើសរើសប្រធានគណៈមេធាវីថ្មីម្នាក់ និងក្រុមប្រឹក្សាគណៈមេធាវីថ្មីមួយ ដោយមេធាវីទាំងអស់ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី ។

មាត្រា ៨៧.-

ក្នុងករណីចាំបាច់ អាណត្តិនៃក្រុមប្រឹក្សាគណៈមេធាវី និងប្រធានគណៈមេធាវី ដែល ជាប់ឆ្នោតលើកដំបូង ត្រូវបន្តរហូតដល់ការប្រកាសលទ្ធផលនៃការ បោះឆ្នោតជ្រើសរើសប្រធានគណៈមេធាវីថ្មី និងក្រុមប្រឹក្សាគណៈមេធាវីថ្មី ។

មាត្រា ៨៨.-

ដោយមិនទាន់គិតដល់មាត្រា ១៤ និងមាត្រា ១៥ អ្នកដែលមានសិទ្ធិ បោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោតដូចមានចែងក្នុងមាត្រា ៨៤ គឺមេធាវី ទាំងឡាយដែលបានចុះឈ្មោះក្នុងបញ្ជីនៃគណៈមេធាវី និងក្នុងបញ្ជីកម្មសិក្សា ដោយមិនគិតពីអតីតភាព ។

មាត្រា ៨៩.-

អនុក្រឹត្យនេះ មានអានុភាពអនុវត្តរហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ។

# ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា ៩០.-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១

ព្រះហស្តលេខា

**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា

**ហ៊ុន សែន**

បានបង្គំទូលថ្វាយនិងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និង ទី២

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

**ចែម ស្នួន**

លេខ ..[illegible].ក.ច.ល.

[illegible]

រាជធានីភ្នំពេញ ថ្ងៃទី .[illegible] ខែ សីហា ឆ្នាំ ១៩៩៥

[illegible]

[illegible] តាន់

# ឧបសម្ព័ន្ធ២.

## អនុក្រឹត្យលេខ: ៥០៥ អនក្រ.តត  ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៥០៥ អនក្រ.តត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# អនុក្រឹត្យ

ស្តីពី

# ការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥

-យោងតាមភាពចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

**សំរេច**

**មាត្រា ១.-**

តែងតាំងលោក **ម៉ែនសុន សម័យ** សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាមាន អត្តលេខ ៥៤ បន្ថែមលើមុខងារបច្ចុប្បន្នជា សារការី ដែលហៅថា "**មេធាវីសារការី**" ។

**មាត្រា ២.-**

**មេធាវីសារការី** ជាមន្ត្រីសាធារណៈ ទទួលបាននូវអំណាចសាធារណៈតាមការតែងតាំងដោយអនុក្រឹត្យនេះ ។

**មាត្រា ៣.-**

**មេធាវីសារការី** មានសមត្ថកិច្ចការងារទូទៅក្នុងវិស័យផ្នែកគ្រួសារ ចលនវត្ថុ និងអចលនវត្ថុ ជាអាទិ៍មាន :

ក. ទទួល និងធ្វើ ឬចារីកបញ្ជាក់ និងប្រថាប់ត្រា នូវលិខិតស្នាមគតិយុត្តិ ឬកិច្ចសន្យាទាំងឡាយដើម្បីជាបន្ទាល់

ពេញលក្ខណៈតាមផ្លូវច្បាប់ ដែលតែងតែមានលិខិតរបស់រាជការអំណាចសាធារណៈ ។

ខ. ធ្វើការបញ្ជាក់លើកាលបរិច្ឆេទ ទទួលតំកល់ទុកឯកសារ និងចេញអោយនូវសេចក្តីដើម ឬសេចក្តីចម្លងនៃលិខិត ឬកិច្ចសន្យាទាំងឡាយនោះតាមមុខការ ។

គ. កិច្ចការនេះត្រូវពិនិត្យ អានឱ្យអស់សេចក្តី និងចុះហត្ថលេខានៃគូភាគីនៅចំពោះមុខ ទើប **មេធាវីសារការី** ចុះហត្ថលេខា ប្រថាប់ត្រា ចារឹកនាពេលនោះជាចុងក្រោយ ។

**មាត្រា ៤.-**

**មេធាវីសារការី** ត្រូវតំកល់ប្រាក់ធានាចំនួន ៦០០.០០០.០០០.០០ (ប្រាំមួយរយលានរៀល) នៅធនាគារជាតិនៃកម្ពុជាសំរាប់ទទួលខុសត្រូវក្នុងមុខការនេះ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

**<u>ចម្លងជូន</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- ឯកសារ -កាលប្បវត្តិ

# ឧបសម្ព័ន្ធ៣.

## អនុក្រឹត្យលេខៈ ១៤៤ អនក្រ.បក  ស្តីពីការទទួលស្គាល់ មន្ទីរសារការី អេស ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៤៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការទទួលស្គាល់មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានទទួលស្គាល់ការបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា** (**H.B.S Notary Public of the Kingdom of Cambodia**) សរសេរកាត់ជាភាសាខ្មែរ "**អ.ប.អ.ស**" និងសរសេរកាត់ជាភាសាអង់គ្លេស "**H.B.S.N**"។

**មាត្រា ២.-**

មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា មានទីតាំងដើមស្ថិតនៅអគារពាណិជ្ជកម្មសូមិា ផ្លូវលេខ ១២០ សង្កាត់ ផ្សារថ្មីទី ១ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ។

**មាត្រា ៣.-**

មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា មានតួនាទី និងភារកិច្ចដូចតទៅ :

- ទទួលធ្វើរាល់លិខិតស្នាមគតិយុត្ត ឬកិច្ចសន្យាទាំងឡាយ ដែលរូបវន្តបុគ្គល ឬនីតិបុគ្គលនៃនីតិឯកជន ឬនីតិបុគ្គលនៃនីតិសាធារណៈមានកាតព្វកិច្ចផ្តល់យថាភូតភាពតាមច្បាប់កំណត់ ឬមានបំណងផ្តល់យថាភូតភាពដោយខ្លួនឯង
- ទទួលបញ្ជាក់រាល់លិខិតស្នាមគតិយុត្ត ឬកិច្ចសន្យាទាំងឡាយ ដែលរូបវន្តបុគ្គល ឬនីតិបុគ្គលនៃនីតិឯកជន ឬនីតិបុគ្គលនៃនីតិសាធារណៈមានកាតព្វកិច្ចតាមច្បាប់កំណត់ ឬឆន្ទៈខ្លួនឯង
- បញ្ជាក់ធានាហត្ថលេខា និងកាលបរិច្ឆេទ នៃលិខិតស្នាមគតិយុត្ត ឬកិច្ចសន្យា
- ផ្តល់យថាភូតភាពលើឯកសារបកប្រែពីភាសាបរទេសមកភាសាខ្មែរ និងពីភាសាខ្មែរទៅភាសាបរទេស
- ធ្វើសំណើចុះបញ្ជី និងលេខាចារឹកទៅស្ថាប័នមានសមត្ថកិច្ច
- ធ្វើការរក្សាទុកច្បាប់ដើមនៃលិខិតស្នាមគតិយុត្ត និងកិច្ចសន្យា
- ធ្វើការរក្សាទុកច្បាប់ដើមនៃមតកសាសន៍
-ចេញច្បាប់ចម្លងនៃលិខិតយថាភូត និង
- ទទួលធ្វើ និងបញ្ជាក់រាល់លិខិតស្នាមគតិយុត្តផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ ។

**មាត្រា ៤.-**

មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា ត្រូវគ្រប់គ្រងដោយសារការី **ឈី តែសេខ** ជាប្រធាន និងសារការី **តាន់ម៉ាង ជាចំណ្ណ** ។

**មាត្រា ៥.-**

មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា ត្រូវតំកល់ប្រាក់ធានាចំនួន ៦០០,០០០,០០០.០០ (ប្រាំមួយរយលានរៀល) នៅធនាគារជាតិ នៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងមន្ទីរសោរការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៧*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ* ✓

# ឧបសម្ព័ន្ធ៤.

## អនុក្រឹត្យលេខ: ២០៣ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសាការីមេគន្ថ

## នៃព្រះរាជាណាចក្រកម្ពុជា

## ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៧០៣ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតមន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**មាត្រា១ .-**

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា** **(MEKONG Notary Public of the Kingdom of Cambodia)** សរសេរកាត់ជាភាសាខ្មែរ "**ម.ស.ម.**" និងសរសេរកាត់ជាភាសាអង់គ្លេស "**M.N.P.**"។


www.pheakdeylaw.com

**មាត្រា២ .-**

ត្រូវបានតែងតាំងជាសារការីនូវបុគ្គលដែលមានរាយនាមដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោកស្រី | **ចាំង** | **ស្រីពៅ** | ដើម្បីបំពេញមុខងារជាប្រធាននៃមន្ទីរសារការីមេគង្គ |
| ២-លោក | **សៅ** | **ឡឿន** | ដើម្បីបំពេញមុខងារជាអនុប្រធាននៃមន្ទីរសារការីមេគង្គ |
| ៣-លោក | **ប៉ាន់** | **វាសនា** | ដើម្បីបំពេញមុខងារជាសមាជិកនៃមន្ទីរសារការីមេគង្គ |
| ៤-លោក | **ផង់** | **វិចិត្រ** | ដើម្បីបំពេញមុខងារជាសមាជិកនៃមន្ទីរសារការីមេគង្គ។ |

ក្នុងករណីចាំបាច់ មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា អាចធ្វើការជ្រើសរើសសារការី ដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀត សម្រាប់ជួយបំពេញតួនាទី និងភារកិច្ច របស់ខ្លួនបាន។

**មាត្រា៣ .-**

មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការនៅផ្ទះលេខ ២២ ផ្លូវលេខ ២៨១ ភូមិទី១៤ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ក្នុងករណីមានការផ្លាស់ប្តូរទីស្នាក់ការ មន្ទីរសារការីត្រូវជូនដំណឹងមកក្រសួងយុត្តិធម៌។

**មាត្រា៤ .-**

មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងនីតិបុគ្គលគ្រប់ប្រភេទ
- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយ តាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំនូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបានយថាភូតភាពពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានាតាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ធានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ធ្វើសំណើចុះបញ្ជី ឬចុះលេខាចារឹកទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកតោភាគីផ្សេងៗ មតកសាសន៍ និងលិខិតស្នាមគ្រប់ប្រភេទ
- ចេញច្បាប់ចម្លងនៃលិខិតយថាភូត
- និងទទួលធ្វើកិច្ចការផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។



www.pheakdeylaw.com

**មាត្រា៥ ..**

នៅពេលចាប់ផ្ដើមប្រតិបត្តិការសកម្មភាពរបស់ខ្លួន មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរំលាយមន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា ប្រាក់តម្កល់ខាងលើនេះត្រូវបង្វិលជូនស្ថាបនិក និងសហភាតាដែលមានសិទ្ធិក្នុងការទទួល បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងប្រាក់សោហ៊ុយនានា ដែលចាំបាច់សម្រាប់ធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

ទំនាក់ទំនងគតិយុត្តរវាងស្ថាបនិក និងសហភាតា ត្រូវកំណត់ដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងដែលត្រូវអនុម័តដោយ មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៦ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា និងសាមីខ្លួនដូចចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែកញ្ញា ឆ្នាំ២០១៦

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៧
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com

# ឧបសម្ព័ន្ធ៥.

## ប្រកាស លេខ: ៣២ កយ.ប្រក/១២
## ស្តីពីការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារគារី
## ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខ: [illegible]

រាជធានីភ្នំពេញ. ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

# ប្រកាស

## ស្តីពី

## ការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារគតិ

### រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមការចាំបាច់

### សម្រេច

ប្រការ ១:

ត្រូវបានកំណត់ជាមន្ត្រីទទួលបន្ទុកកិច្ចការសារការី នៅតាមបណ្តាសមត្ថកិច្ច នៃសាលាដំបូង សាមីខ្លួនដូចមានរាយនាមខាងក្រោម:

**ក.រាជធានីភ្នំពេញ**

១-ឯកឧត្តម ហ៊ួត ហាក់

២-ឯកឧត្តម ជុច សំគី

**ខ.ខេត្តកណ្តាល**

១- ឯកឧត្តម កើត រិទ្ធ

២- លោក ខឡូ ប៊ុនធិសុទ្ធ

**គ-ខេត្តកំពង់ឆ្នាំង**

១-ឯកឧត្តម វិរ៉ល ចំរើន

២-លោក គុណ គិតុល

**ឃ.ខេត្តកំពង់ស្ពឺ**

១. ឯកឧត្តម ស៊ី សុជាតិ

២. លោក ឡូន ណារ៉ា

**ង.ខេត្តកំពត**

១. ឯកឧត្តម គាន ច័ន្ទមគ្គា

២. លោក អ៊ុច ស្រាយ

**ច.ខេត្តព្រះសីហនុ**

១.ឯកឧត្តម ឡៅ ជា

២.លោក ទៀម ច័ន្ទម៉ី

**ឆ.ខេត្តកោះកុង**

១.លោក តុម ឈុនហេង

២.លោក ហុង សុគុណចន្ធារា

**ជ.ខេត្តតាកែវ**

១.លោក មាស សុភក្តិ

២.ឯកឧត្តម អ៊ុំ សេរីវិសុទ្ធ

**ឈ.ខេត្តស្វាយរៀង**

១.ឯកឧត្តម គីម សន្តិភាព

២.លោក យក់ ប៊ុនណា

**ញ.ខេត្តព្រៃវែង**

១-លោក សាយ ណារ៉ូ

២-លោក សម ប៊ុនថុន

គ.ខេត្តកំពង់ចាម

១-លោក ឌាន់ សុភក្រ្ត

២-លោក ប៊ុន យ៉ៃណារិន

ឃ.កំពង់ធំ

១.លោក អ៊ុត សុធា

២. លោក សារឿន កោសល្យមុនី

ង.ខេត្តក្រចេះ

១. លោកស្រី ចាត សុរស្មី

២. ឯកឧត្តម សំ រិទ្ធី

ច.ខេត្តពោធិ៍សាត់

១-លោក ម៉ិច ចាន់សុយុទ្ធារា

២-លោក សៀង ធីរិទ្ធ

ឆ.ខេត្តបាត់ដំបង

១-លោក ហ៊ុន ប៊ុនថន

២-លោក ផាន់ គីរមៀ

ជ.ខេត្តប៉ៃលិន

១.លោក ជុំ សែនសទ្ធា

២.លោក អ៊ុំ សាទិញ

ឈ.ខេត្តបន្ទាយមានជ័យ

១-លោក ផាន់ ចន្ទធ្នារ័ត្ន

២-លោក គី ម៉ាឆេរ៉ា

ញ. ខេត្តសៀមរាប

១-លោក កើត ចន្ទារ័ត

២-លោក ស្រ៊ា រតនៈ

ឍ. ខេត្តឧត្តរមានជ័យ

១. លោក កុយ គាន់យ៉ា

២. ឯកឧត្តម មួន សុមុនី

ណ.ខេត្តព្រះវិហារ

១.លោក ជុំ ស

២.ឯកឧត្តម កៅ ថាច

ប.ខេត្តរតនៈគិរី

១.លោក ឈាង ស្រេង

ប្រការ ២:

មន្ត្រីទទួលបន្ទុកកិច្ចការសារការី ដូចមានរាយនាមខាងលើ ត្រូវអនុវត្តកិច្ចការសារការី ក្នុងអំឡុងពេលរហូតដល់កាលបរិច្ឆេទ នៃការអនុវត្តច្បាប់ស្តីពីលក្ខន្តិកៈនៃសារការី។

មន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវធ្វើកិច្ចការរបស់សារការីដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងធ្វើការចាត់ចែងផ្សេងទៀត ដែលមានកំណត់ក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌។

ប្រការ ៣:

ប្រកាសលេខ ៤៧ កយ.ប្រក/១២ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់ក្រសួងយុត្តិធម៌ ត្រូវទុកជានិរាករណ៍។

ប្រការ ៤:

សាមីខ្លួនដូចមានរាយនាមក្នុងប្រការ១ ខាងលើ និងស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធិភាព តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍានា

ចម្លងជូន :

- ខុទ្ទកាល័យ សម្តេចតេជោ នាយករដ្ឋមន្ត្រី
- សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- អយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ៦.

## អនុក្រឹត្យលេខ: ១១៧ អនក្រ.បក ស្តីពីការបង្កើតសាលតុមិន្ទសារភារី នៃរាជបណ្ឌិតសភាវិជ្ជាជីវ:តុលាការ

## ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតសាលាបណ្តុះបណ្តាលសារការី នៃរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១២៩៧ / ៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០១០៥ / ០១៤ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៦៩៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបែងចែកសមាសភាពគ្រប់គ្រងរបស់រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ
- តាមការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៨

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានបង្កើត សាលាភូមិន្ទសារការី ស្ថិតនៅក្នុងរចនាសម្ព័ន្ធនៃការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់ រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ ។

## ជំពូកទី ២
## តួនាទី និងភារកិច្ច

មាត្រា ២.-

សាលាភូមិន្ទសារការី មានតួនាទី និងភារកិច្ច ដូចតទៅ ៖

- ទទួលបន្ទុកការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូង និងបណ្តុះបណ្តាលបន្ត សម្រាប់សារការី
- លើកយុទ្ធសាស្ត្រការងារ និងរៀបចំផែនការសកម្មភាពបណ្តុះបណ្តាលវិជ្ជាជីវៈសារការី
- រៀបចំតាក់តែងឯកសារគរុកោសល្យសម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈសារការី
- រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូ សម្រាប់បណ្តុះបណ្តាលសារការី
- តាមដានត្រួតពិនិត្យការសិក្សា និង ការគោរពវិន័យរបស់សិស្សសារការី
- ត្រួតពិនិត្យការធ្វើកម្មសិក្សារបស់សិស្សសារការី
- ធ្វើរបាយការណ៍ប្រចាំឆ្នាំ លើស្ថានភាពសីលធម៌ និងគម្រោងការអភិវឌ្ឍន៍របស់សាលា ជូនប្រធានរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការមុននឹងបញ្ជូនទៅក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ
- ត្រួតពិនិត្យ និងចាត់ចែងលើការងារដឹកនាំរបស់ផ្នែកចំណុះ ។

ការបណ្តុះបណ្តាលសារការី ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ ដោយការជិតស្និទ្ធជាមួយក្រសួងយុត្តិធម៌ ។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**មាត្រា ៣.-**

សាលាភូមិន្ទសារការី មានផ្នែកចំណុះពីរគឺ ៖

- ផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងសម្រាប់សារការី
- ផ្នែកបណ្តុះបណ្តាលបន្តសម្រាប់សារការី ។

ផ្នែកនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអាចមានអនុប្រធានមួយចំនួន តាមការចាំបាច់ ។

ប្រធានផ្នែកនីមួយៗ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលាភូមិន្ទសារការី ត្រូវកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

**មាត្រា ៤.-**

សាលាភូមិន្ទសារការី ដឹកនាំការងារបច្ចេកទេស ដោយនាយកមួយរូប ។

នាយកសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

នាយកសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវជ្រើសរើសក្នុងចំណោម ចៅក្រម ឬ ឥស្សរៈជនខ្មែរជាន់ខ្ពស់ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រ ឬផ្នែកគ្រប់គ្រង ឡើងទៅ ឬសញ្ញាប័ត្រវិជ្ជាជីវៈសារការី ។

នាយកសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គឺជាសមាជិកអញ្ជើញរបស់ក្រុមប្រឹក្សាភិបាល នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

## ជំពូកទី ៤
## ការប្រឡងប្រជែងជ្រើសរើសសិស្សសារការី និង ការបណ្តុះបណ្តាល

**មាត្រា ៥.-**

ការប្រឡងប្រជែងជ្រើសរើសសិស្សសារការី ត្រូវកំណត់ដោយប្រកាសរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។



រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវទទួលបន្ទុករៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សសារការី ដោយមានការចូលរួមសហការពីក្រសួងយុត្តិធម៌ ។

មាត្រា ៦.-

បេក្ខជនដែលប្រឡងប្រជែងចូលរៀន សាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិខ្មែរ ។ ចំពោះបេក្ខជនជានិស្សិត ត្រូវមានអាយុមិនលើសពី ៣៥ឆ្នាំ រីឯបេក្ខជនជាមន្ត្រីរាជការ ត្រូវមានអាយុមិនលើសពី៤០ឆ្នាំ គិតមកត្រឹមថ្ងៃប្រឡង
- ត្រូវមានសញ្ញាប័ត្របរិញ្ញាបត្រនីតិសាស្ត្រ ឡើងទៅ
- ត្រូវមានលិខិតថ្កោលទោសបញ្ជាក់ថា មិនធ្លាប់ជាប់ទោសពីបទមជ្ឈិម ឬ បទឧក្រិដ្ឋ
- ត្រូវមានកាយសម្បទាគ្រប់គ្រាន់ ។

មាត្រា ៧.-

បេក្ខជនដែលបានប្រឡងប្រជែងជាប់ជាស្ថាពរនៅ សាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវតែងតាំងជាសិស្សសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ ក្នុងរយៈពេលនៃការបណ្តុះបណ្តាល សិស្សសារការី ត្រូវទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ តាមការកំណត់របស់រដ្ឋ ។

មាត្រា ៨.-

សិស្សសារការី ត្រូវទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងសម្រាប់សារការីឱ្យបានពេញលេញតាមកម្មវិធីសិក្សាដែលត្រូវកំណត់ដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

សិស្សសារការីដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងសម្រាប់សារការី ដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រវិជ្ជាជីវៈសារការី ដែលចេញដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

## ជំពូកទី ៥
## ធនធានហិរញ្ញវត្ថុ

មាត្រា ៩.-

សាលាភូមិន្ទសារការី មានថវិកា ដែលផ្គត់ផ្គង់ដោយរដ្ឋ សម្រាប់អនុវត្តការងាររបស់ខ្លួន ។
ថវិការបស់សាលាភូមិន្ទសារការី ស្ថិតនៅក្នុងកញ្ចប់ថវិការបស់រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

មាត្រា ១០.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១១.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ... ខែ សីហា ឆ្នាំ ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

*កន្លែងទទួល:*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១១*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*